ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 31-Jan-2012, 14:16
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង
# សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី៣០ ខែមករា ឆ្នាំ២០១២**

**ម៉ោង ០៩:០៥ នាទី**

**សវនាការលើកទី២៣**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ម៉ាតេអូ គ្រីប៉ា
*(Mr.Matteo CRIPPA)*

លោក ឌុច ផារី

កញ្ញា ណាតាចា វីស៊ែល រីសឺ
*(Ms. Natacha WEXELS-RISER)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង

លោក វេង ហ៊ត់

លោក ឌេល លីសាក់
*(Mr. Dale LYSAK)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក មៃខល ផេសមិន

*(Mr. Michiel PESTMAN)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកគែន

*(Arthur VERCKEN)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក មៃខល កាណាវាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោកស្រី ទី ស្រ៊ីនណា

លោកស្រី ស៊ីន សុវ៉ន

លោក ហុង គីមសួន

លោក អូលីវីយេ បាហ៊ូញ

*(Mr. Olivior BAHOUGNE)*

កញ្ញា ហ្វីលីពីន ស៊ុតហ្ស៍

*(Ms.Phillipine SUTZ)*

លោក បាណាបេ ណេគ្វី

*(Mr. Barnabé NEKUIE)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក កូវ កែវរតនៈ

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ | បារាំង |
| លោក សេង ប៊ុនឃាង | ខ្មែរ |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក សុន អរុណ | ខ្មែរ |
| លោក ម៉ៃខល ផេសមិន | អង់គ្លេស |
| លោក អាកទួរ វែកគែន | បារាំង |
| លោក អាង ឧត្តម | ខ្មែរ |
| លោក គង់ សំអុន | ខ្មែរ |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| កញ្ញា ហ្វីលីពីន ស៊ុតហ្ស៍ | បារាំង |
| លោក នួន ជា | ខ្មែរ |
| លោកស្រី ប្រាក់ យុត | ខ្មែរ |

# ខ្ទបសម្ព័ន្ធ

**ការសួរសំណួរទៅជនជាប់ចោទ នួន ជា**

សួរដោយលោក ខេល លីសាក់ ផ្ដើមពី៖ ........ទំព័រ ០១

សួរដោយលោក សេង ប៊ុនឃាង ផ្ដើមពី៖ ........ ទំព័រ ២៣

**ការសួរសំណួរទៅលោកស្រី ច្បាក់ យុត** (TCP-542)

សួរដោយកញ្ញា ហ្វីលីពីន ស៊ុតហ្ស៍ ផ្ដើមពី៖ ........ទំព័រ ៤២

សួរដោយលោក ម៉ៃខល ផេសមិន ផ្ដើមពី៖ ........ទំព័រ ៥២

សួរដោយចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ ផ្ដើមពី៖ ........ទំព័រ ៦១

# កិច្ចដំណើរការនីតិវិធី

[០៩:០៥:០០]

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ដំណើរការសវនាការនៅព្រឹកនេះ អង្គជំនុំជម្រះនឹងបន្តសួរចម្លើយជនជាប់ចោទ នួន ជា ដូចនៅលិខិតជូនដំណឹងដល់ភាគីកាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០១២ រួចហើយ។

អនុរក្សមន្ទីរឃុំឃាំងឲ្យនាំលោក នួន ជា មកកាន់ឈើរាងរង់ក្រចកសេះនៅចំពោះមុខអង្គជំនុំជម្រះ!

មន្ត្រីតុលាការមើលរៀបរយប្រដាប់ស្ដាប់សំឡេងរបស់គាត់ តើអាចចំទេ? ដូចជាអាចនៅខិតលើម្ខាង ខិតលើខាង-- ជួយៗរៀបគាត់បន្តិចទៅ!

នៅព្រឹកនេះ អង្គជំនុំជម្រះបន្តកិច្ចដំណើរការក្នុងការសួរជនជាប់ចោទ នួន ជា ដោយសហព្រះរាជអាជ្ញា។ ហើយអង្គជំនុំជម្រះសូមរំឭកសហព្រះរាជអាជ្ញាថា សហព្រះរាជអាជ្ញាមានពេលវេលាតែមួយព្រឹកទៀត មួយព្រឹកនេះទេតែប៉ុណ្ណោះ។ ដូច្នេះសូមសហព្រះរាជអាជ្ញាគិតគូរអំពីពេលវេលានេះ ធ្វើយ៉ាងណាឲ្យកិច្ចដំណើរការប្រព្រឹត្តទៅដោយមានប្រសិទ្ធភាព។ សូមប្រគល់វេទិកាជូនទៅសហព្រះរាជអាជ្ញា។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

លោក នួន ជា នៅពេលដែលយើងខ្ញុំសួរសំណួរចុងក្រោយទៅកាន់លោក យើងនិយាយអំពីៗទីក្រុង និងទីរួមខេត្តនៅក្នុងប្រទេសកម្ពុជា ថាតើមានអ្វីកើតឡើងនៅពេលដែលគេរំដោះក្នុងឆ្នាំ៧២ ដល់ ៧៣ នៅតាមទីរួមខេត្ត និងទីក្រុងនោះ?

**ស៖** នៅពេលនេះខ្ញុំសូមសួរលោកអំពីគោលនយោបាយបក្ស តើលោកចាំដែរឬទេ ថានៅក្នុងឆ្នាំ ៧២ ទៅដល់ឆ្នាំ១៩៧៣ ថាតើវាមានការខ្វែងយោបល់គ្នាក្នុងចំណោមមេដឹកនាំបក្សដែរឬទេ

ដែលចង់ឲ្យលុបចោលនូវទ្រព្យសម្បត្តិឯកជននោះ?

**លោក នួន ជា៖**

**ឆ៖** សូមគោរពលោកប្រធាន សូមគោរពបងប្អូនរួមជាតិទាំងអស់នៅទីនេះ និងទូទាំងប្រទេស។ តាមខ្ញុំចាំ-- អត់ទោស! លោកសួរថាម៉េច? ខ្ញុំភ្លេចហើយ។

**ស៖** ថាតើមានមេដឹកនាំបក្សក្នុងចន្លោះ៧២ទៅដល់ឆ្នាំ៧៣នោះ តើមានមេដឹកនាំបក្សមួយចំនួនដែលគាត់មិនគាំទ្រឲ្យមានការលុបចោលនូវទ្រព្យសម្បត្តិឯកជនដែរឬទេ?

**ឆ៖** អ៎! តាមខ្ញុំចាំ មិនមានលុបចោលកម្មសិទ្ធិឯកជនទេ។ មានតែបញ្ហាដី ឯទ្រព្យសម្បត្តិរួម ឯទ្រព្យសម្បត្តិអីទុកជាឯកជនទាំងអស់។ ដីធ្លីយកមកចូលសហករណ៍។ សូមជម្រាបលោកប្រធាន។

[០៩:១១:១៥]

**ស៖** ខ្ញុំសូមអាននូវសេចក្តីថ្លែងការណ៍នៅក្នុងចន្លោះខែកុម្ភៈ ដល់ខែមីនា ឆ្នាំ១៩៧៦ នៅក្នុងទង់បដិវត្ត។ នៅក្នុងនោះរួមមានដូចតទៅ៖ "នៅពាក់កណ្តាលឆ្នាំ៧២ បក្សប្រកាសជាបន្ទាន់លើជំហរទៅលើពួកគហបតី និងពួក*ប៊ូហ្សឺរស៊ី* ពួកគហបតី។ នេះគឺជាការចាប់ផ្តើមនៃការតស៊ូវណ្ណៈនៅក្នុងបក្សដើម្បីធ្វើយ៉ាងណាទប់ទល់ទៅលើពួកប្រឆាំង។ បក្សមិនត្រឹមតែវាយនៅក្នុងផ្ទៃក្នុងនោះទេ បក្សត្រូវតែប្រឈមនៅក្នុងសង្គម ដើម្បីរៀបចំលក្ខខណ្ឌជាមុនក្នុងការបង្កើតសហករណ៍"។

ឯកសារនេះចេញពី D243/2.1.3 អង់គ្លេស 00517844 បារាំងលេខ ERN គឺ00492790 ខ្មែរ ERN គឺ0063228។

ដូច្នេះ ខ្ញុំសួរទៅលោក នួន ជា ថាលោកចាំដែរឬទេ នៅក្នុងឆ្នាំ១៩៧២ គឺមានការប្រកាសជាបន្ទាន់ថា នៅក្នុងបក្សមានសមាជិកមួយចំនួននៅប្រកាន់ជំហរវណ្ណៈគហបតី និងវណ្ណៈអនុធន? តើលោកចាំទៅលើចំណុចហ្នឹងដែរឬទេ?

[០៩:១៣:០៨]

**ឆ៖** សូមគោរពលោកប្រធាន បញ្ហានេះជាខាងផ្នែករដ្ឋាភិបាល ឯខាងខ្ញុំ ខាងបក្សទទួលខាងអប់រំឯណោះទេ។ ដូច្នោះខ្ញុំមិនទាក់ទងអីនឹងបញ្ហាខាងរដ្ឋបាលទេ។

**ស៖** តើត្រឹមត្រូវដែរឬទេ លោក នួន ជា ដែលថានៅពាក់កណ្តាលឆ្នាំ៧២ បក្សចាប់ផ្តើមអនុវត្តបង្កើតនូវសហករណ៍នៅតាមតំបន់រំដោះមួយចំនួននោះ?

**ឆ៖** សូមជម្រាបលោកប្រធាន ពេលនោះមិនទាន់ចាត់តាំងជាសហករណ៍អីទេ គឺចាត់តាំង

ដំបូងឡើយពីសមាគមស្រូវ សមាគមជួយឧបត្ថម្ភគ្នាពេលឈឺថ្កាត់ សមាគមជួយសង្គ្រោះគ្នាអីៗសិន។ បន្តិចៗគឺពីទាបទៅខ្ពស់ ហើយបានក្រោយមកទៀតបានពេលណាសមាគមនេះបានពង្រីកទៅ ទើបចាប់ផ្ដើមចាត់តាំងសហករណ៍បណ្ដើរៗ ហៅថា "សហករណ៍ថ្នាក់ទាប"។

[០៩:១៥:៥៦]

**ស៖** ឯកសារបក្សជាច្រើនបានយោងទៅលើថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៣ ដែលនៅថ្ងៃនោះ គឺជាថ្ងៃដែលបក្សចាប់ផ្ដើមបង្កើត និងចាត់តាំងឲ្យមានសហករណ៍។ តើលោកចាំទេ ថាអំពីថ្ងៃទី២០ ខែឧសភា ឆ្នាំ៧៣ ដែលបក្សបង្កើតសហករណ៍ដែរឬទេ?

**ឆ៖** សូមជម្រាបលោកប្រធាន ខ្ញុំមិនចាំទេ។

**ស៖** ថាតើតាមដែលលោកចាំ សហករណ៍បានបង្កើតជាដំបូងនៅឆ្នាំដែរណា?

**ឆ៖** សូមជម្រាបលោកប្រធាន សហករណ៍មិនមែនចាត់តាំងទូទាំងប្រទេសភ្លាមទេ គឺកន្លែងដែលអង្គការមហាជន ដូចដែលខ្ញុំបានជម្រាបអំមិញហ្នឹង គឺដូចជាសមាគមស្រូវ សមាគមជួយសង្គ្រោះគ្នារឹងហើយ បានចាប់កន្លែងហ្នឹង ចាត់តាំងសហករណ៍បណ្ដើរៗ។ ដូច្នោះ វាមិនបានព្រមគ្នាទេ។ រកទៅកំណត់ឆ្នាំនោះវាមិនបានទេ ពីព្រោះវាខុសគ្នា សភាពការណ៍គ្នាខុសគ្នា។ ឯចាត់តាំងនេះ ចាត់តាំងពីខាងចុងកាត់មាត់ញកមកមុន មិនមែនចាត់តាំងទីប្រជុំជននោះទេ។

**ស៖** តើបក្សហេតុផលអ្វីដែលសម្រេចឲ្យមានការចាត់តាំងបង្កើតជាសហករណ៍នោះ?

**ឆ៖** សូមជម្រាបលោកប្រធាន បក្សសម្រេចចាត់តាំងសហករណ៍ ខ្ញុំសូមជម្រាបថា បញ្ជាក់ណ៎ា ខ្ញុំសូមបញ្ជាក់ថា សហករណ៍ទាបសិន មូលហេតុគឺមកដើម្បីប្រមូលប្រជាជន បើធ្វើការរាត់រាយទៅ វាខាតកម្លាំងពលកម្ម។ ឧទាហរណ៍ ឧបមាថា ៥០គ្រួសារៗនេះ បើដាំបាយ វាត្រូវខាត៥០នាក់ ៦០នាក់ទៅហើយ ប៉ុន្តែបើចាត់តាំងសហករណ៍រួមគ្នាធ្វើការងារ រួមគ្នាហូបបាយទៅ ចំណាយមនុស្សតិចហើយចំណេញឲ្យធ្វើពលកម្មច្រើន។

[០៩:១៧:៥៣]

**ស៖** តើនរណាគេដែរ ដែលជាអ្នកសម្រេចឲ្យមានការអនុវត្តបង្កើតសហករណ៍? ជាការសម្រេចពីគណៈមជ្ឈិម ឬគណៈអចិន្ត្រៃយ៍ ឬក៏យ៉ាងម៉េច?

**ឆ៖** សូមជម្រាបលោកប្រធាន បញ្ហានេះ គឺគណៈអចិន្ត្រៃយ៍ជាអ្នកសម្រេច ក៏ប៉ុន្តែបញ្ហានេះស្ដាប់មតិពីខាងក្រោម ពីកសិករក្រ កសិករកណ្ដាលឡើងមក គឺបានសេចក្ដីថា ស្ដាប់មតិមហាជនសិន

បានរៀបចំចាត់តាំង បើថាមហាជនគេសុខចិត្តហើយ សឹមយើងចាត់តាំងសហករណ៍។

**ស៖** ខ្ញុំចង់អានចេញពីសេចក្ដីសម្រេចរបស់បក្ស ដែលក្នុងនោះលើកឡើងថា គម្រប់ខួបលើកទីបីនៃសហករណ៍ នៃការបង្កើតសហករណ៍ ថ្ងៃ២០ ខែឧសភា ឆ្នាំ១៩៧៣ រហូតដល់ ២០ ខែឧសភា ៧៦។ ឯកសារ D366/7.1.6.1។ ឯកសារនេះលេខ E3/50។ ឯកសារនេះ រួមដំណកស្រង់ដូចតទៅ៖ "នៅក្នុងឆ្នាំ១៩៧២ ដល់ ៧៣ បក្សចាត់វិធានការ ចាត់តាំងប្រជាជនដោយផ្អែកទៅលើការយល់ដឹងផ្នែកនយោបាយ ដើម្បីគាបសង្កត់លើអំណាចរបស់ពួកមានអំណាច ហើយធ្វើយ៉ាងណាកាត់ផ្ដាច់ទៅលើកម្លាំងពាណិជ្ជកម្ម រៀបចំជាសហករណ៍។ វិធានការនៅក្នុងនោះ គឺការបង្កើតសហករណ៍។ គឺធ្វើយ៉ាងណា វាយទៅលើកម្លាំងអ្នកដែលជាម្ចាស់ដី និងពួកមូលធន"។ ឯកសារនេះ មាននៅក្នុងឯកសារ ERN00363009 បារាំងគឺ0036 សុំទោស! 623783 ខ្មែរគឺ00442209 ខ្ញុំចង់សួរថាតើការអនុវត្តបង្កើតសហករណ៍នេះគឺជាយុទ្ធសាស្ត្ររបស់បក្ស ដើម្បីធ្វើយ៉ាងណាវាយប្រហារទៅលើអ្នកដែលជាម្ចាស់ដី ឬក៏នាយទុន ពួកសក្ដិភូមិ មែនដែរទេ?

[០៩:២០:៣០]

**ជ៖** សូមជម្រាបលោកប្រធាន ការចាត់តាំងសហករណ៍ ដូចជាខ្ញុំបានជម្រាបហើយ ខ្ញុំនៅខាងបក្សទទួលនាទីខាងអប់រំ ឯសហករណ៍នៅខាងរដ្ឋបាល ក៏ប៉ុន្តែតាមខ្ញុំដឹងខ្លះ គឺចាត់តាំងសហករណ៍នេះដើម្បីកែប្រែជីវភាពប្រជាជន ប្រមូលកម្លាំងប្រជាជន មិនមែនសំដៅទៅវណ្ណៈនេះ វណ្ណៈនោះជាសំខាន់នោះទេ ក្រៅតែពីពួកប្រតិកិរិយា បរិវារ ចក្រពត្តិ ឃោរឃៅ។ ឯប្រជាជនពួកអ្នកមានដីធម្មតាអីៗ គេសុខចិត្តចូលសហករណ៍ ក៏គេចូល។

**ស៖** លោក នួន ជា តើលោកមិនបានអប់រំកម្មាភិបាលក្នុងបក្ស កម្មាភិបាលនៅក្នុងតាមតំបន់មួយចំនួនអំពីរបៀបនៃការបង្កើតសហករណ៍ទេ ឬយ៉ាងណានោះ?

**ជ៖** សូមជម្រាបលោកប្រធាន ការចាត់តាំងសហករណ៍ ខ្ញុំមិនបានអប់រំទេ អប់រំតែការចាត់តាំងសមាគមស្រូវ សមាគមអីៗអស់នេះអីផ្សេងៗទេ។ ឯសហករណ៍ ខាងផ្នែករដ្ឋាភិបាល គេចាត់តាំងគេរៀបចំ។

**ស៖** នៅពេលដែលលោកនិយាយថា រដ្ឋាភិបាលជាអ្នកចាត់តាំងនេះ តើលោកសំដៅលើអ្នកណាគេដែរ?

[០៩:២២:២៥]

**ឆៈ** គឺចាត់តាំង គឺរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ-- គឺកាលនោះ--- លោកសួរឆ្នាំ ៧២-៧៣ កាលនោះដូចមិនទាន់បានរំដោះផង។ ៧២-៧៣ នេះ នៅក្នុងរដ្ឋាភិបាលសង្គមរាស្ត្រនិយមនៅឡើយទេ។

**សៈ** ជាការពិត ថាតើនៅពេលនោះទីតាំងទឹកដីមួយចំនួនក្នុងប្រទេសកម្ពុជាមួយចំនួនស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម។ ដូច្នេះ នៅក្នុងទីតាំងដែលលោក ទីកន្លែងដែលលោកក្តោបក្តាប់ចន្លោះឆ្នាំ៧២ ទៅដល់៧៣ នោះ តើលោកអត់មានចាប់ផ្តើមអប់រំអំពីបញ្ហាបង្កើតសហករណ៍ទេ ឬក៏យ៉ាងណា?

[០៩:២៣:២០]

**ឆៈ** តាមខ្ញុំដឹងខាងផ្នែកគណៈតំបន់គេអប់រំបណ្តើរៗ។ ដូចខ្ញុំជម្រាបអ៊ីចឹង មិនមែនដាក់ភ្លាមពីព្រោះការភ្ញាក់រឭករបស់ប្រជាជន ជាពិសេសប្រជាជននៅចុងកាត់មាត់ញក មិនទាន់យល់ច្បាស់ហើយ ក៏មិនទាន់យល់អំពីការចាត់តាំងសហករណ៍អីទេ យល់តែពីការចាត់តាំងអង្គការផ្សេងៗ អង្គការសមាគមស្រូវអី ដូចខ្ញុំបានជម្រាបអ៊ីចឹងហើយ។ ហេតុដូច្នោះ ធ្វើបណ្តើរៗទៅ។

**សៈ** ខ្ញុំសូមសួរទៅលើចំនុចមួយចំនួនទៀត លោក នួន ជា។ តើលោកអាចជម្រាបអង្គជំនុំជម្រះបានដែរឬទេ ថាតើ សុន សេន មានតួនាទីអ្វីនៅចន្លោះឆ្នាំ៧៣ រហូតទៅដល់ ខែមេសា ឆ្នាំ១៩៧៥ តើ លោក សុន សេន មានកាន់តួនាទីខាងយោធាដែរឬទេ?

**ឆៈ** ជម្រាបលោកប្រធាន ខ្ញុំមិនចាំទេ។ ក៏ប៉ុន្តែ គាត់នៅក្នុងគណៈអចិន្ត្រៃយ៍ដែរ។

**សៈ** ថាតើលោកមានវត្តមាននៅក្នុងទីក្រុងភ្នំពេញញឹកញយប៉ុនណាដែរក្នុងចន្លោះឆ្នាំ៧២ រហូតទៅដល់ថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥?

**ឆៈ** ៧២, ៧៥ សូមជម្រាបលោកប្រធាន ខ្ញុំនៅក្នុងទីក្រុងភ្នំពេញខ្លះ ខ្ញុំចុះទៅជនបទខ្លះ។ មិនបាននៅជាប់ទីក្រុងភ្នំពេញទេ។

**សៈ** លោកនៅក្នុងទីក្រុងៗចុងក្រោយនៅក្នុងពេលណាដែរ ឆ្នាំណាដែរ មុនពេលដែលចាប់យកទីក្រុងភ្នំពេញនៅថ្ងៃទ១៧ ខែមេសា ឆ្នាំ១៩៧៥ ដូច្នេះតើលោកនៅភ្នំពេញហ្នឹង ចុងក្រោយគេនៅឆ្នាំណាដែរ?

**ឆៈ** ខ្ញុំជម្រាបលោកប្រធាន កាលនោះតាមខ្ញុំចាំ ដូចជាខ្ញុំមកនៅខាងខ្ញុំមកអប់រំខាងបូព៌ា។ ខ្ញុំចេញពីភ្នំពេញមកហើយ មកអប់រំខាងបូព៌ា។

[០៩:២៦:៣៧]

**ស៖** សំណួរដែលខ្ញុំចង់សួរលោកនោះ ថាតើលោកនៅទីក្រុងភ្នំពេញចុងក្រោយហ្នឹងនៅឆ្នាំណាដែរ ហើយមុនថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥នោះ?

**ឆ៖** ដូចជាខ្ញុំជម្រាបអ៊ីចឹង ១៧ មេសា ៧៥ ថ្ងៃរំដោះ១ ខ្ញុំនៅភ្នំពេញដែរ។ នៅដងស្ទឹងជីនិត។

**ស៖** លោកបានជម្រាបថាលោកនៅស្ទឹងជីនិត នៅថ្ងៃទី១៧ ខែមេសា ៧៥ ខ្ញុំចង់សូមសួរលោកថាតើមុនដែលលោកទៅស្ទឹងជីនិតនោះ។ តើចុងក្រោយគេដែលលោកចាកចេញពីភ្នំពេញហ្នឹង គឺនៅក្នុងឆ្នាំណាដែរ?

**ឆ៖** លោកចង់សួរថា ពេលចាកចេញពីភ្នំពេញហ្នឹង ពេលយួនចូលហ្នឹង ឬយ៉ាងម៉េច? ខ្ញុំចង់ឲ្យលោកសួរឲ្យច្បាស់។

**ស៖** ខ្ញុំសូមសួរម្តងទៀត តើលោកបានស្នាក់នៅទីក្រុងភ្នំពេញនៅក្នុងខែមករា ឆ្នាំ១៩៧៥ ឬក៏ខែមេសា ឆ្នាំ១៩៧៥ ឬក៏ខែកុម្ភៈ ឆ្នាំ១៩៧៥ ដែរឬទេ នៅក្នុងចន្លោះខែហ្នឹង តើលោកមាននៅក្នុងទីក្រុងភ្នំពេញដែរឬទេ មុនពេលថ្ងៃដែលចាប់យកទីក្រុងភ្នំពេញនៅថ្ងៃ១៧ ខែមេសា ១៩៧៥នោះ?

**ឆ៖** សូមជម្រាបលោកប្រធាន ខ្ញុំស្តាប់សំណួរ សំណួរលោកមិនសូវយល់។ សូមលោកសួរខ្លីៗបន្តិច។

[០៩:២៩:១១]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី!

**លោក សុន អរុណ៖**

សូមគោរពលោកប្រធាន សូមគោរពអង្គប្រជុំ។ តាមខ្ញុំស្តាប់សំណួរ និងចម្លើយរបស់លោកព្រះរាជអាជ្ញាជាមួយកូនក្តីខ្ញុំ ប្រហែលបញ្ហាបកប្រែទេមិនដឹង បកប្រែនិយាយ ខ្ញុំក៏ស្តាប់មិនសូវបានដែរ។ លោកប្រធានក៏ដោយ ហើយខ្ញុំជឿថាកូនក្តីខ្ញុំ សុខភាពគាត់ចាស់ចំណាស់នេះហើយ ចាប់មិនទាន់ទេអ៊ីចឹងម្ល៉ោះហើយ សូមឲ្យសួរឲ្យខ្លី ដូចគាត់មានប្រសាសន៍អំមិញអ៊ីចឹង ហើយបកប្រែឲ្យច្បាស់ ហើយកុំញាប់។ តែញាប់ គាត់ស្តាប់អត់បានទេ ច្រឡូកច្រឡំគ្នាហើយ ខ្ញុំស្តាប់ ឃើញគាត់ច្រឡូកច្រឡំពីរបីដងហើយ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណការកត់សម្គាល់របស់លោកមេធាវីការពារក្តី។ សាជាថ្មីម្តងទៀត អង្គជំនុំជម្រះសូម

រំឭកដល់សហព្រះរាជអាជ្ញាអន្តរជាតិសូមសហព្រះរាជអាជ្ញារៀបចំសំណួរខ្លីៗ ដើម្បីឱ្យគាត់ងាយយល់ ពីព្រោះបើមានការពន្យល់វែងទៅ ហើយបានតាំងសំណួរនៅក្នុងនោះអាចមានបញ្ហាដែរ ដោយសារច្រឡំរវាងការពន្យល់ហើយនិងតាំងសំណួរ។ ហើយអ្នកបកប្រែដូចគ្នា សូមឱ្យមានការបកប្រែឱ្យមានឃឹតហើយនិងជាក់ច្បាស់ ដើម្បីឱ្យស្តាប់យល់។

សូមអញ្ជើញ! តាំងសំណួរអម្បាញ់មិញនេះសាជាថ្មីម្តងទៀត។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ខ្ញុំចង់សុំសួរដោយសាមញ្ញថា តើលោកមាននៅក្នុងទីក្រុងភ្នំពេញដែរឬទេនៅចន្លោះខែមករា ឆ្នាំ១៩៧៥ ដល់ខែមីនា ឆ្នាំ១៩៧៥ នោះ?

[០៩:៣១:១០]

**លោក នួន ជា៖**

**ឆ៖** សូមគោរពលោកប្រធាន ឆ្នាំ១៩៧៥ ដើមខែឧសភា កងទ័ពវៀតណាមឈ្លានពានចូលបរិវេណខាងឆ្នេរសមុទ្រខាងកើតកំពត។ លើកទីប្រាំបី ថ្ងៃទី៨ ឧសភា កងទ័ពវៀតណាមចូលដីខ្មែរនៅជាប់ព្រំដែនខេត្តតៃនិញ។ នៅពេលនោះ ពេលកងទ័ពវៀតណាមចូលហើយ ពួកខាងខ្ញុំក៏ជម្លៀសទៅនៅជនបទ ព្រំដែនថៃ។

**ប្រធានអង្គជំនុំ៖**

សូមសួរម្តងទៀត ហើយលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិអាចតាំងសំណួរជាក់ច្បាស់ជាងនេះបានទេ គាត់ដូចជាស្តាប់សំណួរមិនបានទេ ឆ្លើយនូវការបរិច្ឆេទផ្សេងក្រៅពីផុតពីសំណួរដែលលោកសួរ។ លោកសួរគឺក្នុងអំឡុងខែមួយ ហើយដល់ខែមេសា ឆ្នាំ១៩៧៥។ ចំណែកឯគាត់ៗឆ្លើយខែឧសភា ឆ្នាំ១៩៧៥ ទៅហើយៗអង្គហេតុផ្សេងគ្នា រឿងដែនកោះដែនអីនោះវាឆ្ងាយវាណាស់។

[០៩:៣២:៥៦]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន ខ្ញុំនឹងព្យាយាមម្តងទៀត។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** សំណួររបស់ខ្ញុំគឺមិនទាក់ទងទៅនឹងពេលដែលក្រោយថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ នោះទេ គឺខ្ញុំសួរមុននឹង។ តើលោកចាំទេ ថាលោកមានវត្តមាននៅភ្នំពេញនៅចន្លោះខែមករា រហូតទៅដល់ ខែ

មេសា មុនខែមេសា ឆ្នាំ១៩៧៥ ហ្នឹង គឺមុនថ្ងៃរំដោះផង លោកវត្តមាននៅភ្នំពេញ នៅចាំទេ?

**លោក នួន ជា៖**

**ជ៖** សូមជម្រាបលោកប្រធាន ពេលនោះ ខ្ញុំនៅភ្នំពេញ។

**ស៖** នៅក្នុងសក្ខីកម្មរបស់លោកនៅថ្ងៃ១៤ ឆ្នាំ២០១១ លោកបាននិយាយថា នៅក្នុងអំឡុងពេលដែលលោក អៀង សារី នៅប៉េកាំង គាត់ត្រឡប់មកវិញមកកម្ពុជា ប្រហែលជាប្រាំ ឬប្រាំមួយខែ ខ្ញុំចង់សួរលោកថា តើលោកអាចប្រាប់តុលាការបានទេថា តើលោក អៀង សារី មកប្រទេសកម្ពុជាប៉ុន្មានដងនៅក្នុងឆ្នាំ១៩៧៣ និងឆ្នាំ១៩៧៤? តើលោកនៅចាំទេថា អៀង សារី ត្រឡប់មកកម្ពុជា ប៉ុន្មានដង?

**ជ៖** សូមជម្រាបលោកប្រធាន តាមខ្ញុំចាំមួយរយៈកាលដែលគាត់ទៅនៅក្រៅប្រទេស ហើយត្រឡប់មកវិញហ្នឹងតែពីរដងៗតែប៉ុណ្ណឹងទេ។

[០៩:៣៤:៤៨]

**ស៖** តើឱកាសពីរដែលថា លោកចាំថា លោក អៀង សារី មកពីរដងនៅឆ្នាំ១៩៧៣ និង៧៤ហ្នឹងគឺពីរដងហ្នឹង គឺក្នុងឱកាសណាដែរ? ពេលណា?

**ជ៖** តាមខ្ញុំចាំ ម្តងគាត់ជូនដំណើរព្រះករុណាមកធ្វើទស្សនកិច្ចនៅសៀមរាប។ ឯម្តងទៀត ខ្ញុំមិនចាំទេ។

**ស៖** តើខ្ញុំត្រូវទេ ថាទាក់ទងទៅនឹងទីពីរ ឬក៏ពេលមួយទៀត ដែលលោក អៀង សារី ដែលត្រឡប់មកវិញ លោកមិនចាំកាលបរិច្ឆេទច្បាស់លាស់ទេនៅពេលដែលគាត់ត្រឡប់មកកម្ពុជា តើត្រូវទេលោក?

**ជ៖** ជម្រាបលោកប្រធាន ខ្ញុំចាំមិនច្បាស់លាស់ទេ ព្រោះការងារខ្ញុំផ្សេង។ អានេះដូចខ្ញុំបានជម្រាបលោកប្រធានហើយ គឺថា ប៉ុល ពត គាត់ប្រាប់ខ្ញុំថាការងារខាងណោះ ទុកឲ្យគេធ្វើទៅ ខាងពួកបញ្ញាជន ខាងអីៗនោះ។ ឯមិត្តអនុវត្តមាគ៌ារណសិរ្សជាមួយបញ្ញាជន វាមិនផូរផង់។ ដូច្នោះគិតតែខាងអប់រំទៅ ធ្វើម៉េចអប់រំទៅសភាពការណ៍ វាប្រែប្រួលច្រើនហើយ។ ដូច្នោះបានជាខ្ញុំមិនបានជាយកចិត្តទុកដាក់អី អ្នកណាទៅណាមកណាអី ខ្ញុំគិតតែពីខាងបើកវគ្គអប់រំរៀនសូត្រ។

[០៩:៣៧:១៣]

**ស៖** ខ្ញុំចង់សួរសំណួរពីរបីទៅលើកទៀត អំពីទីប្រជុំជន ឬទីក្រុងខ្លះដែលត្រូវបានរំដោះដោយកងទ័ពបដិវត្តន៍កម្ពុជា មុនឆ្នាំ១៩៧៥ ថ្ងៃទី១៧ ខែមេសា។ នៅពេលដែលយើងពិភាក្សាពីមុនគឺថា យើង

ដកស្រង់ពីផ្នែកមួយនៃទស្សនាវដ្តីទង់បដិវត្តអំពីការអនុវត្តនូវការបញ្ជូនប្រជាជន នៃការដកប្រជាជនចេញពីទីក្រុង។ និយាយពីការវាយដណ្តើមប្រជាជននោះ ខ្ញុំសូមអានសេចក្តីថ្លែងការណ៍នៅថ្ងៃ នៅឆ្នាំ១៩៧៦ គឺនៅក្នុងទង់បដិវត្ត ដែលនិយាយដូចខាងក្រោមនេះទាក់ទងទៅនឹងការសហការគ្នាក្នុងការវាយប្រយុទ្ធឆ្នាំ៧៣៖ “យើងយកអ្វីៗនៅក្នុងក្រុងប៉ាកណាម ទាំងជនជាតិវៀតណាម ជនជាតិចិន កងទ័ព នគរបាល ហើយយើងចាប់យក យើងវាយយក ដកយកអ្វីៗចេញពីខ្មាំង”។ ឯកសារ D243/2.1.9 ខ្មែរERN 00063040 អង់គ្លេស 00491424 ហើយភាសាបារាំងERN00504049។

តើលោកអាចប្រាប់យើងបានទេ ថាតើប៉ាកណាម ហ្នឹងគឺស្ថិតនៅកន្លែងណា? ភូមិ ឬក៏ឃុំ បាទ?

[០៩:៣៨:៤៥]

**ឆ៖** សូមជម្រាបលោកប្រធាន។ ខ្ញុំមិនដែលស្គាល់ទេ ប៉ាកណាម។

**ស៖** ចុះពីឧដុង្គវិញ ថាតើបញ្ហាទាក់ទងនៅក្នុងទង់បដិវត្តនោះ និយាយសេចក្តីថ្លែងការណ៍ដូចខាងក្រោមនេះ៖ និយាយថា “យើងរំដោះឧដុង្គ នៅឆ្នាំ១៩៧៤ យើងដកយកប្រជាជនទាំងអស់ចេញ”។ តើលោកអាចជម្រាបតុលាការបានទេ ថាតើកងទ័ពអ្នកណាខ្លះដែលចូលរួមក្នុងការវាយកាន់កាប់ទីក្រុងឧដុង្គក្នុងឆ្នាំ១៩៧៤ នោះ?

**ឆ៖** សូមជម្រាបលោកប្រធាន ខ្ញុំមិនចាំថាកងទ័ពណាទេ ពីព្រោះខ្ញុំមិនបានទទួលខាងកងទ័ព។ ខ្ញុំមិនមានភារកិច្ចអីខាងកងទ័ពទេ។ ខាងកងទ័ព គឺខាង ប៉ុល ពត ខាង សុន សេន ទេ។

[០៩:៤០:០៣]

**ស៖** ថាតើគេយកអ្នកដែល ប្រជាជននៅក្រុងឧដុង្គទៅធ្វើអ្វីដែរ នៅពេលដែលឧដុង្គហ្នឹងត្រូវបានកាន់កាប់ដោយកងទ័ពបដិវត្តន៍កម្ពុជា ក្នុងឆ្នាំ១៩៧៤នោះ?

**ឆ៖** ខ្ញុំសូមជម្រាបលោកប្រធាន ក៏ដូចជារួមទូទាំងប្រទេសអ៊ីចឹង គឺថាទៅរស់នៅដើម្បីបង្កបង្កើនផលនៅតាមជនបទ ពីព្រោះពេលនោះខ្វះស្បៀងហើយ ភ្នំពេញខ្វះស្បៀងតាំងពីឆ្នាំ១៩៧៣ ម្ល៉េះ តាមខ្ញុំចាំ។ ដូច្នោះ ប្រជាជនគ្មានអីហូបទេ ដូច្នោះទៅរួមគ្នា បង្កបង្កើនផលនៅជនបទ ទៅធ្វើសហករណ៍នៅនោះ។ នេះតាមខ្ញុំចាំទេ ខ្ញុំមិនទៅធ្វើផ្ទាល់ទេ។

**ស៖** ប៉ុន្តែនៅក្នុងសុន្ទរកថាដែលបានអាននៅកូរ៉េខាងជើង ក្នុងឆ្នាំ១៩៧៤ ខៀវ សំផន បានរៀបរាប់អំពីការវាយប្រហារនៅប៉ាកណាមគឺថា៖ “នៅថ្ងៃ១៨ មីនា កងទ័ពបដិវត្តន៍កម្ពុជាបានរំដោះក្រុងមួយទៀត ក្រុងឧដុង្គ ដោយការបំផ្លិចបំផ្លាញកងទ័ពអាយ៉ងរបស់ លន់ នល់ ហើយម្យ៉ាងទៀតគឺថា ខ្មាំងជាង

ប្រាំពាន់នាក់ត្រូវបានកម្ទេច ១៥០០ ក្នុងចំណោមនោះត្រូវចាប់ខ្លួនបាន”។ ចប់សេចក្តីដកស្រង់ឯកសារ IS12.7 អង់គ្លេសគឺ 0285860 បារាំង ERN000122 ខ្មែរ ERN 00596141។ លោក នួន ជា តើលោកអាចប្រាប់តុលាការបានទេ ថាតើគេយកខ្មាំង១៥០០នាក់ ដែលគេចាប់ពីក្រុងឧដុង្គបានហ្នឹង គេយកទៅធ្វើអ្វី?

[០៩:៤២:២៦]

**ជ៖** សូមជម្រាបលោកប្រធាន បញ្ហាហ្នឹងចាំលោកសួរ លោក ខៀវ សំផន ទៅ ព្រោះខ្ញុំមិនដឹងទេ។

**ស៖** ឧដុង្គគឺស្ថិតនៅក្នុងមូលដ្ឋានបក្សដែលថា នៅជិតកំពង់ត្រឡាច ដែលថានៅក្នុងឃុំពាម ដែលយើងបានពិភាក្សាពីមុន តើបក្សមានមូលដ្ឋានយោធា ហើយនិងមន្ទីរសន្តិសុខទេ នៅក្នុងតំបន់នោះ? នៅក្នុងឆ្នាំ១៩៧៤?

**ជ៖** បញ្ហានេះ ខ្ញុំមិនដឹងទេ សូមជម្រាបគោរពលោកប្រធាន។

**ស៖** លោក នួន ជា នៅខែកញ្ញា តុលា ឆ្នាំ១៩៧៦ នៅក្នុងទង់បដិវត្ត ឯកសារ D443 គឺថា 1.7 ខ្មែរ ERN 0063095 អង់គ្លេស ERN 00450531 បារាំង ERN 00491897 បញ្ហាដែលស្ថិតនៅក្នុងទង់បដិវត្តនោះ គឺថានិយាយដូចខាងក្រោមនេះ៖ “នៅពេលដែលយើងជម្លៀសប្រជាជនពីទីក្រុង យើងអនុវត្តអំពីការតស៊ូវណ្ណៈ”។ ចប់សេចក្តីដកស្រង់។ តើលោកប្រាប់តុលាការបានទេ ថាតើនៅពេលលោកអនុវត្តការតស៊ូវណ្ណៈប្រឆាំងនឹងប្រជាជនដែលជម្លៀស ឬក៏តាមរយៈការជម្លៀសប្រជាជនចេញពីទីក្រុងហ្នឹង ជាការតស៊ូបែបណា?

[០៩:៤៤:២២]

**ជ៖** សូមជម្រាបលោកប្រធាន ខ្ញុំមិនចាំទេ ពីរឿងការតស៊ូវណ្ណៈ ក៏ប៉ុន្តែខ្ញុំចាំអីចេះគឺថារួមគ្នាធ្វើសហករណ៍ទៅ ដើម្បីចែកគ្នាហូប ឯតស៊ូវណ្ណៈ ទៅរឹបយកអីៗរបស់គេនោះ ខ្ញុំមិនដឹងទេ ព្រោះដូចខ្ញុំជម្រាបដដែលៗ ព្រោះខ្ញុំនៅខាងអប់រំ ឯខាងអប់រំហ្នឹង គឺថាវាមានគោលការណ៍របស់វា គឺថាមួយ កុំប៉ះពាល់ទ្រព្យសម្បត្តិប្រជាជន កុំប្រើអាជ្ញាអំណាច កុំប្រើអាជ្ញា កុំស្រី កុំស្រា កុំលុយ កុំកាក់ កុំល្បែងស៊ីសង ឯល្អិតយ៉ាងម៉េចៗខ្ញុំមិនចាំទេ ព្រោះវាច្រើនឆ្នាំមកទៅហើយ។

**ស៖** សូមអរគុណលោក នួន ជា។ ឥឡូវនេះខ្ញុំចង់ត្រឡប់ទៅរកសំណួរមួយចំនួនទាក់ទងទៅនឹងសេចក្តីសម្រេចរបស់បក្សក្នុងការជម្លៀសទីក្រុងភ្នំពេញ។ លោកបាននិយាយនៅក្នុងសក្ខីកម្មនៅក្នុងថ្ងៃ

១៣ ខែ១២ ឆ្នាំ២០១១ នោះថា សេចក្ដីសម្រេចជម្លៀសភ្នំពេញហ្នឹង គឺធ្វើឡើងក្នុងការប្រជុំជាច្រើនដង។ នៅពេលនោះលោកនិយាយអំពីកិច្ចប្រជុំមួយនៅខែឧសភា ឆ្នាំ១៩៧៤ ដែលគណៈអចិន្ត្រៃយ៍។ តើលោកជម្រាបអង្គជំនុំជម្រះបានទេ នៅក្នុងកិច្ចប្រជុំទាំងនោះ មានកិច្ចប្រជុំណាមួយដែលសម្រេចអំពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ?

**ន៖** ជម្រាបលោកប្រធាន ខ្ញុំមិនចាំទេ។

**ស៖** តើលោកនៅចាំទេថា មានការប្រជុំណាផ្សេងខុសពីនៅពាក់កណ្ដាលឆ្នាំ១៩៧៤ ដែលជាការប្រជុំវិសាមញ្ញរបស់គណៈអចិន្ត្រៃយ៍ ដែលនិយាយពីការជម្លៀសពីទីក្រុងភ្នំពេញហ្នឹង។ តើលោកនៅចាំទេ?

[០៩:៤៦:៥៥]

**ន៖** ខ្ញុំជម្រាបលោកប្រធាន ការប្រជុំហ្នឹង តាមខ្ញុំចាំប្រជុំឆ្នាំ១៩៦០ម្ដង អាហ្នឹងមិនទាន់មានជម្លៀសទេ។ ការប្រជុំឆ្នាំ១៩៦៣ម្ដង ប្រជុំឆ្នាំ១៩៧១ម្ដង ប្រជុំ១៩៧៣ម្ដង រួចហើយ១៩៧៨ម្ដង។ តាមខ្ញុំចាំ មួយរយៈហ្នឹងប្រជុំប្រាំ។ មានប្រជុំគណៈមជ្ឈិមប្រាំដង។ ខ្ញុំចាំប៉ុណ្ណឹង។

**ស៖** លោក នួន ជា ខ្ញុំសួរលោកអំពីពិសេសអំពីសេចក្ដីសម្រេចក្នុងការជម្លៀសប្រជាជនពីទីក្រុងភ្នំពេញ។ ពីមុននោះលោកបាននិយាយជាលម្អិតអំពីពាក់កណ្ដាលឆ្នាំ១៩៧៤ លោកនិយាយថា មានការប្រជុំវិសាមញ្ញមួយដើម្បីធ្វើការសម្រេចរឿងហ្នឹង តើលោកនៅចាំការប្រជុំហ្នឹងទេ? បាទ ឬក៏ទេ លោកអាចឆ្លើយអ៊ីចឹង។

**ន៖** សូមបញ្ជាក់ ឆ្នាំណាលោកព្រះរាជអាជ្ញា?

**ស៖** បាទ នៅឆ្នាំ១៩៧៤ មានការប្រជុំវិសាមញ្ញរបស់គណៈមជ្ឈិមទេ នៅពាក់កណ្ដាលឆ្នាំ៧៤ នេះ ដែលធ្វើសេចក្ដីសម្រេចក្នុងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ?

**ន៖** តាមខ្ញុំចាំដូចមាន។ មាន! ពីព្រោះពេលនោះសភាសហរដ្ឋ ដូចជាកាត់ថវិកាមិនឲ្យកប៉ាល់ហោះអាមេរិកទម្លាក់គ្រាប់បែកលើប្រទេសកម្ពុជាទេ។ ដូច្នោះកងទ័ព លន់ នល់ កាន់តែអន់ហើយស្បៀងអាហារក៏គ្មាន ដូច្នោះបានប្រជុំឆ្នាំហ្នឹងដើម្បីនឹងសម្រេចថាត្រូវជម្លៀសប្រជាជនបណ្ដោះអាសន្ន។

[០៩:៤៩:៤៩]

**ស៖** ហើយយើងព្យាយាមរកឲ្យឃើញថា តើពេលណាដែលកិច្ចប្រជុំនោះធ្វើឡើង គឺថាមានសេចក្ដីថ្លែងការណ៍នៅខែកញ្ញា ឆ្នាំ១៩៧៧ ទង់បដិវត្តនិយាយថា៖ "នៅក្នុងស្ថានភាពនេះ គណៈមជ្ឈិម

របស់បក្ស គឺតាមពិត គឺថានៅក្នុងការប្រជុំខែមិថុនា ឆ្នាំ១៩៧៤ គឺនឹងត្រូវធ្វើការអនុវត្តការជម្លៀសពីទីក្រុងភ្នំពេញ និងក្រុងផ្សេងៗ”។ ឯកសារ D43/2.1.12 ERN ខ្មែរ 0063162 ERN អង់គ្លេស 00486247 បារាំង ERN 0049836។ ថាតើពេលនៃការប្រជុំដែលលោករៀបរាប់នោះ គឺធ្វើសេចក្ដីសម្រេចដើម្បីធ្វើការជម្លៀសទីក្រុងភ្នំពេញ តើការប្រជុំដែលធ្វើឡើងនៅខែមិថុនា ឆ្នាំ១៩៧៤ ដែលឬទេ?

**ផ៖** សូមជម្រាបលោកប្រធាន ដូចខ្ញុំជម្រាបអំមិញហើយ។

**ស៖** តើលោកនៅចាំទេ ថាតើការប្រជុំរបស់គណៈមជ្ឈិមហ្នឹងធ្វើនៅកន្លែងណា ដែលសម្រេចដោយគណៈមជ្ឈិមសម្រេចជម្លៀសទីក្រុងភ្នំពេញហ្នឹង?

**ផ៖** តាមខ្ញុំចាំ ដូចនៅតាមដងស្ទឹងជីនិត។

**ស៖** តើលោកចាំទេ ប្រជុំហ្នឹងរយៈពេលហ្នឹងរយៈពេលប៉ុន្មានដែរ? ប៉ុន្មានម៉ោង ឬប៉ុន្មានថ្ងៃដែរ?

**ផ៖** ប្រជុំហ្នឹង តាមខ្ញុំចាំប្រហែលបីថ្ងៃ។ សូមគោរពលោកប្រធាន។

**ស៖** ថាតើសមាជិកអង្គប្រជុំពេលនោះមានគ្នាប៉ុន្មាននាក់?

**ផ៖** សូមជម្រាបលោកប្រធាន ខ្ញុំមិនចាំទេ ប៉ុន្តែមានតំណាងភាគដែលជាគណៈមជ្ឈិមនោះចុះទៅកាន់ភាគនោះមកគ្រប់ភាគមកប្រជុំ។

[០៩:៥៣:០០]

**ស៖** តើលោកអាចកំណត់អត្តសញ្ញាណរបស់សមាជិកអង្គប្រជុំ ឬក៏ឈ្មោះ? ឈ្មោះសមាជិកអង្គប្រជុំហ្នឹង ក្រៅពីលោកហ្នឹងមានអ្នកណាទៀត? ឲ្យតុលាការបានជ្រាបផង។

**ផ៖** តាមខ្ញុំចាំ ប៉ុល ពត, ខ្ញុំ, នួន ជា, តាម៉ុក, សោ ភឹម, កុយ ធួន។ តាមខ្ញុំចាំៗបានប៉ុណ្ណឹង។

**ស៖** តើលោកឯកភាពទេ ថាលោកមិនចាំឈ្មោះមនុស្សទាំងអស់ដែលចូលរួមកិច្ចប្រជុំហ្នឹងទេ? តើអ៊ីចឹងមែនទេលោក?

**ផ៖** មែន។ អ៎! សុន សេន ដែរ អត់ទោស!

**ស៖** តើលោកចាំទេ នៅក្នុងឆ្នាំ១៩៧៤ មានគណៈប្រតិភូមកពីប្រទេសចិនមកប្រទេសកម្ពុជាដើម្បីថតខ្សែភាពយន្តឯកសារនៅតំបន់រំដោះ តើលោកនៅចាំទេ ពីការវត្តមាននោះ?

[០៩:៥៤:៥៤]

**ឆ៖** សូមជម្រាបលោកប្រធាន ខ្ញុំមិនបានទាក់ទងអីទេ។ ខ្ញុំមិនចាំទេ ព្រោះទីនេះ ជានាទីខាងក្រសួងការបរទេសគេ។

**ស៖** សូមអរគុណ។ លោកបានរៀបរាប់ប្រាប់តុលាការអំពីការខ្វះស្បៀងអាហារនៅក្នុងទីក្រុងភ្នំពេញ ថាជាមូលហេតុសំខាន់នៃការធ្វើសេចក្ដីសម្រេចក្នុង៧៤ ដើម្បីជម្លៀសទីក្រុងភ្នំពេញដោយគណៈមជ្ឈិម។ ឥឡូវនេះ ខ្ញុំចង់ដឹងថាប្រជាជនដែលចេញពីភ្នំពេញ ថាតើលោកមានអាហារគ្រប់គ្រាន់ បើមានអាហារគ្រប់គ្រាន់នោះ តើគណៈមជ្ឈិមបែរជាសម្រេចថាមិនឲ្យគេនៅភ្នំពេញ បើសិនជាមានអាហារសម្រាប់គេគ្រប់គ្រាន់ហើយនោះ?

**ឆ៖** សូមជម្រាបលោកប្រធាន បើមានអាហារគ្រប់គ្រាន់នៅភ្នំពេញល្អជាង។ ពីព្រោះកាលនោះតាមខ្ញុំចាំ លន់ នល់ ក៏ខ្វះស្បៀង ឲ្យកងទ័ពខ្វះលុយបើកប្រាក់ខែឲ្យដែរ។ ដូច្នោះវាកើត ចលាចលពេញតែទីក្រុងភ្នំពេញហ្នឹង បាតុកម្មឡើងបាតុកម្មចុះ ដណ្ដើមស្បៀង ដណ្ដើមអាហារ។ ដូច្នោះ បានគណៈដឹកនាំហ្នឹង យល់ឃើញថា ដល់កាលណារំដោះទៅហ្នឹង មុខតែមានប្រកាប់ប្រចាក់គ្នា លួចប្លន់ ព្រោះពួកដែលចូលហ្នឹង សុទ្ធតែពួកអាវ៉ាសែពាលា យើងក្ដាប់មិនបានទេ។

[០៩:៥៧:០៥]

**ស៖** គណៈមជ្ឈិមបានធ្វើសេចក្ដីសម្រេចដើម្បីជម្លៀសភ្នំពេញហ្នឹង តើលោក នួន ជា យល់ថាវាអនុញ្ញាតឲ្យអ្នកណាម្នាក់នៅក្នុងភ្នំពេញទេ? ឬក៏សេចក្ដីសម្រេចនោះថា អ្នកភ្នំពេញទាំងអស់ ត្រូវតែជម្លៀសចេញទាំងអស់មិនឲ្យសល់?

**ឆ៖** តាមខ្ញុំចាំមានគណៈកម្មការដែលមកជម្លៀសនេះ។ គណៈកម្មការនេះ វាមាន សុន សេន ជាប្រធាន មាន កុយ ធួន ហើយមានសុទ្ធតែប្រធានភាគ ដូចជាគណៈជាកម្មការមកចាត់ចែងជម្លៀស។

**ស៖** ខ្ញុំយល់ហើយថា មានគណៈកម្មការមួយត្រូវបានបង្កើត។ ថាតើគណៈមជ្ឈិមជាអ្នកធ្វើសេចក្ដីសម្រេចទេ នៅខែឧសភា ឆ្នាំ១៩៧៤ ថាសេចក្ដីសម្រេចហ្នឹង ថាត្រូវជម្លៀសប្រជាជនទាំងអស់ចេញពីក្រុងភ្នំពេញនោះ?

[០៩:៥៨:៣៤]

**ឆ៖** ត្រូវហើយ ប៉ុន្តែបណ្ដោះអាសន្នទេ ចាំកាលណា-- ដើម្បីពិនិត្យមើលសភាពការណ៍ ពីព្រោះកាលនោះ វាទំនាស់ បើខ្ញុំនិយាយទៅ វាវែងបន្តិច។ ពេលរំដោះភ្នំពេញ កងទ័ពវៀតណាមរំដោះក្រោយទេ។ ក៏ប៉ុន្តែកងទ័ពវៀតណាមបានចូលទៅក្នុងភ្នំពេញហើយ ឯក្រៅពីនេះ ក៏មានកប៉ាល់ចម្បាំងរបស់

អាមេរិកឈ្មោះ អាម៉ៃយ៉ាហ្គេត បើកទៅចតនៅនេះ កោះតាង។ ដូច្នោះ គណៈមជ្ឈិមយល់ឃើញថា បើកាលណាកើតសង្គ្រាមនៅក្នុងទីក្រុងភ្នំពេញ មុខជាអន្តរាយច្រើនហើយ។ ប្រជាជនសម្លាប់ច្រើនណាស់ ហើយក៏គ្មានស្អីហូបទៀត។ ដូច្នោះ យើងសុខចិត្តឲ្យលំបាកសិនចុះ ហើយយើងទៅឯណោះ ក៏ខំសហករណ៍ ខំពង្រឹងសហករណ៍ឡើង ដើម្បីជួយដោះស្រាយស្បៀងឲ្យប្រជាជនដែលជម្លៀស។ អាហ្នឹងគឺមានទស្សនៈយ៉ាងនេះ។ ហើយបើសិនណាជាអាមេរិកបង្កើតសង្គ្រាមទៀត ពេលរំដោះ តើវៀតណាមខាងជើង តើវៀតណាម វៀតកុង កាលនោះហៅ វៀតកុង តើចូលជ្រៀតជ្រែកយ៉ាងម៉េច? បញ្ហានេះវាស្មុគស្មាញណាស់លោកប្រធាន។ មានទាំងអាមេរិក មានទាំងយួនធីវគី មានទាំងវៀតកុង មានទាំងអី ច្របូកច្របល់គ្នា។

[១០:០១:០០]

**ស៖** ដោយហេតុថា គណៈមជ្ឈិមសម្រេចថា ប្រជាជនទាំងអស់ត្រូវតែឲ្យជម្លៀសចេញពីទីក្រុង ថាតើអ្នកជំងឺនៅតាមមន្ទីរពេទ្យ អ្នកចាស់ជរាអី ត្រូវតែជម្លៀស ត្រូវតែអង្គការជម្លៀសឲ្យអស់ពីភ្នំពេញទេ? ត្រូវទេ?

**ឆ៖** ជម្លៀសទាំងអស់ ជួយសែង ជួយអីគ្នាទៅ អ្នកណាគេមានឡានគេទៅឡានទៅ អ្នកណាមានរទេះអូស ក៏ទៅរទេះអូសទៅ ព្រោះធ្វើម៉េចឲ្យចេញឲ្យផុតពីទីក្រុងសិន។

**ស៖** ថាតើមានមន្ទីរពេទ្យប៉ុន្មានដែរនៅក្នុងទីក្រុងភ្នំពេញ នៅក្នុងឆ្នាំ៧៥ហ្នឹង? លោក នួន ជា មានប៉ុន្មានដែរ?

**ឆ៖** ខ្ញុំមិនចាំទេ។ ប៉ុនតាមសំខាន់ មានពេទ្យមិត្តភាពសូវៀត ពេទ្យរដ្ឋ ពេទ្យរាជការ ប៉ុន្តែចំនួនប៉ុន្មានៗខ្ញុំមិនចាំទេ។

[១០:០២:១៨]

**ស៖** នៅពេលដែលគណៈមជ្ឈិមសម្រេចឲ្យជម្លៀសប្រជាជននៅក្នុងទីក្រុងភ្នំពេញទាំងអស់ តើលោកមានបានព្យាយាមកំណត់ និងគិតមើលថាតើមានមន្ទីរពេទ្យនៅក្នុងទីក្រុងភ្នំពេញប៉ុន្មាន ហើយមានអ្នកជំងឺប៉ុន្មានដែរ តើលោកមានដែលបានគិតមើលទេ?

**ឆ៖** មិនដែលបានគិតទេ ខ្ញុំសូមជម្រាបលោកប្រធាន។ អាល័យតែគិតឯណា បើសភាពការណ៍វាដល់ហើយ។ សំខាន់នោះខ្លាច-- ព្រោះពេលនោះអ៊ីចេះ ពេលដែលបែកភ្នំពេញ សឹង ជុំកថាញ់ៗ ទៅនៅវៀតណាមខាងត្បូងពីរខែមុន ទៅរៀបចំទ័ពនៅឯណោះ ហើយពេលបែកកងទ័ព ច័ន្ទ រង្សី នាំកងទ័ព

មួយចំនួន ម៉ាប្រហែលប៉ុន្មានកងវរសេនាធំ ទៅថៃ។ ដូច្នោះគណៈមជ្ឈិម ហើយនៅក្នុងទីក្រុងភ្នំពេញ តាមផ្ទះមួយៗសុទ្ធតែដាក់បារ៉ែត។ ដូច្នោះ គណៈអចិន្ត្រៃយ៍យល់ឃើញថា អាមេរិក នៅលើសកលលោក ដូចមិនដែលឲ្យអ្នកណា-- មិនដែលធ្វើបដិវត្តន៍ណារ៉ែយកបានទីក្រុងទេ។ ដូច្នោះខ្លាចជាឧបាយកលរបស់គេ អាហ្នឹងឲ្យត្រូវប្រយ័ត្ន ហើយជាពិសេស នៅពេលអាមេរិកវ៉ៃតើវៀតណាម វៀតកុងនៅស្ងៀមទេ? ព្រោះវៀតកុង ចាំតែមើល៍។ វៀតកុងស្តាយណាស់ដែលភ្នំពេញរំដោះមុនវៀតណាមខាងត្បូង គាត់ស្តាយណាស់។ គាត់ថាទោះបីជារំដោះភាគខាងត្បូងបាន បើយើងក្តាប់ បើយើងយកភ្នំពេញមិនបាន យើងខាតធំណាស់។ នេះមតិរបស់អ្នកដឹកនាំវៀតណាម។

[១០:០៥:៤៧]

**សៈ** លោក នួន ជា ថាតើមានសមាជិកគណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍មានការជំទាស់ទៅនឹងសេចក្តីសម្រេចក្នុងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញដែរឬទេ?

**ឆៈ** តាមខ្ញុំចាំ គ្មានទំនាស់ទេ សូមគោរពលោកប្រធាន។ ឯកភាពគ្នា។

**សៈ** ក្រោយពាក់កណ្តាលឆ្នាំ៧៤ ក្រោយពីកិច្ចប្រជុំពាក់កណ្តាលឆ្នាំ៧៤ ដែលបានធ្វើសេចក្តីសម្រេចជម្លៀសប្រជាជនទីក្រុងភ្នំពេញ។ តើលោកមានបានចូលរួមនៅកិច្ចប្រជុំក្រោយៗមកទៀតដែរឬទេ ស្តីអំពីការជម្លៀសប្រជាជនទីក្រុងភ្នំពេញនោះ តើលោកបានចូលរួមប្រជុំចុងក្រោយលើការជម្លៀសប្រជាជនទីក្រុងភ្នំពេញហ្នឹង ចូលរួមប្រជុំចុងក្រោយនៅពេលណាដែរ?

**ឆៈ** ខ្ញុំមិនចាំទេ សូមគោរពលោកប្រធាន ព្រោះវាយូរណាស់មកហើយ។

[១០:០៦:១៧]

**សៈ** នៅកិច្ចប្រជុំពាក់កណ្តាលឆ្នាំ៧៤ របស់គណៈមជ្ឈិមដែលលោកបាននិយាយអម្បាញ់មិញនេះ តើគណៈមជ្ឈិមនៅពេលប្រជុំ ពេលនោះមាននិយាយអំពីខ្មាំងជ្រៀតចូលបក្សដែរឬទេ? ហើយមានបានលើកឡើងអំពីការសម្រេចមិនឲ្យមានបេក្ខជនថ្មីចូលជាសមាជិកបក្សដែរឬទេ?

**ឆៈ** សូមជម្រាបលោកប្រធាន ពេលនោះខ្មាំងច្រើនណាស់។ ខ្ញុំសូមលើកឧទាហរណ៍មុនរំដោះពេលដែលរំដោះខាងក្រចេះមានកងទ័ព គេហៅថា មួយចំនួនទៅចាត់តាំងកងទ័ពនៅកំពង់ធំឯណោះ។ មេបញ្ជាការឈ្មោះ ឃុត ឧត្តមវង្សរតនា ដើម្បីរៀបចំវ៉ៃខាងណោះទៀត ប៉ុន្តែត្រូវប្រជាជនប្រឆាំង។ ហើយខាង សឹង ង៉ុកថាញ់ រៀបចំកងទ័ពពីវៀតណាមខាងត្បូងដើម្បីតម្រង់មកវ៉ៃទៀត។ នេះរឿងវាអ៊ីចឹង។ ហើយក្នុងភ្នំពេញបើថាមិនជម្លៀសអស់ ពួកដែលនៅសល់ ដែលតាមសេចក្តីអំពាវនាវរបស់

ព្រះករុណាឲ្យចូលព្រៃម៉ាគី វាមានទាំងអ្នកល្អ វាមានទាំងអ្នកអាក្រក់ ចូលព្រៃម៉ាគី មានពួកឥស្សរៈចាស់ដែលខ្ញុំជម្រាបឲ្យវែងបន្តិចចុះ។ ពួក ពុត ឆាយ, ពួក ច័ន្ទ រង្សី, ពួក កៅ តក, ពួក ហ៊ុល វង់អនុភាព, ពួកអីៗ សន្ធឹកសន្ធាប់ណាស់។

[១០:០៨:២៧]

ដូច្នោះវាមិនមែនសភាពការណ៍ស្ងប់ស្ងាត់ទេ។ ហើយពួកនេ៎! ម្សៀ ទុំ ពួកអីៗអស់នេះ ច្រើនបក្ស ច្រើនពួកណាស់ សុទ្ធតែពួកនេះ សុទ្ធតែពួកមិនមែនយកឈ្មោះបក្សបដិវត្តន៍បាំងមុខ ប៉ុន្តែដើររែអង្គ្គី ដើររែអង្គាសលុយប្រជាជន បើអ្នកណាមិនឲ្យសម្លាប់។ ពេលនោះបើលោកព្រះរាជអាជ្ញានៅភ្នំពេញផងបានយល់សភាពការណ៍ច្បាស់ ខ្ញុំនិយាយវាមិនយល់ច្បាស់ទេ ពីព្រោះខ្ញុំមិនបានចូលជិតភ្នំពេញដែរ។

**ស៖** ដោយសារតែមានការព្រួយបារម្ភចំពោះខ្មាំង តើវាត្រឹមត្រូវដែរឬទេដែលគណៈមជ្ឈិមបានសម្រេចបិទទ្វារមិនឲ្យមានសមាជិកថ្មីចូលបក្ស ហើយបន្ទាប់មកធ្វើការបោសសម្អាតផ្ទៃក្នុង។ តើពិតមែនដែរឬទេ នៅក្នុងពាក់កណ្តាលឆ្នាំ៧៤នោះ លោក នួន ជា?

[១០:១០:០០]

**ឆ៖** ពាក់កណ្តាល៧៤ តាមខ្ញុំចាំមិនមែនបិទទ្វារទេ គឺជ្រើសរើសណាស់អ្នកដែលចូលបក្ស។ ហើយមិន-- ពេលនោះតាមខ្ញុំចាំគឺពួកដែលឆ្លៀតឱកាសនិយម ពួកដែលគេហៅថា ធ្វើបដិវត្តន៍ឱកាសនិយម ជ្រៀតចូលច្រើនណាស់ ជាពិសេសពេលដែលព្រះករុណាលោក-- ពេលចូលព្រៃម៉ាគីហ្នឹង។ ដូច្នោះ សភាពការណ៍វាស្មុគស្មាញ ហើយកប៉ាល់ហោះអាមេរិកទម្លាក់គ្រាប់បែក២០០ថ្ងៃ ២០០យប់ ប្រជាជនស្លាប់ច្រើន។ សូមគោរពលោកប្រធាន ប៉ុណ្ណឹង។

**ស៖** ខ្ញុំសូមអាននូវទង់បដិវត្តនៅខែកុម្ភៈ ដល់ខែមីនា ឆ្នាំ១៩៧៦។ ឯកសារ D43/2.1.3 ខ្មែរ គឺ 000063229 អង់គ្លេសគឺ 00067884 ទៅដល់ 885 បារាំងគឺ 00492790។ ឯកសារហ្នឹងមានដូចតទៅ៖ "នៅដើមឆ្នាំ១៩៧៤ មានបញ្ហាខ្លាំងធ្វើចំពោះបក្សទៅលើកងទ័ពរបស់យើងទៅលើយុទ្ធជនប្រុសស្រីនិងសមាជិកនៅក្នុងសហករណ៍។ ដោយសារតែជំហរអធនរបស់បក្សមិនរឹងមាំនោះទេ ដូច្នេះហើយបានយើងធ្វើបោកសម្អាតនៅក្នុងបក្ស។ នៅក្នុងទំព័រដដែលនោះ គឺបក្សធ្វើការវាយតម្លៃទៅលើស្ថានភាព ហើយបន្ទាប់មកបិទទ្វារមិនឲ្យមានការចូលបក្ស។ បន្ថែមទៅលើចំណុចហ្នឹងទៀត គឺមានការបោសសម្អាតផ្ទៃសមាជិកបក្សផ្ទៃក្នុងទៀត។ តើលោកចងចាំដែរឬទេ លោក នួន ជា នៅក្នុងពាក់កណ្តាលឆ្នាំ ១៩៧៤ កម្មាភិបាលបក្សមួយចំនួនដែលត្រូវបានបក្សបោសសម្អាតនោះ គឺកម្មាភិបាលមកពីខេត្តកោះកុង

តើត្រឹមត្រូវដែរឬទេ?

[១០:១៣:១៤]

**ឆៈ** សូមជម្រាបលោកប្រធាន ខ្ញុំចាំបានខ្លះ ប៉ុន្តែខ្ញុំភ្លេចច្រើនដែលស្មុគស្មាញជាងគេនេះ គឺនៅភូមិភាគបូព៌ាទេ មិនមែននៅកោះកុងទេ។ នៅភូមិភាគបូព៌ា ពីព្រោះកាលនោះមានឈ្មោះ ចាន់ ចក្រី ដែលជាមេទាំបះបោរ ហើយវៀតណាមក៏នៅពាសពេញភូមិភាគបូព៌ាហ្នឹង ដើម្បី-- បើតាមខ្ញុំចាំចំនួនប្រហែលជា២៥.០០០នាក់តាមឮទេ។ នៅសឹងគ្រប់ទីកន្លែង ហើយស្បៀងអាហារអីៗអស់នេះក៏អាស្រ័យនៅលើប្រទេសមករស់នៅផង មកតាំងទ័ពផង ហើយមកហូបស្បៀងអាហារបាយទឹកអីនៅតែក្នុងប្រទេសកម្ពុជាទាំងអស់។

ដូច្នោះ នៅប្រទេសកម្ពុជា អ្នកខ្លះថាវៀតណាមមានសគុណលើប្រទេសកម្ពុជា ប៉ុន្តែការពិតកម្ពុជាទេដែលមានសគុណលើវៀតណាមឲ្យវៀតណាមមកជ្រកកោននៅក្នុងប្រទេសកម្ពុជា។ ពីព្រោះពេលនោះ អាមេរិកទម្លាក់គ្រាប់បែកខ្លាំងណាស់ រកកន្លែងនៅគ្មានទេ។ ខ្ញុំបានសួរ អ្នកស្រី ង្វៀន ធីប៊ិញ ដែលជាប្រធានកងទ័ពរណសិរ្សមកជួបៗ សោ ភឹម ដល់ត្រឡប់ទៅវិញ ខ្ញុំសួរថាគាត់មកធ្វើអី? ថាគាត់មកសុំកន្លែង ដើម្បីឲ្យកងទ័ពនៅ ពីព្រោះនៅណោះ រកកន្លែងនៅគ្មានទេ។ ចម្ការកៅស៊ូអីៗហ្នឹងវាអស់ស្លឹកអស់អីទៅហើយ។ ដូច្នោះហ្នឹងគឺថា ការពិតហ្នឹង ដូចជាប្រេង ខ្ញុំជម្រាបឲ្យអស់ទៅចុះ ដូចជាអីៗនេះ បន្តកាត់តាមរតនគិរី មណ្ឌលគិរី បន្តមកពីហាណូយ មកតាមផ្លូវហូជីមិញនោះ ដែលប្រេង ដែលចិនជួយអីហ្នឹង។

[១០:១៦:០១]

ដូច្នោះបដិវត្តន៍កម្ពុជានេះ ការតស៊ូរបស់កម្ពុជានេះ ជួយវៀតណាមមិនតិចទេ។ ព្រោះអ្នកដឹកនាំវៀតណាមកាលនោះ តាំងពីឆ្នាំ៦០ ម្ល៉េះ មកនៅក្នុងកម្ពុជាទេ ខ្ញុំសុំ-- ខ្ញុំស្គាល់ហើយ។ ដូចជា ឡេយន់នេះ ង្វៀន វ៉ាន់ លិញ នេះ ហាយសូ នេះ ស៊ួអីអស់នេះ មករស់នៅខាងត្បូងសាលារៀនយុគន្ធរ នៅម្តុំហ្នឹងតើ! មានទៅនៅវៀតណាមឯណា។ ប៉ុន្តែអ្នកដែលមិនដឹង ចេះតែថាវៀតណាមមានសគុណលើខ្មែរច្រើនណាស់។ នេះអ្នកដែលមិនដឹង។ អានេះខ្ញុំសូមឆ្លៀតឱកាសនេះ ខ្ញុំសូមជម្រាបឲ្យអស់ចុះ វាក្រៅបញ្ហាបន្តិច សូមលោកប្រធានអធ្យាស្រ័យ។ ប៉ុន្តែឲ្យយល់ទាំងអស់គ្នា ឲ្យបងប្អូនជំនាន់ក្រោយនេះ យល់ធាតុពិតរបស់-- យល់មហិច្ឆតារបស់វៀតណាមយ៉ាងម៉េច អីយ៉ាងម៉េច? បានប៉ុណ្ណឹងហើយ ដើរឃោសនាទាំងលើសកលលោកទៀត ថាខ្មែរបានអាស្រ័យវៀតណាមទេជួយ។ វាទៅជាអីចឹងទៅវិញទៅ។

[១០:១៧:៣៤]

**ស៖** លោក នួន ជា តើលោកចាំដែរឬទេ លោក ប្រាសិទ្ធ មេដឹកនាំពីខេត្តកោះកុងនោះ តើលោកចាំទេ?

**ជ៖** ខ្ញុំគ្រាន់តែឮទេ ឮថាមកពី-- មិនមែនប្រាសិទ្ធ ទេ ប្រសិទ្ធ។

**ស៖** តើលោកអាចជម្រាបអង្គជំនុំជម្រះបានដែរឬទេ ថាមានអ្វីកើតឡើង ចំពោះលោក ប្រសិទ្ធ ហ្នឹង នៅឆ្នាំ១៩៧៤?

**ជ៖** តាមខ្ញុំដឹងថាមកតាមផ្លូវមានពួកចោរព្រៃស្ទាក់វ៉ៃ កាលនោះខាង គាត់នៅខាង គាត់ឡើងខាងនិរតីទេ គាត់ឡើងជាមួយ តាម៉ុក នៅជាមួយ តាម៉ុក។ ហើយ តាម៉ុក ហៅមក។ ហៅមក ស្រាប់តែដើរកាត់ព្រៃមក មានពួកចោរព្រៃវាស្ទាក់វ៉ៃ ស្លាប់ប៉ុន្មាននាក់ទៅ។ នេះ ខ្ញុំឮ។

**ស៖** សូមអរគុណលោក នួន ជា។ នៅក្នុងសេចក្ដីថ្លែងរបស់លោកៗបានលើកឡើងអំពីមន្ទីរមូលដ្ឋាន ហៅថា ប-៥ ដែលនៅជិតពាម ឃុំពាម។ តើលោកអាចជម្រាបអង្គជំនុំជម្រះទេ ប-៥ នេះជាអ្វីដែរទៅ?

**ជ៖** ខ្ញុំក៏ចាំមិនច្បាស់ដែរ ប៉ុន្តែ ប-៥ នេះជាកន្លែងធ្វើការមួយរបស់ ប៉ុល ពត។

**ស៖** តើ ប-៥ បង្កើតឡើងនៅក្នុងឆ្នាំណាដែរ?

**ជ៖** តាមខ្ញុំចាំ ពេលដែលវ៉ៃ ពេលត្រៀមវ៉ៃរំដោះភ្នំពេញ។ ប៉ុល ពត ទៅប្រចាំការនៅភូមិ នៅឯណោះ។

[១០:១៩:៥៧]

**ស៖** ចាតើក្រៅពី ប៉ុល ពត មាននរណាគេទៀត ដែលនៅមន្ទីរប-៥ នុ៎ង?

**ជ៖** តាមខ្ញុំចាំគ្មានពីណាទេ។ មានតែពួកដែលនៅភូមិភាគ គេមករាយការណ៍ជូនគាត់ ហើយមានអ្នកការពារប៉ុន្មាននាក់ទេ ព្រោះត្រូវនៅស្ងាត់ នេះខ្ញុំសូមជម្រាបលោកប្រធាន។ សង្គ្រាមឈ្លបបំណាធូន់មិនបានទេ មានចំនួនច្រើនមិនបានទេ ស្ងាត់ ចល័ត រហ័ស នេះបានធ្វើសង្គ្រាមឈ្លបបាន។ ផ្លាស់កន្លែងឲ្យញឹក បើមិនអ៊ីចឹងទេ ខ្មាំងវ៉ៃខ្ទេចខ្ទីអស់ហើយ។

**ស៖** តើលោកធ្លាប់បានចូលរួមប្រជុំនៅមន្ទីរប-៥ ដែរឬទេ?

**ជ៖** ខ្ញុំដូចមិនដែលបានចូលប្រជុំនៅមន្ទីរប-៥ ទេ គ្រាន់តែពេលទៅជួប ប៉ុល ពត ម្ដងម្កាលឯទៅប្រជុំរួមអីហ្នឹងគេ មិនដែលទៅប្រជុំទេ។

[១០:២១:២៩]

**ស៖** ខៀវ សំផន បានលើកឡើងនៅពេលដែលចៅក្រមស៊ើបអង្កេតសម្ភាសគាត់ សួរចម្លើយគាត់ គាត់លើកឡើងថា "ក្រោយពេលដែលគេរំដោះភ្នំពេញនៅថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ គាត់បានធ្វើដំណើររួមជាមួយនិងលោកពីមន្ទីរ ប៉ុល ពត នៅខាងលិចខដុង្គនោះមកភ្នំពេញ។ ថាតើលោកធ្វើដំណើរដោយរបៀបណាដែរ? តើលោកបានធ្វើដំណើររួមជាមួយនិងលោក ខៀវ សំផន ដែរឬទេ?

**ឆ៖** សូមជម្រាបលោកប្រធាន ខ្ញុំមិនចាំទេ ពីព្រោះពេលនោះសភាពការណ៍វាច្របូកវាច្របល់ដែរ។

**ស៖** ដូច្នេះ វាត្រឹមត្រូវដែរឬទេ លោកមិនចាំថាលោកមកទីក្រុងភ្នំពេញពីមន្ទីរប-៥ នោះទេ? គឺមិនបានធ្វើដំណើរមកពីស្ទឹងជីនិត មកភ្នំពេញនោះទេ? ត្រឹមត្រូវដែរឬទេ លោក នួន ជា?

**ឆ៖** លោក ស្នើលោកប្រធានអាជ្ញាសួរម្តងទៀត។

**ស៖** តើលោកចាំទេ នៅពេលដែលលោកធ្វើដំណើរមកទីក្រុងភ្នំពេញថ្ងៃរំដោះ ១៧ មេសា ១៩៧៥ តើលោកធ្វើដំណើរមកភ្នំពេញនេះ ពីស្ទឹងជីនិត ឬក៏លោកធ្វើដំណើរពី ប-៥ មកភ្នំពេញ?

**ឆ៖** តាមខ្ញុំចាំ ដូចជាមកពីស្ទឹងជីនិត។

[១០:២៣:៣៦]

**ស៖** ចំណុចចុងក្រោយដែលខ្ញុំចង់សុំសួរលោកនៅក្នុងអំឡុងឆ្នាំ៧៤។ ឯកសារមួយដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ គឺឯកសារលេខ D108/43/1 ដែលដាក់នៅចំពោះមុខអង្គជំនុំជម្រះថាឯកសារ E3/117 គឺជាសេចក្តីប្រកាសជាសាធារណៈដែលចុះដោយលោក ខៀវ សំផន នៅថ្ងៃទី២៦ ខែកុម្ភៈ ៧៥ ក្នុងនាមជាប្រធាន ហ្វុង ដែលក្នុងនោះគឺលើកឡើងអំពីជនក្បត់ចំនួនប្រាំពីរ ពីរបប លន់ នល់។ ក្នុងនោះ រួមមាន៖ លន់ នល់ សិរិមតៈ និង ឡុង បូរ៉េត។ វាចាំបាច់ដែលត្រូវសម្លាប់ជនក្បត់ទាំងប្រាំពីរនេះ ដោយសារតែអំពើក្បត់ជាតិ។ លោកបានជម្រាបចៅក្រម ឡាវែន៍ នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១១ ដែលលើកឡើងអំពីមហាជនក្បត់។ តើលោកឯកភាព មានការចូលរួមឯកភាពក្នុងការឲ្យសម្លាប់ជនក្បត់ទាំងប្រាំពីរពីរបបចាស់ដែរឬទេ?

[១០:២៥:០២]

**ឆ៖** សូមជម្រាបលោកប្រធាន ខ្ញុំមិនដឹងផង។ ខ្ញុំឮតាមវិទ្យុទេ ប្រហែលមិនដឹងជាអ្នកណាប្រកាសផង មិនដឹងជា ខៀវ សំផន ឬអ្នកណា ពីព្រោះស្តាប់វិទ្យុ។

**ស៖** តើលោកឯកភាពដែរឬទេថា អ្នកទាំងប្រាំពីរនៅក្នុងសម័យ លន់ នល់ នោះជាជនក្បត់ ដូច្នេះហើយគួរតែសម្លាប់ពួកគេចោល?

**ឆ៖** ខ្ញុំមិនដែល--*(គ្មានការបកប្រែ)*

**លោក ម៉ៃខល ផេសមិន៖**

សូមអភ័យទោសលោកប្រធាន មុនពេលដែលកូនក្ដីរបស់ខ្ញុំឆ្លើយ ខ្ញុំសូមជំទាស់ទៅនឹងសំណួរនេះ។ ប្រសិនបើអនុញ្ញាត ខ្ញុំសូមលើកជំទាស់។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី! ហើយលោកមេធាវីបង្ហាញពីមូលហេតុនៃការជំទាស់របស់លោក។

**លោក ម៉ៃខល ផេសមិន៖**

ខ្ញុំចង់ឲ្យសហព្រះរាជអាជ្ញាសួរឲ្យបានជាក់លាក់ជាងនេះ។ សួរថាកូនក្ដីរបស់ខ្ញុំឯកភាព ឬមិនឯកភាពនោះ វាហាក់ដូចជាស្រពេចស្រពិល កូនក្ដីរបស់ខ្ញុំបានលើកឡើងហើយថាគាត់មិនដឹងនោះទេ សេចក្ដីសម្រេចនោះអាចធ្វើឡើងមុនរយៈកាលហ្នឹង។ ដូច្នេះហើយ គួរតែបង្គាប់ទៅដល់សហព្រះរាជអាជ្ញា ថាតើកូន-- ឲ្យសួរថា តើកូនក្ដីរបស់ខ្ញុំបានដឹងថាមានការសម្រេចដូច្នោះដែរឬទេ? គួរតែសួរអ៊ីចេះវិញ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញសហព្រះរាជអាជ្ញា មានអីបន្ថែមតវ៉ាទៅលើការជំទាស់របស់មេធាវីការពារក្ដី នួន ជា នេះដែរទេ?

[១០:២៧:១៦]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោក នួន ជា គាត់បានលើកឡើងថាៗគាត់ដឹងបញ្ហានេះតាមការផ្សាយវិទ្យុថា ក្នុងនាមជាសមាជិកគណៈអចិន្ត្រៃយ៍មួយរូបនោះ ថាតើ ខ្ញុំចង់សួរគាត់ៗមានបានធ្វើការពិនិត្យ និងដឹងអំពីការសម្រេចទៅលើសម្លាប់ជនក្បត់ទាំងប្រាំពីរនេះដែរឬទេ?

**លោក នួន ជា៖**

**ឆ៖** ខ្ញុំមិនដឹងទេ ទើបដឹងតាមវិទ្យុ។ ពីព្រោះខ្ញុំនៅខាងអប់រំ ដូចខ្ញុំជម្រាបហើយ រឿងនេះរឿងខាងយោធា។

**ស៖** តើលោកអាចជម្រាបយើងខ្ញុំដែរឬទេ ថាតើគណៈអចិន្ត្រៃយ៍ ឬក៏គណៈមជ្ឈិមមានចេញសេចក្តីបង្គាប់ណាមួយសម្រេចទៅមហាជនក្បត់ទាំងប្រាំពីរ នៅក្នុងសម័យ លន់ នល់ នោះដែរឬទេ ដែលសមាជិកក្បត់ទាំងប្រាំពីរនេះគឺជាអ្នករបបសម័យ លន់ នល់?

**ឆ៖** សូមជម្រាបលោកប្រធាន ខ្ញុំមិនដែលដឹងទេ។

**ស៖** ខ្ញុំយល់ត្រឹមត្រូវដែរឬទេដែលថា គណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិមមិនបានប្រកាសជាសាធារណៈឲ្យមានការសម្លាប់មហាជនក្បត់ទាំងប្រាំពីរ ពីសម័យ លន់ នល់ នោះទេ។ តើត្រឹមត្រូវដែរឬទេ?

[១០:២៨:៥៥]

**ឆ៖** ដូចជាខ្ញុំបានជម្រាបលោកប្រធានអ៊ីចឹង ខ្ញុំនេះគ្រាន់តែឮតាមវិទ្យុទេ ឯមហាជនក៏បែបឮតាមវិទ្យុដែរ។ ប៉ុន្តែមិនសូវមានអ្នកណាស្គាល់ទេ អ្នកដែលត្រូវសម្លាប់នោះ។ ប៉ុន្តែដូចជាខ្ញុំចាំ លន់ នល់ រត់បាត់ទៅហើយ។

**ស៖** ខ្ញុំយល់តាមចម្លើយរបស់លោកថា គណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិមមិនបានប្រកាសឲ្យមានការសម្លាប់ជនមហាក្បត់ទាំងប្រាំពីរនោះទេ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ត្រឹមត្រូវ ឬមិនត្រឹមត្រូវ ខ្ញុំមិនដឹងដែរ ដូចជាខ្ញុំបានជម្រាបហើយ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះដល់ពេលសមល្មមនឹងសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយខ្វះដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

សូមអញ្ជើញលោកមេធាវី!

**លោក អាង ឧត្តម៖**

សូមអរគុណលោកប្រធាន ដោយសារមូលហេតុសុខភាព និងដោយសារលោក អៀង សារី មិនអាចអង្គុយបានយូរតទៅទៀត គាត់បានស្នើលោកប្រធានមេត្តាអនុញ្ញាតឲ្យគាត់បោះបង់សិទ្ធិក្នុងការចូលរួមសវនាការផ្ទាល់នៅទីនេះ ដោយសូមចូលរួមសវនាការផ្ទាល់ពីចម្ងាយ នៅបន្ទប់ខាងក្រោមសម្រាប់រយៈពេលមួយថ្ងៃនេះ។ សូមលោកប្រធានមេត្តាអនុញ្ញាត។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ បានស្តាប់សំណើសុំរបស់ អៀង សារី តាមរយៈមេធាវីរបស់គាត់ ដោយសុំលះបង់សិទ្ធិ

ក្នុងការចូលរួមតាមដានកិច្ចសវនាការដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនេះ ដោយដកថយទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមប្រព័ន្ធសោតទស្សន៍។ អង្គជំនុំជម្រះយល់ព្រមតាមសំណើសុំរបស់លោក អៀង សារី ដែលបានស្នើសុំតាមរយៈមេធាវីរបស់គាត់ក្នុងការលះបង់សិទ្ធិសុំចូលរួមកិច្ចសវនាការដោយផ្ទាល់ នៅក្នុងបន្ទប់សវនាការនេះ ដោយទៅបន្តតាមដានកិច្ចសវនាការពីចម្ងាយតាមប្រព័ន្ធសោតទស្សន៍នៅខាងក្រោម ពីបន្ទប់សវនាការនេះ។

តែអង្គជំនុំជម្រះតម្រូវឲ្យមេធាវីការពារក្ដីជនជាប់ចោទ អៀង សារី ប្រគល់មកឲ្យអង្គជំនុំជម្រះភ្លាមៗនូវលិខិតលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ដោយចុះហត្ថលេខា ឬក៏ផ្ដិតម្រាមដៃយ៉ាងជាក់ច្បាស់ពីជនជាប់ចោទ អៀង សារី ផង។

ហើយបង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ និងសំឡេង រូបភាព សម្រាប់ជនជាប់ចោទតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ នៅក្នុងអំឡុងពេលសវនាការសម្រាប់ថ្ងៃនេះ។ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំលោក អៀង សារី ទៅកាន់បន្ទប់ខាងក្រោមនៃបន្ទប់សវនាការនេះ ដែលមានរៀបចំទុកជាស្រេចសម្រាប់ជនជាប់ចោទចូលរួមសវនាការពីចម្ងាយ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១០:៣២ នាទី ដល់ម៉ោង ១០:៥៤ នាទី)*

[១០:៥៣:៥៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ជាបន្ត សូមផ្ដល់វេទិកាទៅសហព្រះរាជអាជ្ញា ដើម្បីបន្តការសួរទៅជនជាប់ចោទ។ សូមអញ្ជើញ!

**លោក សេង ប៊ុនឃាង៖**

សូមអរគុណលោកប្រធាន។

សំណួរដំបូងរបស់ខ្ញុំ គឺពាក់ព័ន្ធទៅនឹងឯកសារលេខ E148 ហើយឯកសារនេះ គឺខ្ញុំបាន--ខ្ញុំចង់ឲ្យជនជាប់ចោទជួយបញ្ជាក់នូវចំណុចមួយចំនួន ហើយនៅក្នុងនេះដែរ ខ្ញុំបានបោះពុម្ពឯកសារនេះជាក្រដាសដើម្បីជូនទៅជនជាប់ចោទក្នុងការពិនិត្យ ហើយខ្ញុំនឹងសួរសំណួរមួយចំនួនដែលពាក់ព័ន្ធ។ ហើយសូមអនុញ្ញាតពីលោកប្រធាន ដើម្បីប្រគល់ឯកសារនេះ ជូនជនជាប់ចោទពិនិត្យមើល ហើយក្នុង

នេះដែរ ខ្ញុំបានព្រីនបោះពុម្ពឯកសារជាក្រដាសA4 ហើយនិងជាក្រដាសA3។ ប្រសិនជាលោកប្រធានអនុញ្ញាតគឺអាចប្រគល់ជាក្រដាសA3 ងាយស្រួលជនជាប់ចោទក្នុងការពិនិត្យមើល។

[១០:៥៥:២៦]

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការយកឯកសារ ទទួលឯកសារពីសហព្រះរាជអាជ្ញាជាតិទៅជូនជនជាប់ចោទពិនិត្យ។

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** លោក នួន ជា តើកំណត់ហេតុនេះ ជាកំណត់ត្រាដែលលោកសរសេរដោយផ្ទាល់ដៃលោកមែនដែរទេ?

**លោក នួន ជា៖**

**ឆ៖** មែន។

**ស៖** ហើយតើលោកធ្វើកំណត់ត្រានេះដោយយ៉ាងណា ដូចជាទាក់ទងនឹងថ្ងៃខែឆ្នាំ? ព្រឹត្តិការណ៍ផ្សេងៗ ដែលមាននៅក្នុងឯកសារ E148 នេះ តើលោកបានប្រើប្រភពព័ត៌មាន ឬក៏ឯកសារផ្សេងៗដើម្បីជួយរំឭកនូវការចងចាំរបស់លោកដែរទេ?

**ឆ៖** ឯកសារនេះ មានកំណត់ហេតុទុកខ្លះដែរ សូមគោរពលោកប្រធាន។

**ស៖** តើលោកឯកសារដែលលោកបានយោងនោះ គឺលោកអាចបញ្ជាក់បានទេថាឯកសារអ្វីខ្លះទៅ?

**ឆ៖** អានេះ ខ្ញុំមិនចាំទេ មើលៗ ខ្ញុំមើលតាមឯកសារបរទេសខ្លះ អីខ្លះ។ សូមគោរពលោកប្រធានអីចឹង។

**ស៖** បាទ អរគុណ។ នៅក្នុងកំណត់ត្រានេះ ឃើញថាមានកន្លែងមួយចំនួនគឺមានការពិបាកអានដូច្នេះ ខ្ញុំសូមឲ្យលោកជួយអានត្រង់ឃ្លាមួយចំនួន ហើយខ្ញុំនឹងសួរបញ្ជាក់នូវចំណុចមួយចំនួនផងដែរ។ ជាដំបូង គឺនៅត្រង់ទំព័រទីមួយ នៅបន្ទាត់ក្រោមគេបង្អស់ហ្នឹង គឺដែលចាប់ផ្ដើមពី១៩៦៤ ដល់៦៥ សូមលោកជួយអានឃ្លាត្រង់នេះបន្តិច?

[១០:៥៧:៣៧]

**ឆ៖** មួយពាន់ប្រាំបួនរយហុកសិប-- គោរពលោកប្រធាន។ ១៩៦៤ ដល់៦៥ ប៉ុល ពត ន៉ែ សុនសេន, អៀង សារី ចេញពីមន្ទីរ១០០ ទៅព្រំដែនខ្មែរវៀតណាមនៅព្លិសាន។

**ស៖** បាទ សូមអរគុណ។ តើលោកអាចជម្រាបជូនអង្គសវនាការបានទេ ថាមន្ទីរ១០០ នុ៎ង គឺជាអ្វីទៅ?

**ឆ៖** មន្ទីរ១០០ ជម្រាបលោកប្រធាន មន្ទីរ១០០ហ្នឹង ជាមន្ទីរមជ្ឈិម។

**ស៖** តើត្រូវចំណាយពេលប៉ុន្មានថ្ងៃ ក្នុងការធ្វើដំណើរពីភ្នំពេញ ទៅដល់មន្ទីរ១០០នេះ?

**ឆ៖** តាមខ្ញុំចាំ វាផ្លូវព្រៃ-- ផ្លូវ-- ជួនណាទៅដើរផង ជួនណាមានឡានផង អីផង ពីរបីថ្ងៃដែរ។

**ស៖** បាទ សូមអរគុណ។ ជាបន្តមកទៀត គឺនៅត្រង់ទំព័រទីពីរ ជាបន្ទាត់លេខប្រាំបី ចាប់ផ្តើមដោយថ្ងៃទី១ មករា ឆ្នាំ១៩៦៨ សូមលោកជួយអានឃ្លានេះ?

**ឆ៖** ទី-- មានតែទីប្រាំ, ទីប្រាំមួយ, ទីបី, ទីប្រាំ, ទីប្រាំបួន, ទីដប់ អីទៀត មិនឃើញមានទេ។

[១១:០០:០៥]

**ស៖** ត្រង់ទំព័រទី២ ដែលមានលេខ ERN00757831 ហើយបន្ទាត់ គឺបន្ទាត់ទី៨។

**ឆ៖** សូមបញ្ជាក់ម្តងទៀត លោកប្រធាន។ ឯណា? បន្ទាត់ទីប៉ុន្មាន?

**ស៖** បន្ទាត់ទី៨ ដែលចាប់ផ្តើមដោយពាក្យថា "ថ្ងៃទី១ មករា ១៩៦៨"។

**ឆ៖** ថ្ងៃទី១ មករា ១៩៦៨ បក្ស ខាងភូមិភាគកណ្តាល ប្រជុំលេខាភូមិភាគ។

**ស៖** បាទ សូមអរគុណ។ តើការប្រជុំភូមិភាគនេះ គឺលោកសំដៅទៅលើអ្វី? ហើយប្រជុំពីអ្វីខ្លះទៅ?

**ឆ៖** ប្រជុំភូមិភាគពេលនោះគឺ-- គោរពលោកប្រធាន គឺតាមខ្ញុំចាំ គឺដោះស្រាយពីរឿងធ្វើទំនប់ទឹក ធ្វើអីៗទាំងអស់ ហើយសំខាន់ដោះស្រាយខាងជីវភាពប្រជាជន ត្រៀមដោះស្រាយជីវភាពប្រជាជន។

[១១:០២:០៩]

**ស៖** តើកិច្ចប្រជុំនេះធ្វើនៅកន្លែងណាដែរ?

**ឆ៖** តាមខ្ញុំចាំ ដូចតាមដងស្ទឹងជីនិត លោកប្រធាន។

**ស៖** នៅក្នុងចំណុចនេះដដែល ឃើញមានពាក្យថា "ភូមិភាគកណ្តាល" តើលោកចង់សំដៅលើអ្វីទៅ ភូមិភាគកណ្តាលនេះ?

**ឆ៖** សូមជម្រាបលោកប្រធាន ភូមិភាគកណ្តាលហ្នឹង កាលនោះ វារួមមាន កំពង់ឆ្នាំង ជាប់ពោធិ៍សាត់អី។

**ស៖** ហើយនៅក្នុងកិច្ចប្រជុំនេះ តើមានអ្នកណាខ្លះចូលរួម?

 

**ឆ៖** តាមខ្ញុំចាំ កាលនោះមានលេខាប៉ុល ពត-- អ្ហឺ!មិនមែន អត់មាន ប៉ុល ពត ទេ។ មានខ្ញុំ មានណ៎ែ! តា ម៉ុក មានណ៎ែ!ប៉ុន្មាននាក់ទៀត ខ្ញុំភ្លេចឈ្មោះហើយ។

**ស៖** តើនៅក្នុងកិច្ចប្រជុំនេះ បានសម្រេចអំពីការតស៊ូអាវុធដែរឬទេពេលនុ៎ង?

**ឆ៖** សូមគោរពលោកប្រធាន។ មានៗសម្រេចអំពីការចាប់ផ្តើមតស៊ូអាវុធ រួមផ្សំនយោបាយ។

[១១:០៤:០៤]

**ស៖** សូមអរគុណ។ ចុះមកបន្ទាត់ទី១៥ ៗដាក់ថា "កញ្ញា ឆ្នាំ១៩៦៩" សូមលោកជួយអាន ចំណុចហ្នឹងបន្តិច?

**ឆ៖** រវាងខែកញ្ញា ១៩៦៩ នួន ជា ទៅរតនគិរី។

**ស៖** សូមលោកជួយជម្រាបជូនអង្គសវនាការថា ចំណុចនេះវាដូចគ្នាទៅនឹងអ្វីដែលលោកបាន ប្រាប់លោក ខឹម ងុន ថាលោកបានទៅប្រជុំជាមួយ ប៉ុល ពត នៅរតនគិរី ដែលលោកបានបញ្ជាក់ថាការ ធ្វើដំណើរនេះ គឺវាចំណាយពេលមួយខែទៅ មួយខែមក។ អ៊ីចឹងតើវាដូចគ្នាអ្វីដែលលើកឡើងនេះទេ?

**ឆ៖** ដូចគ្នា។

**ស៖** ហើយដើម្បីជាប្រតិចារឹក ឯកសារនោះគឺមានលេខ IS20.28 ERN ជាភាសាខ្មែរគឺ 00078199 ជាភាសាអង់គ្លេស 00184671 ហើយនិងជាភាសាបារាំងគឺ 00596193។

**ឆ៖** សូមជម្រាបលោកប្រធាន ទៅប្រហែលជាមួយខែជាង មកមួយខែ ទៅដើរ។

**ស៖** តើកិច្ចប្រជុំនេះគឺប្រជុំពីអ្វី? ហើយបានសម្រេចលើបញ្ហាអ្វីខ្លះដែរទៅពេលនោះ?

**ឆ៖** ពេលហ្នឹងទៅ-- គោរពលោកប្រធាន ពេលហ្នឹងសម្រេច តាមខ្ញុំចាំអំពី-- ខ្ញុំទៅរាយការណ៍ សភាពការណ៍នៅភូមិភាគ ដែលខ្ញុំទទួលខុសត្រូវហ្នឹងឲ្យ ប៉ុល ពត ដឹង។ ហើយទៅពិភាក្សាគ្នាអំពីរឿង ការតស៊ូអាវុធ រួមផ្សំនយោបាយផង។

[១១:០៦:៣៩]

**ស៖** ហើយចុះមកឃ្លា មកបន្ទាត់ក្រោមទៀត គឺបន្ទាត់លេខរៀងទី២៥ ដែលចាប់ផ្តើមដោយថ្ងៃ ១៨ មីនា ១៩៧០។ សូមលោកជួយអានបន្ទាត់៤ ដែលជាប់គ្នាហ្នឹងដែរ?

**ឆ៖** ថ្ងៃទី១៨ មីនា ១៩៧០ កាលនោះរដ្ឋប្រហារសម្តេច សីហនុ ដែល ខ្ញុំសរសេរថា "ដក ដកសីហនុ ហើយ ង្វៀន វ៉ាន់លិញ ហ្នឹង វៀតណាម ហ្នឹងស្នើឲ្យធ្វើតួលេខ-- វៀតណាមហ្នឹងធ្វើតួលេខ ក្លែងក្លាយឲ្យ តាម៉ុក។ ង្វៀន វ៉ាន់លិញ ហ្នឹងឲ្យខ្ញុំហ្នឹងជ្រើសរើសយុវជនកម្ពុជាមួយចំនួន ដើម្បីឲ្យ

កងទ័ពវៀតណាមហ្នឹងគេអប់រំ ហើយវៀតណាមហ្នឹងលួចធ្វើតួលេខក្លែងក្លាយមួយដាក់ឈ្មោះខ្ញុំ ផ្ញើឲ្យតាម៉ុក ឲ្យចាត់តាំងកងទ័ព ឲ្យរកកម្លាំងមួយវរសេនាធំ។ ហើយពេលហ្នឹង ង្វៀន ធីប៊ិញ ហ្នឹងមកខ្ញុំហ្នឹង សោ ភឹម ដើម្បីសុំកន្លែងជ្រកនៅ ដូចខ្ញុំបានជម្រាបហើយ បួនៗបន្ទាត់ហ្នឹង។

**ស៖** បាទ អរគុណ។ ចូលមកទំព័រទី៣ សូមលោកអានត្រង់បន្ទាត់ទី៥ ដែលចាប់ផ្ដើមដោយខែតុលា ១៩៧០ ប៉ុល ពត ប្រមូលប្រជុំ-- សូមលោកជួយអានបន្តបាទ។

**ឆ៖** បន្ទាត់ទី៥ អ្ហែ?

**ស៖** បន្ទាត់ទី៥។

**ឆ៖** បាទៗ។ ប្រាំ ខែតុលា ១៩៧០ ប៉ុល ពត ប្រមូលប្រជុំមជ្ឈិមពេញអង្គ នៅបឹងល្វា ស្រុកសន្ទុក។

**ស៖** ហើយសូមអានផងដែរនៅបន្ទាត់ទី៦ កំពង់ធំនោះបាទ។

**ឆ៖** កំពង់ធំ សម្រេចចាត់តាំងកម្មាភិបាលសំខាន់ៗ ឲ្យទៅតាមភូមិភាគ។ ស្រុកសន្ទុកហ្នឹងកំពង់ធំ។

[១១:០៩:៥៥]

**ស៖** បាទ អរគុណ។ តើនៅពេលនុំង តើលោកបានចូលរួមប្រជុំក្នុងកិច្ចប្រជុំនេះដែរទេ?

**ឆ៖** ខ្ញុំបានជម្រាប លោកប្រធាន ខ្ញុំបានចូលរួមប្រជុំដែរ។

**ស៖** ហើយតើមានមន្ទីររបស់បក្សកុម្មុយនីស្តកម្ពុជាស្ថិតនៅបឹងល្វា ស្រុកសន្ទុកនេះដែរឬទេ?

**ឆ៖** សូមជម្រាបលោកប្រធាន មាន ប៉ុន្តែចល័តឡើង ចល័តចុះមិននៅមួយកន្លែងទេ។

**ស៖** តើលោកចាំទេថានរណាខ្លះមានវត្តមាននៅក្នុងកិច្ចប្រជុំនោះ?

**ឆ៖** សូមជម្រាបលោកប្រធាន តាមខ្ញុំចាំ គឺសុទ្ធតែលេខាបក្សភូមិភាគទាំងអស់ទៅប្រជុំ។

**ស៖** តើកិច្ចប្រជុំនេះបានពិភាក្សាអំពីអ្វីខ្លះ ហើយបានសម្រេចអ្វីខ្លះចំពោះកិច្ចប្រជុំរបស់គណៈមជ្ឈិមហ្នឹង?

**ឆ៖** សភាពការណ៍នេះបើតាម កម្លាត់តមកហ្នឹង គឺថាឆ្នាំ១៩៧០ ជាប់គ្នាហ្នឹង ខែតុលា វិច្ឆិកាហ្នឹងគឺចរចារវាង ប៉ុល ពត ហើយនិង នួន ជា ហើយនិង ង្វៀន វ៉ាន់លិញ អំពីការ-- ហើយនិងតាណាំទ្រុង ដើម្បីសម្រួលសហការ ការប្រយុទ្ធយ៉ាងម៉េចៗ កុំឲ្យមានការទំនាស់គ្នា។

[១១:១១:៣៩]

**ស៖** នៅក្នុងកំណត់ត្រានេះផងដែរ គឺលោកបានបញ្ជាក់ថា កិច្ចប្រជុំនេះគឺសម្រេចចាត់តាំងកម្មាភិបាលសំខាន់ៗនៅតាមភូមិភាគមួយៗ។ តើមូលហេតុអីបានជាត្រូវចាត់តាំងកម្មាភិបាលនៅតាមភូមិភាគនីមួយៗនៅក្នុងកិច្ចប្រជុំនេះ?

**ឆ៖** សូមជម្រាបលោកប្រធាន ពីព្រោះកម្មាភិបាលសំខាន់ៗហ្នឹង គឺដោយច្រើនគណៈមជ្ឈិមចុះទៅកាន់ភូមិភាគ។

**ស៖** តើនៅពេលនោះកម្មាភិបាលណាខ្លះត្រូវបានតែងតាំងទៅកាន់ភូមិភាគនីមួយៗហ្នឹង លោកនៅចាំបានទេ?

**ឆ៖** អ្នកណានៅ-- សូមជម្រាបលោកប្រធាន នរណានៅភូមិភាគណាទៅកាន់ភូមិភាគហ្នឹង។ ដូច តាម៉ុក គាត់ធ្លាប់នៅខាងនិរតី គាត់ទៅកាន់ភូមិភាគនិរតី។ សោ ភឹម នៅភូមិភាគបូព៌ា ទៅកាន់ភូមិភាគបូព៌ា។ ហើយ កុយ ធួន ដូចនៅឯណា នៅឧត្តរទៅកាន់ភូមិភាគឧត្តរ។ ហើយបាទ-- ខ្ញុំចាំប៉ុណ្ណឹង។

[១១:១៣:០០]

**ស៖** បាទ សូមអរគុណ។ សូមលោកជួយជម្រាបជូនអង្គសវនាការអំពីការទទួលខុសត្រូវ និងភារកិច្ចរបស់លេខាភូមិភាគមួយៗហ្នឹងថា តើអ្នកទាំងនោះត្រូវទទួលខុសត្រូវចំពោះការអនុវត្តរបស់មាគ៌ាបក្សនៅតាមកន្លែងមួយៗរបស់គេដែរឬយ៉ាងណា?

**ឆ៖** សូមជម្រាបលោកប្រធាន កម្មាភិបាលមួយៗ ទទួលខុសត្រូវអនុវត្តនូវមាគ៌ានយោបាយរបស់បក្សតាមមហាសន្និបាតរបស់បក្សសម្រេច។

**ស៖** ចំណុចបន្តទៀត សូមលោកអាននូវបន្ទាត់ចុងក្រោយគេ ដែលពេលនោះពីរចុងក្រោយគេ។

**ឆ៖** បាទ ពេលនោះកងទ័ពបដិវត្តន៍កម្ពុជាឡើងដល់ពីរម៉ឺននាក់។ គឺសភាពការណ៍អសន្តិសុខកើតពាសពេញក្នុងភ្នំពេញ គឺ លន់ នល់ កាន់កាប់មិនបាន។

**ស៖** តួលេខដែលកងទ័ពបដិវត្តន៍កម្ពុជាឡើងដល់ពីរម៉ឺននាក់ បើតាមមើលក្នុងកំណត់ត្រានេះដូចជាៗ ពីររយពាន់នាក់។

**ឆ៖** ពីររយពាន់ បាទ។

**ស៖** បាទ សូមអរគុណ។ សូមចូលទំព័រមួយទៀតគឺទំព័រទីបួន។ នៅត្រង់បន្ទាត់ទីបី ដែលដាក់ថា ២៦ ខែមករា ឆ្នាំ១៩៧៤។

[១១:១៥:១៣]

**ឆ៖** បាទ ថ្ងៃ២៦ មករា ឆ្នាំ១៩៧៤ រាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជាប្រកាសតស៊ូតទៅទៀត។

**ស៖** បាទ សូមអរគុណ។ ហើយបន្ទាត់ទីប្រាំផងដែរ គឺខែមេសា ១៩៧៤។

**ឆ៖** ខែមេសា ១៩៧៤ មានបាតុកម្មកងទ័ពបដិវត្តន៍កម្ពុជានៅចម្ងាយ៦០គីឡូម៉ែត្រពីពោធិ៍ចិនតុង។

**ស៖** បាទ សូមអរគុណ។ ហើយតមកទៀត ចុះមកដល់បន្ទាត់ទីប្រាំបួន និងបន្ទាត់ទីដប់។ សូមលោកជួយអានផងដែរ។

**ឆ៖** ចុងខែមីនា ១៩៧៥ បក្សវៀតណាមស្នើជួប ១បក្សកុម្មុយនីស្តកម្ពុជា។

**ស៖** សូមលោកជួយៗអានបន្ទាត់ទីដប់បន្តទៀតបាទ។

**ឆ៖** បន្ទាត់ទីដប់ ប៉ុល ពត ពេលនោះត្រៀមវាយផ្តាច់ភ្នំពេញ ប៉ុល ពតៗ ទៅនៅក្រាំងដូង ហៅប-៥ ឃុំពាម ស្រុកកំពង់ត្រឡាច ហៅនៅភូមិចាន់ទី ទៅប្រចាំការនៅនោះ ដើម្បីស្រួលបញ្ជាការវាយរំដោះភ្នំពេញ។

[១១:១៧:២៤]

**ស៖** បាទ សូមអរគុណ។ សូមត្រឡប់មកបន្ទាត់ទីប្រាំ អម្បាញ់មិញ ដែលបញ្ជាក់ថាមានបាតុកម្មនៅខែមេសា ១៩៧៤។ តើពេលនោះមានហេតុការណ៍អ្វីកើតឡើងខ្លះទៅ? មាន លោកនៅចាំទេ?

**ឆ៖** តាមខ្ញុំចាំ មានបាតុកម្មប្រជាជនគ្រប់កន្លែង ច្រើនកន្លែងណាស់ កាលនោះ។ ពាសពេញពីព្រោះកងទ័ពចូលជិតដល់ភ្នំពេញហើយ។ មានបាតុកម្មនៅទីក្រុងភ្នំពេញ កូនសិស្សធ្វើបាតុកម្មអីៗ។

**ស៖** បាទ សូមអរគុណ។ ជាបន្តទៀត គឺចូលមកទំព័រទី៥។ ទំព័រទី៥ នៅក្នុងកន្លែងដែលបន្ទាត់ពុះកណ្តាល ហើយនៅខាងស្តាំដៃគេ ខាងលើគេហ្នឹង សូមលោកជួយអានពីរបន្ទាត់ហ្នឹង។

**ឆ៖** អំ ពីបន្ទាត់ទីប៉ុន្មាននេះ? បន្ទាត់ពីប៉ុន្មាន ១៥ អេ្ហះ?

**ស៖** បាទៗ បើគិតជាបន្ទាត់នៅខាងបន្ទាត់ពុះកណ្តាល នៅខាងស្តាំដៃ គឺបន្ទាត់ទីមួយ និងទីរពីរ នៅខាងលើគេ ខាងស្តាំ។

**ឆ៖** ពេលនោះ សោ ភឹម សម្លាប់ខ្លួន ខែឧសភា ឆ្នាំ១៩៧៨ ឯ កុយ ធួន ត្រូវចាប់ឆ្នាំ១៩៧៧ ព្រោះកាលនោះមានកើតការបះបោល បាញ់គ្នា នៅភូមិភាគបូព៌ា។ ដូច្នេះ គណៈមជ្ឈិម អំគណៈ

អចិន្ត្រៃយ៍បញ្ជូនកងទ័ពទៅដើម្បីជួយដោះស្រាយ។ សោ ភឹម គាត់រត់ ហើយគាត់រត់ៗទៅ គាត់គេចមិនរួច ក៏សម្លាប់ខ្លួនឯងចោលទៅ។

**ស៖** បាទ អរគុណ។ ចូលមកបន្ទាត់ទី១៥ ដែលជាអក្សរដែលឆ្លងកាត់បន្ទាត់ពុះកណ្តាលនោះ សូមលោកអានពីរបន្ទាត់ហ្នឹង។

**ឆ៖** បាទ។ បញ្ហាសន្និបាត ៗតាមសមមិត្ត ហែម គាត់ឲ្យដឹងគឺថា គាត់ចាំ គឺឆ្នាំ១៩៦០, ៦៣, ៧១, ៧៦ ដើម្បីរៀបចំគណៈអចិន្ត្រៃយ៍ថ្មី ហើយចាត់តាំងឆ្នាំ១៩៧៨ ចាត់តាំងអចិន្ត្រៃយ៍ថ្មី។

**ស៖** បាទ អរគុណ។ ហើយសូមចូលមកទំព័រចុងក្រោយគេ គឺនៅត្រង់ផ្នែកខាងក្រោមគេហ្នឹង គឺបន្ទាត់ទី១៦ ដែលចាប់ផ្តើមដោយ ១៩៤២។

**ឆ៖** បាទ, ១៩៤២ ខ្ញុំទៅរៀននៅថៃ។

**ស៖** ទាក់ទងទៅនឹងការសិក្សានៅប្រទេសថៃរបស់លោកហ្នឹង គឺតើលោកបានរៀននៅផ្នែកច្បាប់នៅសាកលវិទ្យាល័យធម្មសាត្រ មែនទេដែរ? ហើយរៀនទីនោះរយៈពេលប៉ុន្មានឆ្នាំដែរទៅ?

**ឆ៖** មែន។ ខ្ញុំរៀនបីឆ្នាំ ប៉ុន្តែប្រឡងមិនទាន់ជាប់បានអីទេ។ ខ្ញុំចេញមកគស៊ូមក។

[១១:២១:៥៤]

**ស៖** នៅក្នុងថ្នាក់នុំង តើគេបង្រៀនជាភាសាអ្វីដែរ?

**ឆ៖** បង្រៀនជាភាសាអង់គ្លេសផង ជាភាសាថៃផង។

**ស៖** អ៊ីចឹងតើលោកចេះភាសាអង់គ្លេស ឬភាសាថៃហ្នឹងច្បាស់លាស់ទេ?

**ឆ៖** ភាសាអង់គ្លេសខ្ញុំមិនសូវចេះទេ ភ្លេចអស់ទៅហើយ បើភាសាថៃចេះច្បាស់។

**ស៖** អ៊ីចឹងតើលោកអាចប្រើភាសាបរទេស បានប៉ុន្មានភាសាដែរ?

**ឆ៖** សូមជម្រាបលោកប្រធាន ប្រើជានយោបាយ បើភាសានយោបាយ ខ្ញុំប្រើបានភាសាថៃ ភាសាវៀតណាម។

[១១:២២:៤៩]

**ស៖** បាទអរគុណ។ ចំណុចមួយទៀត នៅត្រង់ទំព័រទី-- បន្ទាត់ទី១៨ ដែលចាប់ផ្តើមដោយ ១៩៤៦។

**ឆ៖** ១៩៤៦ ខ្ញុំចូលអង្គការយុវជនប្រជាធិបតេយ្យថៃ ពីព្រោះនៅថៃមានចាត់តាំងអង្គការយុវជនប្រជាធិបតេយ្យ ក្រោមការដឹកនាំរបស់បក្សកុម្មុយនីស្តថៃ។

**សៈ** តើអង្គការយុវជនប្រជាធិបតេយ្យថៃហ្នឹងជាអ្វីទៅ?

**ឆៈ** អង្គការយុវ-- គោរពលោកប្រធាន អង្គការយុវជនថៃហ្នឹងជាអង្គការសម្រាប់ប្រមូលយុវជនដែលចម្រើន មានស្មារតីប្រជាធិបតេយ្យរួបរួមគ្នាដើម្បីពិភាក្សាអំពីបញ្ហានយោបាយខ្លះ អំពីបញ្ហាសភាពការណ៍នៅក្នុងប្រទេសថៃខ្លះ។

[១១:២៣:៥៧]

**សៈ** បាទអរគុណ។ បន្តមកទៀតនៅបន្ទាត់ទី២៤។

**ឆៈ** បាទ ការចែកបក្សកុម្មុយនីស្តឥណ្ឌូចិនជាបីបក្ស ឆ្នាំ១៩៥១ កាលនោះក្នុងឆ្នាំ១៩៥០ នៅជាបក្ស។ ឆ្នាំ១៩៥១ បក្សកុម្មុយនីស្តឥណ្ឌូចិនចែកជាបីបក្ស។ ១) បក្សពលករវៀតណាម ២) បក្សប្រជាជនបដិវត្តន៍កម្ពុជា ៣) បក្សប្រជាជនបដិវត្តន៍ឡាវ។

**សៈ** បាទ អរគុណ។ តើនៅពេលនោះ លោកមានវត្តមាននៅក្នុងពេលបែងចែកនោះដែរទេ?

**ឆៈ** ពេលនោះ សូមជម្រាបលោកប្រធាន ពេលនោះខ្ញុំមានវត្តមានដែរ។

**សៈ** តើនរណាគេជាអ្នកអញ្ជើញលោកឲ្យចូលរួមក្នុងមហាសន្និបាតបែងចែកបក្សនេះ?

**ឆៈ** គឺសមមិត្តដែលគេចូលបក្សមុនៗ គេបបួល គេឃោសនាអប់រំរកសមាជិកបក្ស ឈ្មោះឧត្តម។

**សៈ** តើលោកនៅចាំទេថាតំណាងដែលទៅពីប្រទេសកម្ពុជាហ្នឹងមានប៉ុន្មាននាក់ដែរ?

**ឆៈ** ខ្ញុំមិនចាំទេ ពីព្រោះមិនបានជួបគ្នា ទៅនៅវត្តរៀងខ្លួន កាលនោះទៅនៅថៃ នៅវត្តរៀងខ្លួន។

**សៈ** ចុះនៅពេលដែលលោកបានចូលនៅក្នុងការបែងចែកនោះ តើលោកបានឃើញតំណាងខាងពីកម្ពុជាទៅចូលរួមនៅពេលនោះដែរទេ?

**ឆៈ** ជម្រាបលោកប្រធានមិនឃើញទេ។

**សៈ** បាទ សូមអរគុណ។ ឥឡូវខ្ញុំចូលទៅប្រធានបទមួយទៀត ទាក់ទងនឹងការប្រើឈ្មោះរបស់លោក។ សូមលោកជួយជម្រាបជូនអង្គសវនាការអំពីឈ្មោះផ្សេងៗរបស់លោក ដែលលោកបានប្រើកន្លងមក តើមានឈ្មោះអ្វីខ្លះទៅ?

[១១:២៧:០០]

**ឆៈ** ឈ្មោះដើមកំណើត ដែលកើតក្នុងសំបុត្រកំណើតហ្នឹងឈ្មោះ ឡៅ "សៃឡៅ" គឺមរន

ហើយប្រែមកទៀត ខ្ញុំប្រែឈ្មោះច្រើនណាស់ ឈ្មោះ ផែន ឈ្មោះ ជា ហើយមកក្រោយនេះបានឈ្មោះ នួន ជា។

**ស៖** ឈ្មោះ នួន ជា តើនៅពេលណាដែលលោកប្រើឈ្មោះ នួន ជា ហ្នឹង?

**ឆ៖** ពេលដែលខ្ញុំត្រឡប់មករស់នៅប្រទេសកម្ពុជាវិញហើយ។

**ស៖** ចុះលោកធ្លាប់ប្រើឈ្មោះ ឡុង ប៊ុនរ័ត្ន ឬក៏ ឡុងរ័ត្ន ដែរទេ?

**ឆ៖** មិនដែលទេ។ គេអាចគេសរសេរខុស។

**ស៖** ចុះនៅពេលដែលលោករៀននៅប្រទេសថៃ លោកដែលប្រើឈ្មោះ ឡុងឡឺត ឡៅឌី ដែរទេ?

**ឆ៖** ប្រើ ជម្រាបលោកប្រធាន រុងឡឺត ឡៅឌី ព្រោះថៃគេឲ្យប្រែ ឲ្យខ្មែរទាំងអស់ប្រែឈ្មោះជាថៃ។

**ស៖** បាទសូមអរគុណ។ ទាក់ទងចំណុចមួយទៀតដែរ គឺទាក់ទងនឹងសៀវភៅទង់បដិវត្ត ចាប់ពីខែកញ្ញា ១៩៦០ ដល់ខែមេសា ឆ្នាំ១៩៧៥ តើទង់បដិវត្តបានបោះពុម្ពញឹកញាប់ដែរទេនៅពេលហ្នឹង?

[១១:២៩:០៦]

**ឆ៖** តាមខ្ញុំចាំដូចមួយខែម្តង។

**ស៖** តើទង់បដិវត្តនេះជាទស្សនាវដ្តីសម្ងាត់ ដែលសម្រាប់ចែកឲ្យតែសមាជិកតែប៉ុណ្ណោះ មែនដែរទេ?

**ឆ៖** ចែកឲ្យតែកម្មាភិបាលទេ។

**ស៖** តើមូលហេតុអីបានជាចាត់ទុកទស្សនាវដ្តីនេះជាការសម្ងាត់ទៅវិញ?

**ឆ៖** សូមជម្រាបលោកប្រធាន ពីព្រោះពេលនោះធ្វើការសម្ងាត់។ បើគេឃើញគេចាប់ រដ្ឋបាលឃើញចាប់។

**ស៖** នៅពេលបោះពុម្ពផ្សាយម្តងៗ តើសៀវភៅទង់បដិវត្តនេះ ធ្វើឡើងបានចំនួនប៉ុន្មានច្បាប់ដែរ?

**ឆ៖** តាមខ្ញុំចាំបោះដៃ សរសេរដៃ ទង់បដិវត្តសរសេរបាន ដូចជា ប្អូនដប់ក្បាលប៉ុណ្ណឹងទេ ចែកតាមន័ ចែកតាមភាគ។

**ស៖** បាទ អរគុណ។ ខ្ញុំចូលចំណុចមួយទៀត ទាក់ទងទៅនឹងនីតិវិធី នៃការចូលបក្សកុម្មុយនីស្តកម្ពុជា។ សូមលោកជួយជម្រាបជូនអង្គសវនាការអំពីនីតិវិធី ឬក៏ដំណើរការចំពោះអ្នកដែលត្រូវចូល

បក្ស តើត្រូវធ្វើយ៉ាងណាខ្លះ?

[១១:៣០:៤៩]

**ឆ៖** សូមជម្រាបលោកប្រធាន មុនដំបូង នៅក្នុងអង្គការយុវជនប្រជាធិបតេយ្យថៃ សាកល្បងការងារ ចូលរួមធ្វើបាតុកម្មប្រឆាំងរដ្ឋបាល ប្រឆាំងការចាប់ចងសាស្ត្រាចារ្យ ដែលចម្រើននៅមហាវិទ្យាល័យធម្មសាត្រអីៗហ្នឹង។ រួចទៅគេសាកល្បងទៅ បានគេឃើញសកម្ម ឃើញសកម្មហ្នឹងបានគេបបួលចូលបក្ស ឯចូលបក្សហ្នឹងមិនមានពិធីអីទេ គ្មានគោរពទង់អីទេ ពីព្រោះវាសម្ងាត់។ ហើយត្រៀមចូលបក្សហ្នឹងត្រៀមប្រាំពីរខែ បានពេញសិទ្ធិ។

**ស៖** សំណួរអ៊ីចេះ ខ្ញុំចង់ដឹងថា សមាជិកបក្សដែលត្រូវចូលក្នុងបក្សកុម្មុយនីស្តកម្ពុជា តើមាននីតិវិធី ឬក៏ដំណើរការយ៉ាងម៉េច ចំពោះអ្នកដែលស្នើសុំចូលបក្សហ្នឹង?

**ឆ៖** ចូលបក្សវិជ្ជា? លោកប្រធានចង់សួរយ៉ាងម៉េច?

**ស៖** ចូលបក្សកុម្មុយនីស្តកម្ពុជា។

**ឆ៖** កាលខ្ញុំមក មានវៀតណាមម្នាក់ គេទៅឧទ្ទេសនាម គេថា មិត្តពីដើមនៅបក្សកុម្មុយនីស្តថៃ ឥឡូវមិត្តមកធ្វើការនៅកម្ពុជា មិត្តត្រូវផ្ទេរមកចូលបក្សកុម្មុយនីស្តឥណ្ឌូចិន។ ដូចគ្មានពិធីអីទេ។

**ស៖** ខ្ញុំចង់និយាយជាទូទៅ ចំពោះបក្សកុម្មុយនីស្តកម្ពុជា បើសិនជាមាននរណាម្នាក់ចង់ស្នើចូលបក្ស។ តើគេត្រូវបំពេញនីតិវិធី ឬក៏ដំណើរការយ៉ាងម៉េច? មិនមែនសំដៅទៅលើរូបលោកទេ គឺទៅលើជនទូទៅ ដែលចង់ស្នើសុំចូលបក្សកុម្មុយនីស្តកម្ពុជារបស់លោក។

[១១:៣៣:០១]

**ឆ៖** តាមខ្ញុំដឹង សូមជម្រាបលោកប្រធាន វាមានលក្ខខណ្ឌមួយ មានស្មារតីស្នេហាជាតិ ស្នេហាប្រជាជន មិនពាលាអាវាសែ គោរពអង្គការចាត់តាំង គោរពវិន័យ មានគុណធម៌បដិវត្ត មិនស្រា មិនស្រី មិនខូច មិនខាត គឺថា មិនអបាយមុខ មិនប្រព្រឹត្តអបាយមុខ និយាយឲ្យខ្លីចុះ ហើយសាកល្បងការងារសិន។

**ស៖** អ្នកដែលស្នើសុំចូលបក្សហ្នឹង គឺចាំបាច់ត្រូវតែមានអ្នកឧទ្ទេសនាមឲ្យចូលដែរឬទេ ឬក៏គេអាចចូលផ្ទាល់តែម្តង?

**ឆ៖** តាមខ្ញុំចាំ មានអ្នកឧទ្ទេសនាមបីនាក់ បានគេទទួល។

**ស៖** ហើយចំពោះអ្នកដែលចូលបក្សហ្នឹង តើត្រូវឲ្យគេបញ្ជាក់អំពីការយល់ព្រមរបស់ពួកគេនៅ

ក្នុងការគោរពមាគ៌ារបស់បក្សដែរទេ?

**ឆ៖** ពេល-- តាមខ្ញុំចាំធ្វើសម្បថ គោរពទង់បក្ស សច្ចាចំពោះទង់បក្សថា ប្ដេជ្ញាស្នេហាជាតិ ស្នេហាប្រជាជាន គោរពវិន័យរបស់បក្ស ហើយលះបង់ផលប្រយោជន៍ផ្ទាល់ខ្លួន ដើម្បីផលប្រយោជន៍រួម។ ពេលណាមានទំនាស់ រវាងផលប្រយោជន៍ផ្ទាល់ខ្លួន និងផលប្រយោជន៍រួម ត្រូវគិតផលប្រយោជន៍រួមមុន ហើយសឹមគិតផលប្រយោជន៍ផ្ទាល់ខ្លួនឯង។ នេះតាមខ្ញុំចាំ។

[១១:៣៥:២០]

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងសមាជិកបក្សធម្មតា ដែលចង់ចូលជាសមាជិកគណៈមជ្ឈិម ឬក៏គណៈអចិន្ត្រៃយ៍បាន តើមានលក្ខណៈសម្បត្តិយ៉ាងណាខ្លះទៅ?

**ឆ៖** អានេះ អ្នកដែលចូលជាសមាជិកបក្ស គឺសមាជិកអចិន្ត្រៃយ៍បានទាល់តែមកពីសាខាបក្សភូមិ អំ សាខាបក្សឃុំសិន កសាងខ្លួនតាំងពីក្រោមឡើងមក។ ខំធ្វើការងារ បើល្អបានធ្វើលេខាសាខាបក្សឃុំ ហើយធ្វើការងារគេកាន់តែល្អទៀត ឡើងធ្វើជាគណៈកម្មការឃុំ ស្រុក។ កាលនោះវាមានន៎តំបន់ ចេះតែឡើង បើធ្វើការងារល្អ ហើយឡើងមកភាគ។ ប៉ុន្តែទាល់តែប្រយុទ្ធ មិនគោរព-- មិនៗ--និយាយរួម គឺមិនខូចមិនកាច ដូចខ្ញុំជម្រាបអ៊ីចឹង។ ហើយពុះពារក្នុងការប្រយុទ្ធ។

**ស៖** តើមានករណីលើកលែងណាមួយដែរទេ ឬក៏សមាជិកបក្សទាំងអស់មានសិទ្ធិស្មើគ្នា គ្មានករណីលើកលែងពិសេសណាមួយទេ ដែលអាចចូលជាមជ្ឈិម ឬក៏ជាគណៈអចិន្ត្រៃយ៍បក្សហ្នឹង?

**ឆ៖** សូមជម្រាបលោកប្រធាន។ មានសិទ្ធិ-- ឲ្យតែមានគុណធម៌បដិវត្តន៍។ ខ្ញុំនិយាយមួយម៉ាត់ថា គុណធម៌បដិវត្តន៍ មានសីលធម៌បដិវត្តន៍ ខ្នះខ្នែងក្នុងការងារ គឺចូលបក្សបាន អាចឡើងបាន។ ប៉ុន្តែសំខាន់ គឺធាតុវណ្ណៈ គឺវណ្ណៈ បើវណ្ណៈកសិករក្រ ហើយយល់ដឹងមានសមត្ថភាពវប្បធម៌គ្រាន់បើរហ័ស។ ប៉ុន្តែបើវណ្ណៈផ្សេងៗ ដែលមិនមានសមត្ថភាពខាងវប្បធម៌ ឬក៏មិនសកម្មក្នុងការងារ អាហ្នឹងគឺថាត្រូវត្រៀមយូរបន្តិច។ ត្រៀមមានមួយឆ្នាំ ពីរឆ្នាំ។

[១១:៣៨:០៧]

**ស៖** តាមដែលលោកបញ្ជាក់អម្បាញ់មិញ គឺមានន័យថា គ្មានករណីលើកលែងទេ ទាល់តែត្រូវ-- គឺត្រូវតែបំពេញតាមលក្ខខណ្ឌទាំងអស់នេះ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ជម្រាបលោកប្រធាន។

**ស៖** បាទ សូមអរគុណ។ ខ្ញុំចូលមកចំណុចមួយទៀត ទាក់ទងទៅនឹងរូបលោកមានទំនាក់ទំនង

ជាមួយនឹងលោក ខៀវ សំផន។ សូមលោកជួយបញ្ជាក់ថា តើលោកជួប ខៀវ សំផន ដំបូងគេបង្អស់ ហ្នឹងនៅពេលណាដែរ?

[១១:៣៨:៤២]

**ផ៖** ខ្ញុំ-- សូមជម្រាបលោកប្រធាន។ ខ្ញុំដូចជួបគាត់នៅក្នុងព្រៃ។

**ស៖** ទីតាំងហ្នឹងឈ្មោះអ្វីដែរ? លោកចាំទេ?

**ផ៖** តាមខ្ញុំចាំដូចជា ជិតភ្នំឱរ៉ាល់។

**ស៖** ហើយលោកជួបនៅក្នុងឆ្នាំណាដែរ?

**ផ៖** កាលនោះ ខ្ញុំមិនចាំឆ្នាំទេ ខ្ញុំភ្លេចឆ្នាំហើយ។

**ស៖** លោកភ្លេចឆ្នាំ តើលោកចាំព្រឹត្តិការណ៍អីមួយដែរទេនៅពេលនុ៎ង?

**ផ៖** ខ្ញុំដែលមិនដែលស្គាល់គាត់ទេ។ ប៉ុន្តែឮគេថា ហ្នឹង ខៀវ សំផន ហើយហ្នឹង ហើយមិនសូវទាក់ទងគ្នា ព្រោះគាត់ខាងបញ្ញាជន។ ខាងបញ្ញាជន គេផ្សេង។ ខាងសាខាបញ្ញាជនហ្នឹងមាន ប៉ុល ពត គាត់ទទួលខុសត្រូវ។ ឯខាងខ្ញុំណោះផ្សេង ខាងបក្ខជនធម្មតា ជាប្រជាជនធម្មតា ជាកសិករ ជាអីៗ។

[១១:៤០:១០]

**ស៖** បាទ អរគុណ។ តើលោក ខៀវ សំផន ធ្លាប់បានចូលរួមប្រជុំរបស់គណៈមជ្ឈិមណាខ្លះជាមួយលោកដែរទេ ចាប់ពីឆ្នាំ១៩៧១ ដល់ខែមេសា ឆ្នាំ១៩៧៥?

**ផ៖** ខ្ញុំមិនចាំដែរ ដូចជាមិនដែលចូលរួមប្រជុំទេ គាត់ប្រជុំផ្សេងគ្នា។ ខ្ញុំប្រជុំផ្សេង។

**ស៖** អ៊ីចឹង មានន័យថា លោកមិនដែលបានប្រជុំជាមួយលោក ខៀវ សំផន ទាល់តែសោះ ក្នុងអំឡុងពេលនេះ អ៊ីចឹងមែនទេ?

**ផ៖** មែន។

**ស៖** បាទសូមអរគុណ។ ឥឡូវខ្ញុំចូលចំណុចមួយទៀត ទាក់ទងទៅនឹងឯកសារលេខ IS20.32។ ឯកសារនេះ គឺជាបទសម្ភាសន៍របស់ នួសារ៉ា ថៃថារ៉ាត់ ថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០០១ ដែលលោកបានសម្ភាសជាមួយលោក។

**លោក សេង ប៊ុនឃាង៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតប្រគល់ឯកសារនេះ ជូនជនជាប់ចោទដើម្បីពិនិត្យមើល បាទ។

[១១:៤១:៤៧]

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការទទួលឯកសារពីតំណាងសហព្រះរាជអាជ្ញាជាតិ យកទៅជូនជនជាប់ចោទ នួន ជា ពិនិត្យ។

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** តើលោកនៅចាំទេ បទសម្ភាសន៍ របស់លោកជាមួយនឹងលោក នូសារ៉ា ថៃថាវ៉ាត់ នេះ?

**លោក នួន ជា៖**

**ឆ៖** ខ្ញុំសូមជម្រាបលោកប្រធាន ខ្ញុំមិនដែលស្គាល់ផង។ ខ្ញុំមិនដែលស្គាល់ទេ។

**ស៖** បើយើងនៅពិនិត្យនៅលើឯកសារនេះ គឺនៅទំព័រដំបូងហ្នឹង ឃើញមានបញ្ជាក់ថា ការធ្វើសម្ភាសនេះគឺមានការចូលរួមផងដែលរបស់លោក ណាវ៉ាវ៉ាត់ សុខសំរាន ដែលជាអ្នកនិពន្ធព័ត៌មានប្រចាំខេត្តនៃកាសែតបាងកកប៉ុស្ដិ៍ ។ វរសេនីយ៍ទោ ស៊្វីរាពង្ស អានុគល់ អនុប្រធានការិយាល័យនៃការិយាល័យសម្របសម្រួលព្រំដែនកម្ពុជាថៃ ព្រមទាំងក្នុងនោះ ក៏មានសរសេរអំពីភរិយារបស់លោក ក៏មានវត្តមានក្នុងនោះដែរ តើលោកនៅចាំទេ?

**ឆ៖** សូមជម្រាបលោកប្រធាន ខ្ញុំមិនចាំទេ។

**ស៖** បាទ សូមអរគុណ។

[១១:៤៣:២៩]

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន តើសូមអាចលេខយោងជាភាសាអង់គ្លេសបានទេ លោកព្រះរាជអាជ្ញា? ឬក៏អាចបង្ហាញនៅលើអេក្រង់ ដើម្បីខ្ញុំមើលផង។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ សូមអរគុណ។ សូមបង្ហាញលេខ ERN ជាភាសា ទាំងបីភាសា ហើយនិងបង្ហាញឯកសារនេះ នៅលើកញ្ចក់អេក្រង់ទូរទស្សន៍។

**លោក សេង ប៊ុនឃាង៖**

លោកប្រធាន តំណាងសហព្រះរាជអាជ្ញាសំណួរអ្វីទាក់ទងទៅនឹងចំណុចស៊ីជម្រៅរបស់ឯកសារនេះទេ គ្រាន់តែចង់បង្ហាញថា ឯកសារនេះគឺមានលេខ IS20.32។

**ប្រធានអង្គជំនុំ៖**

អ៊ីចឹងអញ្ជើញបន្តសំណួរថ្មីទៀតទៅ បើមិនមានការប៉ុនប៉ងក្នុងការសំណួរអ្វីផ្សេងទៀត ពាក់ព័ន្ធជាមួយនឹង IS20.32 នេះទេ។

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកប្រធាន ហើយឯកសារមួយនេះដែរ គឺមួយទៀតដែរ គឺឯកសារលេខ IS20.34 សូមអនុញ្ញាតលោកប្រធាន ដើម្បីប្រគល់ឯកសារនេះជូនលោក នួន ជា ដើម្បីពិនិត្យមើល។

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការទទួលឯកសារពីតំណាងសហព្រះរាជអាជ្ញាជាតិ ដើម្បីជូនទៅលោក នួន ជា ដើម្បីពិនិត្យ។

*(មន្ត្រីតុលាការយកឯកសារឲ្យជនជាប់ចោទ)*

[១១:៤៥:១១]

**ប្រធានអង្គជំនុំ៖**

ដូចគ្នាលោកសហព្រះរាជអាជ្ញា សូមបង្ហាញនូវអត្តសញ្ញាណឯកសារឲ្យច្បាស់លាស់ ហើយបើអាចធ្វើបាន គឺបង្ហាញនៅលើកញ្ចក់អេក្រង់ទូរទស្សន៍ដើម្បីឲ្យភាគីដទៃទៀត និងអង្គជំនុំជម្រះបានពិនិត្យមើលឯកសារដែលលោកប៉ុនប៉ងក្នុងការសួរនាំទៅជនជាប់ចោទនេះផង។

**លោក សេង ប៊ុនឃាង៖**

បាទ អរគុណលោកប្រធាន។ សហការីរបស់ខ្ញុំនឹងដាក់បញ្ចាំងនៅបន្តិចទៀតនេះ ហើយឯកសារនោះគឺមានលេខ IS20.34។

**ប្រធានអង្គជំនុំ៖**

ចុចៗក្បាលមេក្រូ សឹមនិយាយណ៎ា!

**លោក នួន ជា៖**

សូមជម្រាបលោកប្រធាន ទាល់តែពិនិត្យយូរបានដឹង។

**សួរដោយលោក សេង ប៊ុនឃាង៖**

បាទ ខ្ញុំដូចឮលោក នួន ជា និយាយថា ពិនិត្យយូរបានដឹង ថាតើលោកស្គាល់ឯកសារនេះមែនទេ?

**លោក នួន ជា៖**

ខ្ញុំមិនចាំទេ។

**លោក សេង ប៊ុនឃាង៖**

ឯកសារដែលបង្ហាញនេះ គឺជាបទសម្ភាសន៍រវាងលោកជាមួយនឹងលោក អៀ ម៉េងទ្រី និង សុភ័ក្ត្រ លឿង នៅត្រង់ទំព័រទី១០ ទៅ១៨ ជាភាសាខ្មែរ ហើយERN ជាភាសាខ្មែរ គឺ00347040 ដល់ 00347048 ហើយ ERN ជាភាសាអង់គ្លេស គឺ00000931 ដល់00000935។

**ប្រធានអង្គជំនុំ៖**

មេធាវីអន្តរជាតិការពារក្ដី ខៀវ សំផន!

[១១:៤៨:៣៧]

**លោក អាកទួរ វែកតែន៖**

បាទ សូមអរគុណលោកប្រធាន។ សូមអភ័យទោសលោក នួន ជា ខ្ញុំសូមធ្វើការជំទាស់មួយយ៉ាងហោចណាស់ក៏ចង់ផ្ដល់ដំណឹងជូនដល់អង្គជំនុំជម្រះថា ខ្លួនខ្ញុំផ្ទាល់ហ្នឹង គឺថាសហព្រះរាជអាជ្ញាកំពុងតែចោទសំណួរទៅជនជាប់ចោទទៅលើឯកសារដែលខ្ញុំពុំមាននោះទេ។ អ៊ីចឹងខ្ញុំសូមសួរថា តើព្រោះថានេះជាបញ្ហា ជាការចោទសួរដែលយើងត្រូវត្រៀមទុកពីយូរហើយ ហើយអ៊ីចឹងសូមឲ្យសហព្រះរាជអាជ្ញាហ្នឹងផ្ដល់ឯកសារមកឲ្យយើងមុន ដែលដកចេញពីសំណុំរឿង ដែលខ្លួនចង់ប្រើប្រាស់ក្នុងការជំនុំជម្រះនេះ ក្នុងការសួរចម្លើយនេះ ព្រោះថាអានេះវាអាចឲ្យយើង ព្រោះថាដឹងថាខ្លួនមិនមានម៉ាស៊ីនហ្វូតូកូពីនៅក្នុងការិយាល័យរបស់គាត់នោះទេ គឺយើងអាចធ្វើហ្វូតូកូពី ខាងយើងនេះបាន ដើម្បីឲ្យអាចពិភាក្សាគ្នាបាន។ ឥឡូវនេះ គឺថាយើងសហព្រះរាជអាជ្ញាប្រើឯកសារមួយ ហើយខ្ញុំពុំមានឯកសារនោះទេនៅលើអេក្រង់ ហើយក្រដាសនោះ ក៏អត់មានដែរ។ អ៊ីចឹងប្រហែលជាថា គឺថាគ្រាន់តែយើងសួរចម្លើយអ៊ីចេះដែលថាត្រៀមទុកជាហើយហ្នឹង គួរតែផ្ដល់ដំណឹងមកឲ្យយើងមុនទាក់ទងនឹងឯកសារដែលខ្លួនចង់ប្រើនោះ។

**ប្រធានអង្គជំនុំ៖**

លោកតំណាងសហព្រះរាជអាជ្ញាជាតិ មានឯកសារជាភាសាអង់គ្លេស-- ជាភាសាបារាំងទេ។

**លោក សេង ប៊ុនឃាង៖**

បាទ អរគុណលោកប្រធាន។ ឯកសារ IS20.34 ជាភាសាបារាំងគឺ 00613200 ដល់

00613212។

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** លោក នួន ជា តើលោកធ្លាប់បានធ្វើសម្ភាសជាមួយអ្នកទាំងពីរនាក់នេះដែរឬទេ?

**លោក នួន ជា៖**

**ឆ៖** អត់ទោសលោកប្រធាន សម្ភាសជាមួយអ្នកណា?

**ស៖** សម្ភាសជាមួយលោក អៀ ម៉េងទ្រី និង សុភ័ក្ត្រ លឿង។

**ឆ៖** ខ្ញុំមិនស្គាល់ផង។ មិនដឹងជាអ្នកនោះឈ្មោះអី មិនដឹងជាឲ្យសម្ភាសអ្នកណា ព្រោះអ្នកដែលគេទៅលេងផ្ទះខ្ញុំនោះ គេទៅលេង គេមិនដែលប្រាប់ថាគេទៅធ្វើអីៗផង។ រួចខ្ញុំក៏និយាយ គេសួរអីក៏និយាយលេងអីចឹងទៅ។

**ស៖** បាទ សូមអរគុណ។ ចំណុចមួយទៀត គឺទាក់ទងទៅនឹងសៀវភៅរបស់លោក ខៀវ សំផន ដែលមានចំណងជើងថា "ពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជាពីដើមរហូតដល់សម័យកម្ពុជាប្រជាធិបតេយ្យ" ថានៅខែកញ្ញា ឆ្នាំ១៩៥១ គឺលោកត្រូវបានគេចាត់តាំងជាសមាជិកនៃគណៈកម្មាធិការមជ្ឈិមនៃបក្សប្រជាជនបដិវត្តន៍កម្ពុជា។ ហើយដើម្បីជាប្រតិចារឹក ឯកសារនោះគឺមានលេខ D213.2 ERN ជាភាសាខ្មែរគឺ 00380357 ហើយជាភាសាអង់គ្លេសគឺ 00498226 ជាភាសាបារាំងគឺ 0064 3824។ តើជាការត្រឹមត្រូវទេដែលរូបលោកដែលត្រូវបានតែងតាំងជាសមាជិកនៃគណៈមជ្ឈិមរបស់បក្សប្រជាជនបដិវត្តន៍កម្ពុជានៅក្នុងឆ្នាំ១៩៥១ នោះ?

[១១:៥៣:០៤]

**ឆ៖** ខ្ញុំមិនដែលឃើញសៀវភៅហ្នឹងសរសេរផង ប៉ុន្តែឆ្នាំ១៩៥១ ខ្ញុំមិនទាន់បានចាត់តាំងជាមជ្ឈិមអីទេ ព្រោះខ្ញុំនៅជាបក្ខជនធម្មតា។ ខ្ញុំទៅធ្វើការឃោសនាអប់រំទេ។ ខ្ញុំមិនទាន់ចូល ខ្ញុំមិនមែនថ្នាក់មជ្ឈិម ថ្នាក់អីទេ។ កាលនោះ១៩៥១ នៅតស៊ូជាមួយបារាំងនៅឡើយ មិនទាន់មានចាត់តាំងមជ្ឈិមអីទេ។

**ស៖** អ៊ីចឹងថាតើនៅពេលនោះលោកមានតួនាទីអ្វីខ្លះទៀតទៅនៅក្នុងបក្សកុម្មុយនីស្ត-- បក្សប្រជាជនបដិវត្តន៍កម្ពុជា ចាប់ពីឆ្នាំ១៩៥១ ដល់ឆ្នាំ១៩៥៥?

**ឆ៖** កាលនោះ ខ្ញុំធ្វើការងារឃោសនាអប់រំ។ សរសេរកាសែត កាលនោះគេហៅកាសែតឥស្សរៈ ហើយដើរអប់រំកម្មាភិបាលតាមភូមិឃុំអីខ្លះតែប៉ុណ្ណឹង។

[១១:៥៤:១៧]

**ស៖** បាទ អរគុណ។ ចំណុចមួយទៀត ទាក់ទងទៅនឹងសុន្ទរកថាកាលពីខែកញ្ញា ឆ្នាំ១៩៧៧ របស់លោក ប៉ុល ពត គឺគាត់បានលើកឡើងថា "នៅឆ្នាំ១៩៥៧ យើងបានចាត់តាំងគណៈកម្មាធិការមួយ ដើម្បីរៀបចំនូវនយោបាយ មាគ៌ានយោបាយរបស់បក្ស គណៈកម្មាធិការនេះប្រមូលមានសមាជិកជា កម្មាភិបាលទទួលខុសត្រូវ ធ្វើការនៅជនបទខ្លះ និងកម្មាភិបាលទទួលខុសត្រូវធ្វើការនៅក្រុងភ្នំពេញខ្លះ" ហើយឯកសារហ្នឹង គឺមានលេខ D243/2.1.12 ERN ជាភាសាខ្មែរ គឺ00063133 ហើយជាភាសា អង់គ្លេស 00486225 ជាភាសាបារាំង 004922810។

**ឆ៖** សូមជម្រាបលោកប្រធាន ខ្ញុំមិនដែលឃើញសុន្ទរកថាហ្នឹងផង។

**ស៖** លោកបានជម្រាបជូនអង្គសវនាការរួចហើយ ពាក់ព័ន្ធទៅនឹងការងាររបស់លោកជាមួយ ប៉ុល ពត ក្នុងការរៀបចំមាគ៌ារបស់បក្ស។ សំណួរសួរថា តើមានអ្នកណាខ្លះទៀត ដែលបានចូលរួម រៀបចំពង្រាងអំពីមាគ៌ានយោបាយរបស់បក្សហ្នឹង ដាក់ជូនមហាសន្និបាតលើកទីមួយរបស់បក្ស តើពេល នោះមានអ្នកណាផ្សេងទៀត ដូចជា អៀង សារី មានដែរទេ ពេលនុ៎ង?

**ឆ៖** តាមខ្ញុំចាំកាលនោះមានលោកតា ទូ សាមុត ទីប្រឹក្សា។ ខ្ញុំទទួលមើលតែខាង យល់សភាព ការណ៍នៅជនបទ។ អៀង សារី យល់-- ន៎ែ ប៉ុល ពត គាត់យល់សភាពការណ៍នៅទីក្រុង។ កាលនោះ ដូចគ្មាន អៀង សារី ទេ មានតែបីនាក់ទេ ប៉ុណ្ណឹង។ តា ទូ សាមុត, ប៉ុល ពត ហើយនិងខ្ញុំ។

[១១:៥៦:៥១]

**ស៖** នៅមុនពេលមហាសន្និបាតបក្សលើកទីមួយ ឆ្នាំ១៩៦០ តើលោកបានធ្វើដំណើរទៅ តៃនិញ ដើម្បីពន្យល់ដល់បក្សវៀតណាម អំពីមាគ៌ានយោបាយ ដែលរូបលោក ហើយនិង ប៉ុល ពត រៀបចំនេះ ដែរទេ?

**ឆ៖** ខ្ញុំចាំ ក៏ប៉ុន្តែ មិនដឹងជាខែណា ឆ្នាំណាទេ ប៉ុន្តែមានទៅ។ ទៅពន្យល់អំពីមាគ៌ានយោបាយ យុត្តិសាស្ត្រ យុត្តិវិធី ប៉ុន្តែបក្សវៀតណាម គេមិនពេញចិត្តទេ។ ពីព្រោះមិនបានពិភាក្សាជាមួយគេ។

**ស៖** នៅពេលដែលបក្សវៀតណាមមិនពេញចិត្តហើយ លោកនៅតែយកមាគ៌ាផែនការរបស់ លោកហ្នឹងទៅដាក់អនុម័តនៅក្នុងមហាសន្និបាតបក្សលើកទីមួយអ៊ីចឹងដែរឬទេ?

**ឆ៖** ខ្ញុំនៅធ្វើអ៊ីចឹង ពីព្រោះខ្ញុំប្រាប់ថា បក្សយើង បក្សកម្ពុជាឯករាជ្យ អធិបតេយ្យភាព បូរណភាពរបស់ខ្លួន។ ខ្លួនទីពឹងខ្លួន ខ្លួនម្ចាស់ការឯករាជ្យចំពោះវាសនារបស់ខ្លួន។ ឯបក្សវៀតណាម គេ

ធ្វើ គេពេញចិត្ត ឬមិនពេញចិត្ត អាហ្នឹងស្រេចនឹងគេ។

[១១:៥៨:៣៨]

**ស៖** តើពេលនោះ បក្សវៀតណាមហ្នឹង គេមិនពេញចិត្តត្រង់ចំណុចណាមួយដែរជាសំខាន់?

**ឆ៖** តាមខ្ញុំចាំ ចង់រួមផ្សំការតស៊ូនយោបាយនិងអាវុធ។ ហើយគ្មាននិយាយអំពីសហព័ន្ធឥណ្ឌូចិន។ គេចង់ឲ្យនិយាយអំពីសហព័ន្ធឥណ្ឌូចិន។ សាមគ្គីខ្មែរ វៀតណាម លាវ។ ក៏ប៉ុន្តែក្នុងបក្សប្រជាជនបដិវត្តន៍កម្ពុជាដែលធ្វើហ្នឹង គឺគ្មាននិយាយទេ។

**ស៖** បាទ សូមអរគុណ។ តើនៅពេលនោះមានអ្នកណាខ្លះធ្វើដំណើរជាមួយលោកទៅពន្យល់បក្សវៀតណាមនៅពេលនោះដែរ?

**ឆ៖** ពេលនោះមានខ្ញុំម្នាក់ឯង។

**ស៖** បាទ សូមអរគុណ ដោយសារពេលវេលានៅពេលនេះអស់ហើយ ខ្ញុំសូមបញ្ចប់សំណួរខ្ញុំសង្ខេបត្រឹមនេះសិន ហើយសូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ សហព្រះរាជអាជ្ញាជាតិ។ បាទឥឡូវនេះដល់ពេលសមល្មមនឹងសម្រាកដើម្បីពិសាថ្ងៃត្រង់ហើយ ៗមុននឹងសម្រាកក៏អង្គជំនុំជម្រះសូមជម្រាបថា ពេលវេលាសម្រាប់លើការសួរ តាំងសំណួររបស់សហព្រះរាជអាជ្ញាចំពោះជនជាប់ចោទ នួន ជា អំពីបរិបទប្រវត្តិសាស្ត្រកម្ពុជាអស់ហើយ។ ហើយជាបន្តទៅទៀតនៅពេលខាងមុខនឹងដល់បន្តបន្ទាប់គឺដល់ពេលភាគីដទៃទៀត ដែលមានឱកាសក្នុងការតាំងសំណួរចំពោះជនជាប់ចោទ នួន ជា។

សូមអញ្ជើញ លោកមេធាវី!

**លោក ម៉ៃខល ផេសមិន៖**

កូនក្ដីរបស់ខ្ញុំសូមធ្វើសំណើឲ្យបញ្ជូនគាត់ទៅបន្ទប់រង់ចាំខាងក្រោម នៅក្នុងពេលរសៀលនៃសវនាការថ្ងៃនេះ។ ខ្ញុំដឹងហើយថា តាម-- ខ្ញុំយល់ថាតាមអ្វីដែលយើងដឹង គឺយើងបន្តស្ដាប់ចម្លើយសាក្សីដែលធ្វើកាលពីសប្ដាហ៍មុន។

[១២:០១:១៧]

**ប្រធានអង្គជំនុំ៖**

បានស្ដាប់សំណើសុំរបស់លោក នួន ជា តាមរយៈមេធាវីរបស់គាត់ ស្នើសុំទៅតាមដានកិច្ច

ដំណើរការសវនាការពីចម្ងាយ តាមប្រព័ន្ធសោតទស្សន៍នៅបន្ទប់ខាងក្រោម អង្គជំនុំជម្រះយល់ព្រម តាមសំណើរបស់ នួន ជា ដែលបានស្នើសុំតាមរយៈមេធាវីរបស់គាត់ ដោយលះបង់សិទ្ធិក្នុងការចូលរួម កិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ទៅបន្តកិច្ចដំណើរការ-- តាមដានកិច្ច ដំណើរការសវនាការពីចម្ងាយ ពីបន្ទប់នៅខាងបន្ទប់សវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍។ តែអង្គជំនុំជម្រះតម្រូវឲ្យមេធាវីការពារក្ដី នួន ជា ប្រគល់មកឲ្យអង្គជំនុំជម្រនូវលិខិតលះបង់សិទ្ធិ ចូលរួមសវនាការដោយផ្ទាល់នៅក្នុងបន្ទប់សវនាការ ដោយចុះហត្ថលេខា ឬស្នាមមេដៃយ៉ាងជាក់ច្បាស់ ពីជនជាប់ចោទ នួន ជា។ ហើយនិងបង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សំឡេង និង រូបភាព សម្រាប់ជនជាប់ចោទតាមដានកិច្ចដំណើរការសវនាការពីចម្ងាយនៅក្នុងអំឡុងពេលធ្វើសវនាការ នៅរសៀលនេះ។

[១២:០២:២២]

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទ នួន ជា ព្រមទាំងលោក ខៀវ សំផន ផង ទៅកាន់បន្ទប់សម្រាកខាងក្រោម ហើយដោយឡែករសៀលនេះបង្គាប់ឲ្យនាំខ្លួនលោក ខៀវ សំផន មកកាន់បន្ទប់សវនាការ។ ដោយឡែកលោក នួន ជា ទុកគាត់នៅបន្ទប់រង់-- បន្ទប់ខាងក្រោមដែលមាន ប្រព័ន្ធសោតទស្សន៍ ដើម្បីឲ្យគាត់តាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។

សូមសម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១២:០២នាទី ដល់ម៉ោង ១៣:៣១នាទី)*

[១៣:៣១:៣១]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

នៅរសៀលនេះ អង្គជំនុំជម្រះបន្តស្ដាប់សក្ខីកម្មសាក្សី ប្រាក់ យុត ដែលនឹងបន្តការសួរដេញ ដោលដោយក្រុមមេធាវីការពារក្ដីទាំងបីក្រុម។

លោក ផារី តើមានវត្តមានសាក្សីរូបនេះដែរឬទេនាពេលនេះ?

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន។ សាក្សី ប្រាក់ យុត មានវត្តមាន គាត់នៅក្នុងបន្ទប់រង់ចាំ រង់ចាំការ

កោះហៅពីអង្គជំនុំជម្រះ ដើម្បីចូលសាលសវនាការ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណលោក ផារី។

មន្ត្រីច្បាប់ សូមអញ្ជើញលោកស្រី ប្រាក់ យុត ចូលមកកាន់សាលសវនាការ។

សូមអញ្ជើញ!

[១៣:៣២:៥៦]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន យើងខ្ញុំស្នើសុំរយៈពេល១៥នាទីបន្ថែមទៀត នៅថ្ងៃនេះ ហើយយើងជឿថាការពីប្រជុំរៀបចំសវនាការកាលពីថ្ងៃចន្ទនោះ គឺថាគេប្រគល់ពេលវេលា ឲ្យយើងសម្រាប់១៥នាទី បន្ថែមទៀតដើម្បីសួរសាក្សីនេះលោកប្រធាន។

*(សាក្សីចូលមកក្នុងបន្ទប់សវនាការ)*

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាតតាមសំណើសុំរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងការបន្តពេលវេលា១៥នាទី ក្នុងការសួរទៅកាន់សាក្សីរូបនេះ ប៉ុន្តែមុននឹងប្រគល់វេទិកា អង្គជំនុំជម្រះសូមរំឭកដល់ក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីទទួលសិទ្ធិថា នៅក្នុងអំឡុងពេលនៃការសួរដេញដោល នៅក្នុងនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង នៅក្នុងសំណុំរឿង ០០២ នេះមិនអនុញ្ញាតឲ្យក្រុមមេធាវី យកសេចក្តីថ្លែងការណ៍របស់សាក្សីមួយផ្សេងណា ឬច្រើនផ្សេងទៀតមកដកស្រង់ ដើម្បីសួរដេញដោលសាក្សីដែលនៅចំពោះមុខអង្គជំនុំជម្រះឡើយ។ ហើយសូមចងចាំឲ្យច្បាស់ ពីព្រោះថាអង្គជំនុំជម្រះបានសម្រេចបញ្ហានេះរួចហើយ មិនគប្បីយកបញ្ហាដដែលនេះឲ្យកើតឡើងមានម្តងហើយម្តងទៀតនោះទេ។

សូមអញ្ជើញ!

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយកញ្ញា ហ្សីលីពីន ស៊ុតហ្ស៍៖**

សូមអរគុណលោកប្រធាន ហើយសូមអរគុណផងដែរលោកប្រធាន ដែលផ្តល់រយៈពេល១៥នាទីបន្ថែមទៀតដល់ក្រុមយើងខ្ញុំ។ សូមគោរពលោក លោកស្រីចៅក្រម សូមគោរពភាគីទាំងអស់ សូមគោរព

លោកស្រី ប្រាក់ យុត។

**ស៖** ខ្ញុំនឹងបន្តការសួរសំណួរលោកស្រីបន្តទៅទៀត។ ជាដំបូង ខ្ញុំនឹងចាប់ផ្តើមពីសំណួរមួយចំនួនដែលមានលក្ខណៈទូទៅ ដើម្បីឲ្យលោកស្រីយល់អំពីមូលហេតុ ដែលលោកស្រីនៅមានវត្តមាននៅទីនេះ។ តើលោកស្រីបានយល់ច្បាស់ទេ ថាលោកស្រីមានវត្តមាននៅទីនេះក្នុងឋានៈជាសាក្សី មិនមែន មិនមែនមកទីនេះ ដើម្បីឲ្យគេផ្តន្ទាទោសលោកស្រីនោះទ?

**លោកស្រី ប្រាក់ យុត៖**

**ឆ៖** ខ្ញុំយល់ច្បាស់។ មកកន្លែងនេះ គឺខ្ញុំជាសាក្សី មិនមែនមកកន្លែងផ្តន្ទាទោសទេ។

**ស៖** ដូច្នេះគឺថា លោកស្រីបានយល់ច្បាស់ណាស់ថា សំណួររបស់យើងនេះគឺដើម្បីបង្ហាញនូវការពិតនៃអង្គហេតុ ហើយអ្វីដែលលោកស្រីបានដឹង ហើយវាមានទំនាក់ទំនងទៅនឹងឧក្រិដ្ឋកម្ម ដែល នួន ជា, អៀង សារី, ខៀវ សំផន ត្រូវបានជាប់ចោទពីឧក្រិដ្ឋកម្មទាំងអស់នេះ។

**ឆ៖** ខ្ញុំអត់យល់។

**ស៖** តើខ្ញុំត្រូវនិយាយសំណួរម្តងទៀត ឬក៏យ៉ាងណាលោកស្រី?

**កញ្ញា ហ្វីលីពីន ស៊ុតហ្សំ៖**

តើខ្ញុំត្រូវសួរសំណួរនេះដដែលឡើងវិញទៀត ឬក៏យ៉ាងណា ពីព្រោះថា ខាងយើងខ្ញុំមិនទាន់បានទទួលចម្លើយនេះជាភាសាបារាំងនៅឡើយទេលោកប្រធាន?

**ប្រធានអង្គជំនុំ៖**

លោកស្រីសួរសំណួរសាជាថ្មីម្តងទៀត ហើយលោកមេធាវី គប្បីគិតគូរពិចារណាផងដែរសាក្សីនៅចំពោះមុខ លោកស្រីដែលកំពុងសួរនេះ កម្រិតវប្បធម៌ការយល់ដឹងរបស់គាត់មានកម្រិតទាប។ដូច្នេះ ការសួរសំណួរដែលសាមញ្ញ ហើយខ្លី ដើម្បីឲ្យគាត់ងាយស្តាប់នូវសំណួរបាន ហើយក៏បានឆ្លើយទាន់ដែរ។ បើពុំដូច្នោះទេ លោកស្រីអាចចំណាយពេលវេលាសុំ១៥នាទីនេះ ប្រហែលជាមិនប្រើប្រាស់អាចប្រើប្រាស់មានប្រសិទ្ធភាពនោះឡើយ នូវរយៈពេលដែលបានផ្តល់ឲ្យបន្ថែមនេះ។

[១៣:៣៨:២៥]

**កញ្ញា ហ្វីលីពីន ស៊ុតហ្សំ៖**

សូមអរគុណលោកប្រធាន។

**សួរដោយកញ្ញា ហ្វីលីពីន ស៊ុតហ្ស៍៖**

**ស៖** លោកស្រី ខ្ញុំបានសួរអម្បាញ់មិញនេះថា គឺលោកស្រីដឹងទេថា សំណួរដែលយើងសួរទាំងអស់នេះ មានគោលដៅក្នុងការលាតត្រដាងនូវការពិត ទៅលើអង្គហេតុដែលលោកស្រីបានដឹង ដោយខ្លួនឯងផ្ទាល់ ហើយដែលវាមានទំនាក់ទំនងជាមួយនឹងឧក្រិដ្ឋកម្ម ដែលបានចោទប្រកាន់ទៅលើ នួន ជា, ខៀវ សំផន និង អៀង សារី?

**លោកស្រី ប្រាក់ យុត៖**

**ឆ៖** សំណួរខ្ញុំឆ្លើយចំពោះលោកស្រី ខ្ញុំមិនយល់បញ្ហាដែរ។ ខ្ញុំសូមមានមតិប៉ុណ្ណឹង។

**ស៖** ដូច្នេះ ខ្ញុំនឹងសួរសំណួរមួយទៀត តើលោកស្រីដឹងទេថា នៅពេលដែលលោកស្រីឆ្លើយនោះគឺថាលោកស្រីត្រូវតែឆ្លើយនូវការពិត ហើយលោកស្រីគឺថាមិននឹងទទួលរងនូវការកាត់ទោសពីតុលាការនេះទេ។

**ឆ៖** និយាយរួម គឺខ្ញុំអត់បានដឹងដែរ។ លោក នួន ជា, អៀង សារី, ខៀវ សំផន មានទោសឧក្រិដ្ឋនោះ ខ្ញុំអត់យល់ដែរ។ ខ្ញុំអត់ដឹង។ និយាយឲ្យច្បាស់ គឺខ្ញុំអត់ដឹង។ ហើយខ្ញុំមិនខ្លាចកាត់ទោស នៅក្នុងអង្គសវនាការនេះទេ តែការពិតខ្ញុំមិនដឹងថា លោក ខៀវ សំផន, នួន ជា ហើយនិង លោក អៀង សារី នេះជាទោសឧក្រិដ្ឋ ឬយ៉ាងម៉េច ខ្ញុំអត់ច្បាស់លាស់ខ្លួនឯងដែរ។ សូមអស់។

[១៣:៤០:១៣]

**ស៖** សូមអរគុណ។ ដូច្នេះខ្ញុំនឹងបន្តការសួរសំណួរតទៅទៀតទៅលើអង្គហេតុ កាលពីថ្ងៃព្រហស្បតិ៍នោះគឺបានបញ្ឈប់នៅពេលដែលខ្ញុំបានសួរទៅនឹងសំណួរមួយចំនួន ពាក់ព័ន្ធទៅនឹងតួនាទីនៅឆ្នាំ៧៧ និង៧៨ ពេលដែលលោកស្រីស្រុកកំពង់សៀម។ ដូច្នេះ ខ្ញុំត្រឡប់មកនិយាយអំពីបញ្ហានេះឡើងវិញ ដើម្បីបំភ្លឺអំពីដំណើរការរបស់ខ្ញុំក្នុងការសួរសំណួរនេះ ហើយនិងកុំឲ្យមានការជំទាស់ពីខាងមេធាវីការពារក្ដីផងដែរ គឺគោលដៅរបស់យើង គឺថាធ្វើយ៉ាងណាដើម្បីកំណត់អំពីរចនាសម្ព័ន្ធដែលមានស្រាប់នៅថ្នាក់ភូមិភាគ និងកម្រិតផ្សេងៗនៅតាមភូមិភាគ ហើយនិងដើម្បីកំណត់អំពីរចនាសម្ព័ន្ធនៃអំណាចដែលមានស្រាប់ ហើយនិងអំណាចនៃការសម្រេចសេចក្ដី។

[១៣:៤១:០៧]

ខ្ញុំនឹងយោងទៅលើមន្ទីរសន្តិសុខ ហើយនិងមន្ទីរ-- និងទីកន្លែងសម្លាប់មនុស្សមួយចំនួនដែលស្ថិតនៅតំបន់នោះ។ ហើយចំណុចទាំងអស់នេះ គឺវាមិនស្ថិតនៅក្នុងក្របខ័ណ្ឌ ឬក៏ដែនកំណត់ទូទៅនៃ

ដំណាក់កាលសំណុំរឿង០០២នេះទេ ហើយក៏មិនមាននៅក្នុងដីកាដំណោះស្រាយដែរ។ គឺយើងខ្ញុំគ្រាន់តែចង់បង្កើតនូវអង្គហេតុដែលបានប្រព្រឹត្តទៅ ហើយនិងកំណត់នូវរចនាសម្ព័ន្ធនៃការធ្វើសេចក្ដីសម្រេចនៅសម័យនោះ និងជាពិសេសគឺរចនាសម្ព័ន្ធនៃអំណាចនៅថ្នាក់ផ្សេងៗគ្នានៅភូមិភាគ។

លោកស្រី ប្រាក់ យុត លោកស្រីបានបញ្ជាក់កាលពីសប្ដាហ៍មុនថា លោកស្រីជាលេខាស្រុកកំពង់សៀម ហើយនិងជាសមាជិកទីបួននៃស្រុក៤១ នៅក្នុងចន្លោះឆ្នាំ៧៧ ហើយនិងចន្លោះឆ្នាំ៧៨។ តើលោកស្រីអាចបញ្ជាក់ថា តើលោកស្រីមានទំនួលខុសត្រូវអីផ្សេងទៀតទេនៅសម័យនោះ នៅថ្នាក់ស្រុក និងថ្នាក់ភូមិភាគ?

**ឆ៖** ខ្ញុំសូមឆ្លើយតបសំណួរ អត់ច្បាស់ ខ្ញុំសូមឲ្យលោកស្រីសួរម្ដងទៀត និយាយឲ្យច្បាស់ពីបញ្ហាហ្នឹង ខ្ញុំវាអត់យល់។ ពីថ្នាក់ស្រុក និងភូមិភាគចង់និយាយពីអី ខ្ញុំវាអត់ច្បាស់លាស់ដែរ។ សូមសួរម្ដងទៀត។

**ស៖** ខ្ញុំនឹងសួរសំណួរជាលក្ខណៈត្រង់តែម្ដង។ លោកស្រីបាននិយាយប្រាប់យើងខ្ញុំថា លោកស្រីជាលេខាស្រុកកំពង់សៀម ហើយនិងជាសមាជិកទីបួននៃតំបន់៤១។ តើលោកស្រីជាលេខាផ្ទេរសិទ្ធិនៃគណៈស្រុក៤១ នេះដែរឬទេ?

[១៣:៤៣:០០]

**ឆ៖** ខ្ញុំជាសមាជិកទីបួនរបស់គណៈតំបន់៤១ ហើយឋានៈខ្ញុំគឺលេខាស្រុកកំពង់សៀម។

**ស៖** តើលោកស្រីមិនមែនជាលេខា ដែលទទួលសិទ្ធិនៅគណៈតំបន់៤១ ទេឬ?

**ឆ៖** ខ្ញុំអត់មានសិទ្ធិគណៈតំបន់ទទួលនៅក្នុង៤១ គឺខ្ញុំមានភារកិច្ចគឺចែកគ្នានៅតាមស្រុក។ ខ្ញុំនៅស្រុកកំពង់សៀម។

**ស៖** សូមអរគុណ។ តើលោកស្រីមានទំនួលខុសត្រូវនៅក្នុងគណៈនៃតំបន់-- នៃភូមិភាគមជ្ឈិមដែរទេ? តើលោកស្រីជាសមាជិកនៃភូមិភាគកណ្ដាលដែរឬទេ?

**ឆ៖** ខ្ញុំអត់បានជាប់គណៈភូមិភាគកណ្ដាលទេ។ ខ្ញុំនៅតំបន់៤១។ គណៈតំបន់ ភូមិភាគ អាហ្នឹងខ្ញុំអត់បានចូលរួមទេ គឺខ្ញុំ នែ៎ សមាជិកតំបន់ ហើយនៅក្នុងស្រុកកំពង់សៀម។

**ស៖** លោកស្រីបានបញ្ជាក់ថា បានចូលរួមនៅក្នុងកិច្ចប្រជុំមួយចំនួននៅថ្នាក់ភូមិភាគកណ្ដាល។ តើលោកស្រីដឹងទេថា តើអ្នកណាខ្លះជាសមាជិកនៃគណៈភូមិភាគកណ្ដាលនោះ?

**ឆ៖** ខ្ញុំបានចូលរួមប្រជុំក្នុងគណៈភូមិភាគកណ្ដាល ជំនាន់នោះ គឺមានឈ្មោះ តែឥឡូវនេះគឺក៏វា

ភ្លេចដែរ មិនដឹងឈ្មោះអីខ្លះ តែចាំមានពីរបីនាក់ហ្នឹង ដូច តាចន ឈ្មោះអីខ្លះ? ចាំតែបីនាក់ ក្រៅពីហ្នឹងខ្ញុំអត់បានចាំដែរ។ គាត់ស្លាប់អស់ហើយ។

[១៣:៤៥:០៦]

**ស៖** តើ តាអាន ជាសមាជិកនៃគណៈភូមិភាគកណ្ដាលដែរឬទេ?

**ឆ៖** កាលនោះ គឺមិនដឹងជាគាត់ជាប់គណៈភូមិភាគ ឬក៏អត់ ខ្ញុំក៏អត់បានសាកសួរគាត់ដែរ ព្រោះក្នុងគណៈតំបន់៤១ ខ្ញុំដឹងតែក្នុងគណៈតំបន់៤១។ តែចំពោះ តាអាន ហ្នឹង មិនដឹងជាគាត់ជាប់ភូមិភាគ ឬអត់ ខ្ញុំអត់ដែលបានពិភាក្សាជាមួយគាត់បញ្ហាហ្នឹង។

**ស៖** សូមអរគុណ។ កាលពីថ្ងៃព្រហស្បតិ៍មុននេះ ពេលនឹងទៅឆ្លើយសហព្រះរាជអាជ្ញាលោកស្រីបានបញ្ជាក់ថា មានមន្ទីរមួយនៅស្រុកកំពង់សៀម។ នៅចន្លោះមន្ទីរស្រុក ហើយនិងភ្នំប្រុស តើលោកស្រីអាចបញ្ជាក់ពីឈ្មោះនៃមន្ទីរសន្តិសុខនេះបានដែរឬទេ?

**ឆ៖** មន្ទីរសុន្តិសុខនៅចន្លោះហ្នឹង គឺមានខ្ញុំទទួលដែរ មិនមានអ្នកណាក្រៅពីខ្ញុំ គឺការអប់រំប្រជាជន ឬក៏អប់រំមនុស្សដែលនៅក្នុងស្រុកមានការខិលខូចអីអ៊ីចឹង ហ្នឹងអប់រំបញ្ហាហ្នឹង។ តែកន្លែងអប់រំនេះ គឺនៅក្នុងចន្លោះភ្នំស្រីភ្នំប្រុស តែក្នុងហ្នឹង ខ្ញុំទទួលខុសត្រូវ។

[១៣:៤៦:៤៨]

**ស៖** តើលោកស្រីអាចផ្ដល់ឈ្មោះពិតប្រាកដនៃមន្ទីរសន្តិសុខនេះបានដែរឬទេ អំពីមន្ទីរដែលលោកស្រីនិយាយនេះ?

**ឆ៖** អត់មានឈ្មោះណា-- អត់មានអ្នកទទួលខុសត្រូវផង កាលហ្នឹងខ្ញុំអត់ទាន់រៀបរយ ទើប--

**ស៖** តើជាវត្តអង្គញជី មែនទេលោកស្រី?

**ឆ៖** ចាស ជាវត្តអង្គញជី មន្ទីរស្រុកខ្ញុំហ្នឹង។

**ស៖** អ៊ីចឹង តើមន្ទីរសន្តិសុខនេះ ស្ថិតនៅក្នុងវត្តអង្គញជីនេះដែរឬទេ?

**ឆ៖** មន្ទីរសន្តិសុខ គឺនៅស្ថិតក្នុងវត្តអង្គញជី។

**ស៖** សូមអរគុណ។ កាលពីថ្ងៃព្រហស្បតិ៍មុន លោកស្រីក៏បានបញ្ជាក់ផងដែរ ខ្ញុំអានប្រតិចារឹកគឺក្នុង-- គឺថាមន្ទីរសន្តិសុខនេះ គឺមិនស្ថិតនៅក្នុងតំបន់ ឬក៏ភូមិភាគណាទេ ហើយគឺថាខ្ញុំ គឺជាអ្នកអប់រំមនុស្សនៅតំបន់នោះ។ តើលោកស្រីពន្យល់ឲ្យបានច្បាស់ជាងហ្នឹងបន្តិចទេ ថាតើលោកស្រីជាអ្នកទទួលខុសត្រូវនៅមន្ទីរសន្តិសុខនោះ មែន ឬក៏មិនមែន?

**ធ៖** ចាស ជាខ្ញុំអ្នកទទួលសុខត្រូវនៅក្នុងមន្ទីរអប់រំហ្នឹង។

**ស៖** អរគុណ។ អ៊ីចឹងមានន័យថា គឺលោកស្រីជាអ្នកសម្រេចក្នុងការបញ្ជូនមនុស្សទៅកាន់តំបន់ហ្នឹង ដោយខ្លួនឯងផ្ទាល់? ឬមួយក៏លោកស្រីទទួលបញ្ជាពីថ្នាក់លើ ដើម្បីបញ្ជូនមនុស្សទៅកាន់មន្ទីរសន្តិសុខនោះ?

[១៣:៤៨:៥៥]

**ធ៖** ហ្នឹង មនុស្សនៅក្នុងស្រុកហ្នឹង ខ្ញុំមិនអាចយកមកពីណាទេ គឺថានៅក្នុងស្រុក។ មានការខិលខូច ឬក៏យើងអប់រំមិនបានអ៊ីចឹងទៅ យើងយកមកអប់រំនៅកន្លែងមន្ទីរស្រុក។ ហេតុនេះ ខ្ញុំមិនមានការសម្រេចមកពីខាងណាទេ ព្រោះខ្ញុំអប់រំខ្លួនឯង ការខុសត្រូវអីគឺខ្ញុំអប់រំនៅកន្លែងហ្នឹង។

**ស៖** គឺលោកស្រីជាអ្នកសម្រេចផ្ទាល់តែម្តង គឺថាលោកស្រីមិនបានទទួលបញ្ជាពីខាងណាទេមែនទេ?

**ធ៖** ខ្ញុំសម្រេច តែការអប់រំហ្នឹង បើមិនស្តាប់ ខ្ញុំក៏បញ្ជូនឲ្យខាងតំបន់អីជួយអប់រំ មិនយកទៅណាទេ។ បើខ្ញុំអប់រំមិនបាន។ នេះ ខ្ញុំសូមជម្រាប។

[១៣:៥០:០០]

**ស៖** សូមអរគុណ។ តើនៅក្នុងស្រុកកំពង់សៀម មានកន្លែងសម្លាប់មនុស្សដែរឬទេ?

**ធ៖** ចាស! នៅក្នុងស្រុកកំពង់សៀម អត់មានកន្លែងសម្លាប់មនុស្សទេ។

**ស៖** តើលោកស្រីធ្លាប់ឮឈ្មោះភ្នំប្រុសភ្នំស្រីដែរឬទេ?

**ធ៖** ចាស! ខ្ញុំនៅជិតហ្នឹងដែរ ប៉ុន្តែឮ ឃើញភ្នំស្រីភ្នំប្រុស ប៉ុន្តែការកាប់សម្លាប់មនុស្សអី ខ្ញុំមិនបានដឹងដែរ ព្រោះខ្ញុំមិនបានទៅកន្លែងហ្នឹងញឹកញាប់អី ខ្ញុំនៅកន្លែងមន្ទីរស្រុក។ ខ្ញុំធ្វើការនៅក្នុងស្រុកខ្ញុំៗក៏មិនបានដឹងឮពីបញ្ហាសម្លាប់មនុស្សនៅកន្លែងភ្នំស្រីភ្នំប្រុស ខ្ញុំអត់ឮទេអាហ្នឹង និយាយដោយរឿងពិតមិនមែនចេះតែកុហកនៅក្នុងអង្គប្រជុំទេ ខ្ញុំសូមជម្រាប។

[១៣:៥១:០៩]

**កញ្ញា ហ្វីលីពីន ស៊ុតហ្ស៖**

លោកប្រធានពាក់ព័ន្ធនឹងចំណុចនេះ គឺខ្ញុំសូមយោងទៅលើសេចក្តីសង្ខេបនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលនិយាយយោងទៅដល់ សំដៅទៅដល់កន្លែងនេះ ហើយនិងដែលនិយាយពីឈ្មោះលោកស្រី ប្រាក់ យុត ដែរ។

ជាថ្មីម្តងទៀត គឺសំណើនេះ គឺថាដើម្បីបង្ហាញនូវរចនាសម្ព័ន្ធដែលមានស្រាប់នៅថ្នាក់ស្រុកនេះ លោកប្រធាន។ ហើយនិងរចនាសម្ព័ន្ធបញ្ជានិងខ្សែចង្វាក់បញ្ជាការ ហើយនិងអ្នកណាជាអ្នកទទួលខុសត្រូវក្នុងការធ្វើសេចក្តីសម្រេច។

**ប្រធានអង្គជំនុំ៖**

លោកស្រីចង់ធ្វើដូចម្តេចទៅ? ដូចជាស្តាប់ហើយអត់យល់ទេ ថាបំណងរបស់លោកស្រីចង់បានដូចម្តេច។ ឥឡូវនេះ ប្រាក់ យុត គាត់មកចំពោះមុខអង្គជំនុំជម្រះក្នុងនាមសាក្សី។ ហើយទីពីរ ពេលវេលាដែលសុំ១៥នាទី ដូចជាអាចលើសហើយ។

ដាក់បញ្ហានេះចុងក្រោយ ឥឡូវសួរម៉េច ចង់និយាយថាម៉េច ឥឡូវនេះបញ្ហាអំមិញដែលចង់លើកឡើងនេះ ចង់ឲ្យតុលាការហ្នឹង អង្គជំនុំជម្រះហ្នឹងធ្វើយ៉ាងម៉េច?

**កញ្ញា ហ្គីលីពីន ស៊ុតហ្ស៍៖**

លោកប្រធាន គឺថាខ្ញុំចង់យោងទៅលើសេចក្តីសង្ខេបនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំអានសេចក្តីសង្ខេបនេះជូនលោកស្រី ប្រាក់ យុត ពីព្រោះថាក្នុងឯកសារនោះ គឺយោងមាននិយាយឈ្មោះភ្នំប្រុស ភ្នំស្រី ហើយក៏មានលើកឈ្មោះលោកស្រី ប្រាក់ យុត នៅក្នុងឯកសារនោះផងដែរ។

[១៣:៥៣:០០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៥៥:១២]

**ប្រធានអង្គជំនុំ៖**

មេធាវីចង់បង្ហាញអំមិញហ្នឹង តើពាក្យតាំងខ្លួនដើមបណ្តឹងរដ្ឋប្បវេណីរបស់បុគ្គលណាគេ ដែលចង់ដកស្រង់យកមកបង្ហាញសាក្សីរូបនេះ ដើម្បីឲ្យគាត់ឆ្លើយ ឬក៏ធ្វើការអត្ថាធិប្បាយនេះ?

**កញ្ញា ហ្គីលីពីន ស៊ុតហ្ស៍៖**

លោកប្រធាន តើខ្ញុំត្រូវផ្តល់លេខឯកសារដែរឬទេ ដើម្បីរក្សានូវអានាមិកភាពនៃជនរងគ្រោះ។ គឺឯកសារលេខ D22/1264 ហើយនិង D22/3358។

**ប្រធានអង្គជំនុំ៖**

ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីហ្នឹងមិនមែនជារបស់ឈ្មោះ ប្រាក់ យុត នេះពិតមែនដែរទេ?

**កញ្ញា ហ្វីលីពីន ស៊ុតហ្ស៍៖**

គឺឯកសារនេះមិនមែនជាឯកសាររបស់លោកស្រី ប្រាក់ យុត ទេឯកសារហ្នឹងគឺមានលើកឈ្មោះ អ្នកស្រី ប្រាក់ យុត។

[១៣:៥៦:៤៣]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:០០:៣៧]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម។ អង្គជំនុំជម្រះប្រគល់ភារៈបញ្ហានេះជាមួយនឹងមេធាវីតំណាង មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីឲ្យច្បាស់។ សូមអញ្ជើញ!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំ-- អង្គជំនុំជម្រះសូមបញ្ជាក់ថា ខ្ញុំចង់បានឱកាសដើម្បីពិចារណា ដើម្បីថាអនុញ្ញាតឲ្យមេធាវីយកចម្លើយរបស់សាក្សី របស់ជនជាប់ចោទ អ៊ំ! ជនរងគ្រោះមកសួរសាក្សី រូបនេះ ហើយយើងចង់ពិនិត្យមើលបញ្ហានេះគឺថា ហើយប្រសិនបើយើងពិចារណាថាមានភាពចាំបាច់ យើងនឹងសម្រេចបែបនោះ។ ដូច្នេះសូមឲ្យលោកស្រីមេធាវីបន្តសំណួរទៅមុខទៀត។ អ៊ីចឹងគឺថាយើង អាចនឹងសុំឈប់ប្រាំនាទី។

**កញ្ញា ហ្វីលីពីន ស៊ុតហ្ស៍៖**

គឺខ្ញុំអស់សំណួរទៅហើយ គឺថានៅសល់តែសំណួរហ្នឹងទេ ដែលពាក់ព័ន្ធទៅនឹងពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណីនោះ។

[១៤:០២:១០]

**លោក អាកឡូរ វែកកែន៖**

លោកប្រធាន ក្នុងករណីដែលអង្គជំនុំជម្រះឆ្លើយឯកភាពទៅនឹងសំណើរបស់មេធាវីដើមបណ្តឹង រដ្ឋប្បវេណី គឺថាគឺអាចបញ្ជាក់ សុំឲ្យបញ្ជាក់ឯកសារលេខERN ហើយនិងបញ្ជាក់ជាភាសាបារាំងផង ដែរ លោកប្រធាន ប្រសិនបើពេលដែលអង្គជំនុំជម្រះអនុញ្ញាតនោះ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះដូចជាស្តាប់ពីរបីលើកហើយដែលលោកមេធាវីអន្តរជាតិការពារក្តីឲ្យលោក ខៀវ

សំផន លើកឡើងបញ្ហានេះ។ ហើយឯកសារទាំងអស់នេះ តាមកម្មវិធីហ្សាយឡេប ដែលយើងប្រើប្រាស់នៅក្នុងអង្គជំនុំជម្រះសាលាដំបូងនេះ នៅចំពោះមុខ អ.វ.ត.ក នេះ លោកអាចមើលឃើញ ដោយវាយលេខឯកសារ ដែលបានបង្ហាញដោយភាគីផ្សេងទៀត នៅក្នុងកម្មវិធី ហើយរកវាជាភាសាដែលខ្លួនប្រើប្រាស់។ យើងគិតថាដូចជាកន្លងមកមិនដែលមានបញ្ហាអីទេ ភាគីដទៃទៀត លើកលែងតែលោកម្នាក់គត់ ដែលលោកមានបញ្ហាដូច្នេះ។

[១៤:០៣:៣៣]

**លោក អាកទួរ វែកគែន៖**

បាទលោកប្រធាន គឺខ្ញុំគឺជាម្នាក់គត់ដែលលើកឡើងដើម្បីបញ្ហានេះ ព្រោះខ្ញុំបានរក ERN ជាភាសាបារាំងហើយ ប៉ុន្តែឯកសារនេះមិនត្រូវបានបកប្រែជាអង់គ្លេស ឬជាបារាំងទេ។ គឺដូច្នេះ គឺខ្ញុំចង់ផ្តល់លទ្ធភាពឲ្យ ថាកុំឲ្យដើមបណ្តឹងរដ្ឋប្បវេណីហ្នឹង គាត់ធ្វើ និយាយទៅដើម្បីបោកបញ្ឆោតខ្ញុំ។ លោកប្រធាន តើឲ្យខ្ញុំឆ្លើយតបពីបញ្ហាហ្នឹងទេលោកប្រធាន?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញប្រគល់វេទិកាទៅលោកមេធាវីការពារក្តី អៀង សារី ជាមុនសិន ព្រោះគាត់លើកដៃមុន ដើម្បីឲ្យចៀសវាងការឆ្លើយឆ្លងគ្នាម្តងម្នាក់ៗហ្នឹង មួយរសៀលនេះមិនចប់បញ្ហាទេ។

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន សូមជម្រាបសួរលោក លោកស្រីចៅក្រម ហើយនិងសមាជិកទាំងអស់។ មានសេចក្តីសម្រេចទាក់ទងទៅនឹងសំណើរួចហើយ ៗខ្ញុំចង់ដឹងចំណុចមួយចំនួន ទីមួយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី គឺមិនបានស្នើនូវការដាក់ភស្តុតាង គឺថាតើសំណួរហ្នឹងវាទាក់ទៅនឹងអ្វីដែលសាក្សីត្រូវផ្តល់សក្ខីកម្មដែរឬទេ? បើមិនមានមូលដ្ឋានអីជ្រៅទេ គឺថាគោលបំណងតែមួយគត់នោះគឺចង់ឲ្យសាក្សីហ្នឹងគាត់ឆ្លើយដាក់បន្ទុកខ្លួនឯងតែប៉ុណ្ណោះ ដោយខ្ញុំសូមបញ្ជាក់ប្រាប់តុលាការថាការតាំងសំណួរនោះ គឺថាសុំតុលាការផ្តល់ការអនុញ្ញាតតាមសំណើដែលថា សាក្សីគប្បីតែទទួលដំណឹងថា គាត់មានសិទ្ធិនៅស្ងៀមមិនឆ្លើយតប ទាក់ទងទៅនឹងសិទ្ធិក្នុងការមិនឆ្លើយដាក់បន្ទុកលើខ្លួនឯង។ នេះហើយជាចំណុចដ៏សំខាន់បំផុត ជាពិសេសដោយហេតុថា ប្រហែលជាយើងពិនិត្យឃើញថា អាចដូចជាការឲ្យសាក្សីឆ្លើយដាក់ទៅថា ពីរឿងបទឧក្រិដ្ឋអ្វីមួយដែលគាត់បានធ្វើ។ សូមអរគុណលោក លោកស្រីចៅក្រម ហើយខ្ញុំសូមជំទាស់សំណួរនេះ ដោយហេតុថា វាហួសពីសមត្ថកិច្ចដែលថាសាក្សីនេះ អាច

ឆ្លើយបាន។ ប្រសិនបើទាក់ទងទៅនឹងទំនាក់ទំនងនៃរបាយការណ៍ ឬខ្សែបញ្ជាហ្នឹងគឺថា អាចសួរតែសំណួរទាក់ទងទៅនឹងអ្វីដែលគាត់ដឹងតែប៉ុណ្ណោះបានហើយ។ បាទ សូមអរគុណតុលាការ។

[១៤:០៥:៥៨]

**ប្រធានអង្គជំនុំ៖**

អរគុណ សូមអញ្ជើញមេធាវី!

**កញ្ញា ហ្វីលីពីន ស៊ុតហ្ស៍៖**

សូមអរគុណលោកប្រធាន។

**សួរដោយកញ្ញា ហ្វីលីពីន ស៊ុតហ្ស៍៖**

**ស៖** គោលបំណងរបស់យើងខ្ញុំនេះ គឺថាមិនមែនដើម្បីធ្វើឲ្យសក្ខីកម្មប្រឆាំងនឹងខ្លួនឯងទេ គឺគ្រាន់តែចង់ឲ្យសាក្សីបង្ហាញការពិត ហើយនិងបង្ហាញថាតើមានខ្សែចង្វាក់បញ្ជាការដែរឬទេ? ហើយប្រសិនបើលោកស្រីគាត់ទទួលបញ្ជាក្នុងការបញ្ជូនមនុស្សទៅកាន់កន្លែងសម្លាប់មនុស្ស។ ដូច្នេះ គឺថាយើងត្រូវតែ-- យើងមិនមែនបង្ហាញពីពិរុទ្ធភាពរបស់គាត់ របស់សាក្សីនេះទេ គឺថា ដើម្បីយោងថា តើមានថ្នាក់លើជាអ្នកបញ្ជា ឬក៏អត់?

**ឆ៖** ខ្ញុំសូមបញ្ជាក់លោកស្រី បានសួរសំណួរខ្ញុំថា តើនៅកន្លែងស្រុកកំពង់សៀម មានកន្លែងសម្លាប់មនុស្សនៅភ្នំស្រីភ្នំប្រុស? ខ្ញុំមិនបានទទួលបន្ទុកខាងភ្នំស្រីភ្នំប្រុសទេ ប៉ុន ខ្ញុំសូម ចង់និយាយអំពីស្រុកកំពង់សៀមវិញ។ ស្រុកកំពង់សៀម គឺខ្ញុំបានអប់រំ កន្លែងហ្នឹង តែឲ្យខ្ញុំបញ្ជូនមនុស្សទៅសម្លាប់នៅភ្នំស្រីភ្នំប្រុសៗគឺអត់មានទេ តែក្នុងហ្នឹងក្នុងការអប់រំ សូមបញ្ជាក់លោកស្រីថា ការអប់រំរបស់ខ្ញុំនៅក្នុងស្រុក សន្តិសុខនៅក្នុងស្រុកនេះ គឺមិនមែនជារឿងអីធំដុំ ត្រូវសម្លាប់មនុស្សទេ គឺខ្ញុំអប់រំតែរឿងណាដែលវាមានការទាក់ទងរវាង ខិលខូច ការលួចប្លន់អីទេ ការលួចស៊ីសុខទុក្ខអីអ៊ីចឹងទេ តែឲ្យមានរឿងធំដុំដែលអាចយកទៅសម្លាប់ ហើយខ្ញុំក៏មិនអាចអារកាត់ចំពោះខ្លួនឯងបានដែរ គឺមានថ្នាក់លើ តែខ្ញុំក៏មិនដែលបានបញ្ជូនហ្នឹងទៅកន្លែងភ្នំស្រីភ្នំប្រុសដែរ។ ហើយនេះសូមជម្រាប ហើយលោកស្រីបានសួរមកខ្ញុំក៏វាអត់ដែលដឹងមែន កន្លែងហ្នឹងសម្លាប់មនុស្សអី ខ្ញុំឮតែនៅស្រុកកំពង់សៀមមែន តែជាការងាររបស់ខាងណាក៏ខ្ញុំអត់ដឹងដែរ។ នេះ សូមបញ្ជាក់ឲ្យខ្លីអ៊ីចឹង កុំឲ្យលោកស្រីមានការទាក់ទាមដល់ខ្ញុំថាបើខ្ញុំបានស្តាប់ថា ដូចជារឿងហ្នឹងគេយកបន្ទុកខ្លួនឯង។ ខ្ញុំសូមជម្រាបថា មិនមែនបន្ទុកខ្លួនឯងទេ គឺខ្ញុំបានធ្វើតែក្នុងស្រុក តែលោកស្រីបានសួរមកថា តើកន្លែងភ្នំស្រីភ្នំប្រុសហ្នឹងមានការ-- កន្លែងសម្លាប់

មនុស្ស? ខ្ញុំកន្លែងហ្នឹង ការសម្លាប់មនុស្សក៏ខ្ញុំអត់ដឹងដែរ ខ្ញុំដឹងតែក្នុងស្រុក។ នេះខ្ញុំសូមបញ្ជាក់ខ្លីអ៊ីចឹង។ សូមអស់។ ហើយកន្លែង ខ្ញុំសូមជម្រាបដែរ លោកស្រីសួរមកកន្លែងខ្លះក៏ខ្ញុំអត់យល់ដែរ ព្រោះខ្ញុំមិនបានធ្វើ។ អ៊ីចឹងខ្ញុំឆ្លើយថា អត់ៗយល់អ៊ីចឹង ឬក៏អត់ដឹង។ នេះ សូមបញ្ជាក់ខ្លីអ៊ីចឹង។

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:១០:០០]

**ប្រធានអង្គជំនុំ៖**

ពេលវេលាសម្រាប់តំណាងមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការសួរសាក្សីរូបនេះអស់ហើយ។ ឥឡូវនេះ អង្គជំនុំជម្រះផ្តល់វេទិកាទៅមេធាវីការពារក្តីលោក នួន ជា ដើម្បីមាន ឱកាសក្នុងការតាំងសំណួរ ចំពោះសាក្សីរូបនេះ ប្រសិនបើមាន។ សូមអញ្ជើញ!

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរអ្នកស្រីប្រាក់ យុត ខ្ញុំអាចនឹងបញ្ចប់មុនពេលដែលសម្រាកល្ងាចនេះ ខ្ញុំសង្ឃឹមថាធ្វើបាន។ ហើយប្រហែលជាមិនពិបាកប៉ុន្មានទេ ជាពិសេស។

**ស៖** អ្នកស្រីប្រាក់ យុត កាលពីសប្តាហ៍មុន លោកស្រីប្រាប់យើងថា នៅពេលដែលលោកស្រីជាសមាជិកនៃគណៈស្រុក៣៥ គឺថាទទួលបន្ទុកខាងកិច្ចការស្ត្រី កិច្ចការនារី តើមែនទេ?

**លោកស្រី ប្រាក់ យុត៖**

**ឆ៖** ចាស!

[១៤:១១:២៣]

**ស៖** តើគេហៅលោកស្រីថា ប្រធានទេ ឬក៏គណៈខាងស្ត្រីទេ កាលនោះ?

**ឆ៖** គេហៅខ្ញុំខាងកិច្ចការនារី ខាងស្ត្រី។

**ស៖** តើលោកស្រីធ្លាប់ជួបមនុស្សផ្សេងទៀត ដែលមកពីតំបន់ផ្សេង នៅក្នុងគណៈតំបន់ផ្សេងៗទៀត ដែលមកជួបលោកស្រីនោះ?

**ឆ៖** ខ្ញុំអត់យល់ តំបន់ផ្សេងៗម៉េច? សូមឲ្យ--

**ស៖** ថាតើមានការប្រជុំរវាងកម្មាភិបាលតំបន់ផ្សេងៗ ដែលមានសមាជិកតំបន់ចូលរួមទេ? មានការប្រជុំបែបនោះទេ?

**ផ៖** កាលនោះយើងប្រជុំក្នុងតំបន់៣៥ គឺមានសមាជិកតំបន់៣៥ គឺចូលរួមប្រជុំ។ តែបើកន្លែងផ្សេងៗអត់បានចូលរួមទេ។

**ស៖** តើលោកស្រីធ្លាប់ជួបមនុស្សម្នាក់ ដែលជាអ្នកទទួលខុសត្រូវនៅក្នុងកិច្ចការស្ត្រីនៅក្នុងតំបន់១៣ ដែរទេ?

[១៤:១៣:១២]

**ផ៖** មនុស្សម្នាក់ខ្ញុំមិនដឹងឈ្មោះអី ខ្ញុំអត់ច្បាស់ដែរ។ ដល់លោកលើកឲ្យខ្ញុំស្គាល់ឈ្មោះ បានខ្ញុំដឹងថាជួប។

**ស៖** ខ្ញុំអាច-- ម្នាក់ហ្នឹងគាត់កើតនៅក្នុងស្រុករបស់លោកស្រីនោះដែរ នៅក្នុងភូមិ នៅក្នុងឆ្នាំ១៩៤៦។ បាទ ដែលថាអ្នកនោះអាយុប្រហែលនឹងអ្នកស្រីនោះដែរ តើអាចឲ្យអ្នកស្រីនឹកឃើញទេ?

**ផ៖** ចាស ខ្ញុំនឹកអត់ឃើញផង មិនដឹងអ្នកណា។ ភ្លេចហើយ វាយូរពេកហើយ។

**ស៖** កាលពីអាទិត្យមុន នៅពេលដែលលោកស្រីនិយាយអំពីសមាជិកតំបន់៣៥នោះ លោកស្រីបានបញ្ជាក់ឈ្មោះមួយចំនួន មាន តាផន, តាជុន, តាឃុត, កង ចាប ហើយនិង តាទី។

**ផ៖** ហ្នឹងក្នុងគណៈតំបន់៣៥ ខ្ញុំស្គាល់ឈ្មោះទាំងអស់គណៈតំបន់៣៥។ តាផន, តាទី, តាសៀន, តាកុត, តាណយ ខ្ញុំស្គាល់ទាំងអស់គណៈតំបន់៣៥ លើកលែងតែ-- រាល់ថ្ងៃគាត់ស្លាប់អស់ហើយ ខ្ញុំ-- ដូចអត់មាននៅទេ នៅសល់ម្នាក់តែចាស់ហើយ។

[១៤:១៥:០០]

**ស៖** ថាតើអ្នកណាខ្លះដែលថានៅរស់នៅឡើយនោះមានប៉ុន្មាន?

**ផ៖** អត់មានរស់ផង ស្លាប់អស់ហើយនៅសល់តែខ្ញុំមួយហ្នឹង មើលតាផន ក៏ស្លាប់ តាសៀន ក៏ស្លាប់ តាទី ក៏ស្លាប់ តាកុត ក៏ស្លាប់។ ស្លាប់អស់ហើយ បីបួនប្រាំនាក់ហើយ តាណយ ក៏ស្លាប់។ ស្លាប់អស់ប្រាំនាក់។ ហើយនៅសល់រស់ ក៏ខ្ញុំមិនដែលបានទៅសួរសាកអី មិនដឹងជាមានអ្នកណានៅរស់ប៉ុន្មាននាក់ខ្ញុំ-- ដូចអត់មាននៅសល់ទេ តាមខ្ញុំស្គាល់។

[១៤:១៥:៤៩]

**ស៖** តើលោកស្រីនៅចាំទេ ការសម្ភាសលើកទី២ ដែលលោកស្រីជួបជាមួយអ្នកស៊ើបអង្កេតពីតុលាការនេះនោះណ៎ានៅឆ្នាំ២០០៩ ការសម្ភាសនោះខ្លីទេ លោកស្រីនៅចាំទេ?

**ផ៖** ទៅមុនដំបូងអ្ហែ?

**សៈ** បាទ ការសម្ភាសទីពីរ សម្ភាសទីពីរ បាទ។

**ឆៈ** សម្ភាសទីពីរ គឺសម្ភាសខ្លី ខ្ញុំអត់បានចាំដែរ មិនដឹងថ្ងៃណា ទាល់មើលក្នុងគម្រោង។

**សៈ** តើលោកស្រីនៅចាំសំណួរ ដែលគេសួរលោកស្រីទេ? បាទ ដែលសួរនៅសម្ភាសនោះ?

**ឆៈ** ចាស ខ្ញុំអត់សូវចាំដែរ ខ្ញុំមើលទៅ ប៉ុន្តែដូចថា មិនសូវចាំ វាមិនបានមើលរាល់ថ្ងៃ ប៉ុន្តែថ្ងៃប៉ុន្មានថ្ងៃនេះ ខ្ញុំមើលចប់ តែវាមិនចាំទាំងអស់។ កន្លែងខ្លះក៏ខ្ញុំភ្លេចដែរ។

**សៈ** គេបានសួរលោកស្រីសំណួរមួយ។ សួរថាតើ តាអាន ជាសមាជិកនៃគណៈស្រុក៣៥ដែរឬទេ? គេសួរអ៊ីចឹង។ បាទ តំបន់១។

**ឆៈ** តាអាន ហ្នឹង អង្កាល់នុំងគាត់ មិនដឹងសមាជិកទីប៉ុន្មានទេ តែឃើញនៅតំបន់៣៥ដែរ តែខ្ញុំក៏ឃើញគាត់ធ្វើមិនដឹងទី៤ ឬក៏ទី៣ ឬក៏ទី៥ ឬក៏ប៉ុន្មានទេ ពូអានគាត់ធ្វើដែរនៅក្នុងតំបន់៣៥ហ្នឹង។ តែមិនដឹងសមាជិកទី៣ ឬក៏៤ ខ្ញុំមិនបានចាំទេ តែនេះឈ្មោះពូអាន។ ខ្ញុំគឺទី៤ គាត់មិនដឹងទី៣ ឬក៏យ៉ាងម៉េចព្រោះក្នុងស្រុកតំបន់៣៥ វាមានទី៣ ទី៤ ទី៥ ទី៦ ទី៧ ច្រើនណាស់។ វាមានច្រើន-- គណៈតំបន់ហ្នឹងគឺមានច្រើននាក់៨រូប ៩រូប ហើយពូអានគាត់មិនដឹងជានៅក្នុងសមាជិកទីប៉ុន្មាន ខ្ញុំវាអត់ច្បាស់លាស់ដែរ។

[១៤:១៨:៣៥]

**សៈ** លោកស្រី ប្រាក់ យុត ហេតុអ្វីបានជា លោកស្រីតែងតែភ្លេចឈ្មោះគាត់ នៅពេលដែលគេសួរលោកស្រី អំពីសមាជិករបស់គណៈតំបន់៣៥ លោកស្រីតែងតែភ្លេចឈ្មោះគាត់នោះ ហេតុអ្វីតែងតែភ្លេច?

**ឆៈ** តែងភ្លេចឈ្មោះ ខ្ញុំហ្នឹងអ្ហែ? ចេះតែភ្លេច នេះសូមជម្រាប មិនដឹងយ៉ាងម៉េចចេះតែភ្លេចឈ្មោះខ្លួនឯង។ ដូចថា កង ចាប គាត់ប្រធានហើយ តាផន អនុ តាសៀន សមាជិកអ៊ីចឹងមក មាន តាទីមាន ខ្ញុំ មានអ្នី តាអាន អ៊ីចឹងមក ច្រើនគ្នាវាភ្លេចដែរ វាយូរពេកហើយ។ ហើយខ្លួនខ្ញុំចេះតែភ្លេចផ្ទាល់ខ្លួនឯង ចេះតែភ្លេចរហូត។ នេះសូមអស់។

[១៤:១៩:៣៣]

**សៈ** តើលោកស្រីចាំទេ តើ តាអាន ហ្នឹងគាត់ធ្វើអ្វី ឬជួបបញ្ហាអ្វីទេ នៅពេលដែលលោកស្រីឬក៏បាទគាត់នោះ ទៅកាន់នៅតំបន់៤១នោះ?

**ឆៈ** គាត់អង្កាល់នៅតំបន់៤១ គាត់មានជួបប្រទះអីទេ គាត់ជាលេខានៅជាមួយខ្ញុំហ្នឹង។

**សៈ** តើគាត់ជាលេខាតំបន់៤១ហ្នឹង ជាប្រធានរបស់លោកស្រីឬ?

**ផ៖** គាត់ជាប្រធានរបស់ខ្ញុំ។

**ស៖** ចាតើលោកស្រីចាំទេ អ្នកណាជាអនុលេខានៃតំបន់ហ្នឹង?

**ផ៖** ខ្ញុំអត់បានចាំដែរ អនុលេខាហ្នឹង ហើយសមាជិកទីមួយ ទីពីរហ្នឹង ដឹងដូចជា កាន ឬក៏មាន ការ, មានតាកាន, មានតាស៊ីម ហើយបីនាក់ទៀតខ្ញុំភ្លេចឈ្មោះហើយ មិនដឹងអ្នកណាគេ។

**ស៖** អនុប្រធាននៃ-- អនុលេខានោះ គឺតាអាន តើលោកស្រីអាចនឹកឃើញទេ? ប្រហែលទេ?

**ផ៖** មិនមែន តាអាន ទេ តាអាន ប្រធាន។ អនុលេខា--

[១៤:២១:៣២]

**ស៖** ចង់សួរលេខាភូមិភាគថ្មីៗ ភូមិភាគកណ្តាលថ្មី។ នៅក្នុងបទសម្ភាសន៍ទីពីរ លោកស្រីបាន ឆ្លើយថា លោកមិនដឹងថា តាអាន ស្លាប់ ឬរស់ អត់ដឹងទេឥឡូវនេះនោះ។ លោកស្រីបានឆ្លើយអ៊ីចឹងនៅ ក្នុងឆ្នាំ២០០៩។

**ផ៖** ហើយនៅក្នុងគណៈភូមិភាគ ខ្ញុំអត់យល់។ សូមសួរម្តងទៀត។ គណៈភូមិភាគថ្មីម៉េច? ខ្ញុំ មិនយល់។

**ស៖** សំណួរ យើងចូលទៅដល់សំណួរមួយទៀត។ តើត្រឹមត្រូវទេ ដែលថាលោកស្រីអត់ដឹងថា គាត់ស្លាប់ ឬរស់ទេឥឡូវនេះនោះ?

**ផ៖** ខ្ញុំអត់ដឹងដែរ។ អត់បានជួបគ្នា តាំងរត់យួន អ៊ំ រត់មកមិនដែលបានជួបគាត់ទេ។ មិនដឹងជា គាត់ស្លាប់ ឬរស់ខ្ញុំមិនដែលបានទាក់ទងគ្នា។

[១៤:២២:៤២]

**ស៖** អ៊ីចឹង គឺថាបើតាមខ្ញុំដឹង គាត់ប្រហែលជាគាត់រស់នៅចម្ងាយពីលោកស្រីនោះ ប្រហែល ជា៣០គីឡូម៉ែត្រទេ នៅឆ្ងាយពីឃុំលោកស្រីនោះ។

**ផ៖** ចាស អត់បានទាក់ទងគ្នាទេកន្លងទៅ ព្រោះខ្ញុំមិនដែលដឹងថា គាត់នៅ ឬអត់។ និយាយការ ពិត មិនមែនចេះតែកុហកទេ គឺនិយាយការពិតតែម្តង។ អត់ដែលបានជួបគ្នា តាំងពីថ្ងៃនោះមកដល់ថ្ងៃ នេះ។ អត់ដែលបានឃើញគ្នាទេ ប៉ុន្តែនៅឆ្ងាយពីគ្នាមែន តែខ្ញុំអត់ដែលបានទាក់ទងគ្នាទេ។

**ស៖** ខ្ញុំចាប់អារម្មណ៍ថា គឺថាលោកស្រីដូចជាមានការលំបាកណាស់ក្នុងការបំភ្លឺព័ត៌មានអីដែល ទាក់ទងទៅនឹង តាអាន។ ហេតុអីបានជាមានការលំបាកអ៊ីចឹង? ប្រាប់តុលាការបានទេ?

[១៤:២៣:៣៥]

**ឆះ** ខ្ញុំអត់ខ្លាចទេ ប៉ុនខ្ញុំវាអត់ការពិត។ ដូចថា ពូ អាន នៅ ខ្ញុំមិនដឹងថាគាត់នៅឯណា។ កន្លងទៅខ្ញុំមិនដែលបានជួបគាត់ អ៊ីចឹងខ្ញុំនិយាយទៅនាំឲ្យខុសតែខ្ញុំ។ បើខ្ញុំមិនដែលឃើញគាត់ផង ឲ្យខ្ញុំបំភ្លឺតុលាការយ៉ាងម៉េច។ បើឧទាហរណ៍ យើងពីមុនរស់នៅជាមួយមែន តែក្រោយមកខ្ញុំវាអត់បានជួបគាត់ មិនដឹងថា គាត់នៅរស់ ឬក៏ស្លាប់។ ខ្ញុំប្រាប់ដល់លោកសង្កេតការណ៍ដែរតើ! ខ្ញុំមិនដែលជួបគាត់ទេ ពីថ្ងៃនោះមកដល់ថ្ងៃនេះ រហូតមកដល់ថ្ងៃនេះ ខ្ញុំនិយាយពីការពិតតើ! ព្រោះខ្ញុំមិនមែនខ្លាចបំភ្លឺទេ។ ព្រោះបើឃើញ ខ្ញុំបំភ្លឺហើយ តែវាអត់ដឹងថា គាត់នៅឯណាមែនហ្នឹង តែលោកថាគាត់នៅចម្ងាយប៉ុណ្ណេះគីឡូៗ។ ព្រោះខ្ញុំអត់ដែលបានជួប បានខ្ញុំថាមិនដឹង បើសិនថាខ្ញុំបានជួប ខ្ញុំក៏មិនអាចប្រកែកបានដែរក្នុងបញ្ហានេះ។ បើយើងបាននៅជាមួយគ្នា ខ្លាចអីនិយាយ។ ប៉ុន្តែខ្ញុំវាអត់បានជួប មិនដឹងថាពេលរត់យួនមក គឺបែកគ្នារហូត ហើយនិងកាលពីក្រោយដកប្តីមក ខ្ញុំក៏មកមុនគាត់រហូត។

[១៤:២៤:៤០]

ហេតុនេះខ្ញុំមិនដែលបានជួបគាត់ ជារឿងពិតតើ! ហើយអង្កាល់នោះគេដូចថា មិនសូវស្គាល់ខ្ញុំអីដែរ ហើយទោះបីគេឮដំណឹងអី ក៏គេមិនសូវចាប់អារម្មណ៍ដែរ ព្រោះខ្ញុំវាអ្នកមានសមាសភាព។ នេះខ្ញុំនិយាយដោយការស្មោះត្រង់។ អ៊ីចឹងរហូតដល់ថ្ងៃនេះ ក៏ខ្ញុំអត់ដែលបានទាក់ទងគ្នាដែរ។ នេះ ខ្ញុំសូមនិយាយដោយការពិតអ៊ីចឹងតែម្តង កុំឲ្យលោកនៅងឿងឆ្ងល់ថា ខ្ញុំ ប្រហែលជារឿងអីបានជានៅមិនហ៊ាននិយាយរឿង ពូ អាន សោះ។ ខ្ញុំមិនមែនថា មិនហ៊ាននិយាយទេ ខ្ញុំហ៊ាននិយាយ តែដោយខ្ញុំវាអត់ឃើញគាត់ ហើយតាំងពីថ្ងៃនោះ មកដល់ថ្ងៃនេះខ្ញុំអត់ដែលបានជួបគាត់មែន។ នេះ សូមជម្រាបដោយការស្មោះត្រង់ក្នុងអង្គប្រជុំតែម្តង។

[១៤:២៥:៣០]

ហើយគឺបញ្ហានេះ ខ្ញុំឃើញលើកមកសំណួរគ្រប់សំណួរបញ្ហា ហើយខ្ញុំសូមបញ្ជាក់ដែរ ដូចលោកស្រីគាត់បានលើកអ៊ីចឹងថា នៅក្នុងភ្នំស្រីភ្នំប្រុស មានការសម្លាប់មនុស្ស ហើយហេតុអីក៏ខ្ញុំអត់ដឹង? ការពិតជារឿងរបស់ខ្ញុំដែលដឹង គឺខ្ញុំត្រូវដឹងដែរ បើខ្ញុំអត់ដឹង មិនដឹងថាឆ្លើយថាដឹងយ៉ាងម៉េច។ អ៊ីចឹងហើយ នាំឲ្យខ្ញុំចេះតែឆ្លើយទទេៗនៅក្នុងអង្គសវនាការ។ នេះ ខ្ញុំសូមជម្រាបអ៊ីចឹង។

**សះ** លោកស្រី ប្រាក់ យុត តើលោកស្រីធ្លាប់ដឹងទេ ថាមានរឿងក្តី០៤ នៅតុលាការនេះ? ធ្លាប់ដឹងទេ?

[១៤:២៦:១៦]

**ប្រធានអង្គជំនុំ៖**

លោកស្រីមិនបាច់-- សាក្សីមិនបាច់ឆ្លើយរឿងហ្នឹង ឆ្លើយតបជាមួយនឹងមេធាវីទេ ហើយរឿងនោះមិនពាក់ព័ន្ធនឹងរឿងនេះទេ ហើយករណីឈ្មោះ អាន ហ្នឹង ក៏មិនពាក់ព័ន្ធនៅក្នុងសំណុំរឿង០០២/១ដែរ។

មេធាវីអាចបន្តសំណួរផ្សេងទៀត ហើយសូមរៀបចំនូវសំណួរណាដែលពាក់ព័ន្ធនឹងអង្គហេតុដែលអង្គជំនុំជម្រះកំណត់ធ្វើសវនាការ។ មិនស្រេចតែចិត្តក្នុងការពន្លាតនៅក្នុងវិសាលភាពដែលនូវអ្វីដែលមិនពាក់ព័ន្ធនោះឡើយ។

[១៤:២៧:២៩]

**សួរដោយលោក ម៉ៃខល ផេសមិន៖**

សូមអភ័យទោសលោកប្រធាន។

**ស៖** បាទ អ៊ីចឹងគឺថាអ្នកដែលទទួលបន្ទុកខាងកិច្ចការនារីនៅក្នុងតំបន់នោះ គឺឈ្មោះ អ៊ឹម ចែម នៅតំបន់១៣។ តើលោកស្រីដឹងទេ?

**លោកស្រី ប្រាក់ យុត៖**

**ឆ៖** ចាស ខ្ញុំអត់បានទាក់ទងគ្នាផង សម័យនោះ គឺយាយ ចែម គាត់នៅតំបន់១៣ គាត់ចេះតែនៅ ប៉ុន្តែការទាក់ទងរវាងគ្នាទៅវិញទៅមក គឺខ្ញុំមិនដែលបានទាក់ទងទេ។ ហើយបើការ-- យើងមកធ្វើការ មកប្រជុំអី នៅតំបន់១៣អី ចូលរួមគ្នា គឺបានជួប តែឲ្យទាក់ទងការងារជាមួយគាត់ គឺអត់មានទេ។ គាត់ធ្វើផ្សេង ខ្ញុំធ្វើផ្សេង។

[១៤:២៨:២៧]

**ស៖** ដូចដែលខ្ញុំដឹង គឺថា តាអាន ហើយនិង អ៊ឹម ចែម គឺជាជនសង្ស័យនៅក្នុងរឿងក្តីទីបួន តើលោកស្រីដឹងទេ?

**ឆ៖** ចាស ខ្ញុំអត់ដឹង។

**ប្រធានអង្គជំនុំ៖**

លោកមេធាវី យើងបានប្រាប់អម្បាញ់មិញហើយ សំណុំរឿងពាក់ព័ន្ធនឹង០៣, ០៤ គឺជារឿងមួយដោយឡែក គេរៀបចំ កំពុងតែរៀបចំ បាននឹងរៀបចំដំណើរការដាច់ដោយឡែកពីសំណុំរឿង០២។ នៅក្នុងសំណុំរឿង០២ទៀតសោត អង្គជំនុំជម្រះបានកំហិត កំណត់នូវវិសាលភាពនៃអង្គហេតុសម្រាប់

ធ្វើសវនាការយ៉ាងជាក់ច្បាស់។

យើងគិតថាលោកមេធាវីយល់ច្បាស់ពីបញ្ហានេះ ហើយអង្គជំនុំជម្រះកំហិតកំណត់លោកសួរដេញដោលកំហិតត្រឹមតែវិសាលភាពដែលពាក់ព័ន្ធជាមួយនឹងអង្គហេតុ ដែលត្រូវធ្វើសវនាការក្នុងសំណុំរឿង០០២/១ ដោយតាមលំដាប់លេខរៀងពីអង្គហេតុលេខតូចមកលេខធំ។

**លោក ម៉ៃខល ផេសមិន៖**

សូមអភ័យទោសលោកប្រធាន *ហេតហ្វូន*របស់ខ្ញុំ ប្រដាប់ស្តាប់ខ្ញុំស្តាប់អត់ទាន់ សូមអភ័យទោស ស្តាប់អត់បានការសម្រេចរបស់លោកប្រធាន។

[១៤:២៩:៥៤]

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

ខ្ញុំនឹងប្រាប់ទៅ ជម្រាបទៅលោក លោកប្រធានបានសម្រេចពីរដងហើយថា លោកគប្បីតែតាំងសំណួរក្នុងរង្វង់នៃរឿងក្តី០០២ វគ្គទីមួយនេះតែប៉ុណ្ណោះ។ តើលោកច្បាស់ទេប៉ុណ្ណឹង?

**លោក ម៉ៃខល ផេសមិន៖**

សំណួររបស់ខ្ញុំ គឺស្ថិតនៅក្នុងរង្វង់ នៅក្នុងវិសាលភាព។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមលោកកុំតតាំងជាមួយនឹងយើងខ្ញុំ។ សូមលោកបន្តទៅប្រធានបទផ្សេង។

**លោក ម៉ៃខល ផេសមិន៖**

ខ្ញុំសូមជំទាស់ ខ្ញុំសូមបញ្ជាក់ថានៅក្នុងរឿងក្តីនេះ គឺថាយើងខ្ញុំយល់ថារដ្ឋាភិបាលជ្រៀតជ្រែកឬរំខានដល់រឿងក្តី០០២ ដែលទាក់ទងនឹងកូនក្តីរបស់ខ្ញុំផងដែរ គឺរឿងក្តី០០២។ ខ្ញុំនឹងសុំសួរសំណួររបស់ខ្ញុំតទៅទៀត។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

ខ្ញុំដឹងហើយថា តួនាទីរបស់លោកគឺតំណាងការពារកូនក្តីរបស់លោក ដូច្នេះសូមលោកបន្តតាំងសំណួរនៅក្នុងបរិបទសវនាការនាថ្ងៃនេះ។ អរគុណ។

[១៤:៣១:២៧]

**សួរដោយលោក ម៉ៃខល ផេសមិន៖**

**ស៖** មុនពេលដែលលោកស្រីផ្តល់សក្ខីកម្ម លោកស្រី ប្រាក់ យុត តើមាននរណាគេធ្លាប់ទៅរក

លោកស្រីដែរឬទេ? មាននរណាគេទៅទាក់ទងលោកស្រីអំពីការដែលលោកស្រីមកបង្ហាញខ្លួននៅតុលាការនេះដែរឬទេ?

**លោកស្រី ប្រាក់ យុត៖**

**ឆ៖** មាន--

**ប្រធានអង្គជំនុំ៖**

សំណួរ អ្ហឺ! សាក្សីមិនបាច់ឆ្លើយតបនឹងសំណួរនេះទេ។ សំណួរហ្នឹងមិនពាក់ព័ន្ធនឹងអង្គហេតុដែលត្រូវសួរដេញដោលទេ។

[១៤:៣២:១២]

**សួរដោយលោក ម៉ៃខល ផេសមិន៖**

**ស៖** តើលោកស្រីដឹងថារដ្ឋាភិបាលជំទាស់នឹងការស៊ើបអង្កេតបន្ថែម និងចោទប្រកាន់ទៅលើសំណុំរឿង០៤ដែរឬទេ?

**ប្រធានអង្គជំនុំ៖**

លោកស្រីមិនចាំបាច់ឆ្លើយនឹងសំណួរនេះឡើយ។

អញ្ជើញសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ គឺខ្ញុំអំមិញហ្នឹងរៀបនឹងធ្វើការជំទាស់ទៅនឹងសំណួររបស់មេធាវីការពារក្តី។ ខ្ញុំមិនដឹងថាតើការសួរទៅលើសំណុំរឿងជនសង្ស័យផ្សេងនោះ វាពាក់ព័ន្ធយ៉ាងម៉េចនោះទេ។

យើងដឹងហើយថា មានតែបុគ្គលមួយចំនួនតែប៉ុណ្ណោះនៅក្នុងបន្ទប់នេះដែលដឹងអំពីការរក្សាការសម្ងាត់។ ដូច្នេះសាក្សីក៏គាត់មិនដឹងអំពីការគោរពទៅលើការរក្សាការសម្ងាត់នេះដែរ។ ដូច្នេះ ខ្ញុំសូមជំទាស់ទៅលើសំណួរដែលបានសួរដោយមេធាវីការពារក្តី។ សូមអរគុណ។

**លោក ម៉ៃខល ផេសមិន៖**

គឺវាជាការដឹងទូទៅរួចទៅហើយ ដែលថាជនសង្ស័យនៅក្នុងសំណុំរឿង០០៤នោះ គឺនរណាគេនោះ។ គឺបានផ្សព្វផ្សាយតាមគេហទំព័រសឹងតែជាសាធារណៈរួចទៅហើយ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវី ថ្ងៃនេះអង្គជំនុំជម្រះមិនបានឲ្យលោកសួរដេញដោលពាក់ព័ន្ធនឹងបញ្ហាទាំងឡាយ

នៅក្នុងសំណុំរឿងផ្សេង ក្រៅពីសំណុំរឿង០០២/០១ ឡើយ។

**លោក ម៉ៃខល ផេសមិន៖**

លោកប្រធាន ខ្ញុំជឿថាសាក្សីនេះមិន ហាក់ដូចជាគាត់ហ្នឹងមិនបង្ហាញអំពីការផ្ដល់សក្ខីកម្មដោយសេរីសោះ។ ដោយសារតែយើងដឹងហើយថា រដ្ឋាភិបាលគាត់មិនចង់ឲ្យមានការចោទប្រកាន់ ស៊ើបអង្កេតទៅនឹងសំណុំរឿង០០៤ ដូច្នេះហើយទើបខ្ញុំសួរគាត់អំពីចំណុចដែលវាអាចពាក់ព័ន្ធទៅនឹងសំណុំរឿងនេះផង ដែលថាវាអាចប៉ះពាល់ទៅដល់រឿង០០២ របស់យើង ដែលគាត់មានការភ័យខ្លាច។ ដូច្នេះខ្ញុំសូមអនុញ្ញាតសួរបន្តទៅទៀត។

[១៤:៣៤:៣៧]

**ប្រធានអង្គជំនុំ៖**

អនុញ្ញាតឲ្យសួរ ប៉ុន្តែលោកមិនឲ្យ យើងបានប្រាប់ហើយ មិនឲ្យលោកពាក់ព័ន្ធលើបញ្ហានេះទៅនឹងសំណុំរឿងផ្សេងឡើយ។ ការសួរដេញដោលនៅសំណុំរឿង០០២ នេះទៀតសោត កំហិតត្រឹម ០០២/០១ តែប៉ុណ្ណោះដែលយើងបានកំណត់ឲ្យភាគីទាំងអស់បានដឹងរួចហើយ។ ហើយសួរតែពាក់ព័ន្ធទៅសាក្សីដែលលោកគិតថា សាក្សីនុ៎ងដឹងអង្គហេតុទាំងឡាយដែលគាត់បានដឹងពាក់ព័ន្ធជាមួយនឹងអង្គហេតុដែលអង្គជំនុំជម្រះបានសម្រេចនៅក្នុង០០២/០១ ដោយធ្វើលំហូរនៃនីតិវិធីចៀសវាងការច្របូកច្របល់ឲ្យដំណើរការពីអង្គហេតុវគ្គដំបូងវគ្គទីមួយនេះ គឺបរិបទប្រវត្តិសាស្ត្របក្សកុម្មុយនីស្តកម្ពុជា បន្ទាប់មកគឺរចនាសម្ព័ន្ធរដ្ឋបាលកម្ពុជាប្រជាធិបតេយ្យ ហើយនិងលំដាប់បន្តបន្ទាប់ត្រឹមកម្រិត០០២/០១ បើពុំដូច្នោះទេគឺលោកនឹងអាចអស់ពេលវេលានៅក្នុងការសួរ ប្រសិនបើលោកនៅតែព្យាយាមចាកចេញពីអង្គហេតុ ដែលអង្គជំនុំជម្រះបានកំណត់ឲ្យធ្វើសវនាការដេញដោលនៅក្នុងអង្គសវនាការដំណាក់កាលដំបូងនេះ។ សួរគ្រប់ភាគី គ្រប់គោលដៅនៃការសួរទាំងអស់។

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:៣៧:៤២]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម លោកស្រីអាចតាំងសំណួរចំពោះសាក្សីរូបនេះមួយចំនួន។ សូមអញ្ជើញ!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

**ស៖** លោកស្រី ប្រាក់ យុត លោកស្រីបាននិយាយជារឿយៗរួចមកហើយនៅក្នុងតុលាការនេះ ថាលោកស្រីមិនបានចងចាំអង្គហេតុ ឬក៏ហេតុការណ៍ដែលបានកើតឡើងជាង៣០ឆ្នាំមកហើយនោះទេ។ ដូច្នេះខ្ញុំចង់សុំសួរលោកស្រីមួយ ឬក៏ពីរសំណួរនៅពេលនេះដោយសារតែមេធាវីខាងការពារក្តីលោក នួន ជា បានគិតថាលោកស្រីមានការភ័យខ្លាចមិនហ៊ានឆ្លើយទៅនឹងសំណួរនៅក្នុងថ្ងៃនេះ។ ដូច្នេះ ខ្ញុំសូមសួរថាតើមាននរណាគេគំរាមកំហែងលោកស្រីក្នុងការមកផ្តល់ចម្លើយ ឬក៏សក្ខីកម្មក្នុងតុលាការនៅក្នុងថ្ងៃនេះដែរឬទេ?

**លោកស្រី ប្រាក់ យុត៖**

**ឆ៖** ខ្ញុំសូមបញ្ជាក់ថា ការខ្ញុំឡើងមកសវនាការនេះអត់មានអ្នកណាគំរាមកំហែងទេ។ គឺខ្ញុំឡើងមកនិយាយ បើខ្ញុំចងចាំប៉ុនណា ខ្ញុំនិយាយប៉ុណ្ណឹង តែរឿងមិនដឹងគឺខ្ញុំអត់ដឹង។ ហេតុនេះ ខ្ញុំមិនមានអ្នកណាគំរាមកំហែងខ្ញុំមិនឲ្យនិយាយទេ។ នេះខ្ញុំសូមជម្រាបប៉ុណ្ណឹង។

[១៣:៣៩:១៤]

**ស៖** តើមានគេឲ្យលោកស្រីនិយាយឲ្យប្រយ័ត្នប្រយែងដែរឬទេ នៅពេលដែលមកផ្តល់ចម្លើយក្នុងតុលាការនេះ។

**ឆ៖** អត់មានអ្នកនិយាយថាឲ្យខ្ញុំនិយាយប្រយ័ត្នប្រយែង គាត់ឲ្យឡើងតុលាការ យើងជម្រាបអំពី បំភ្លឺតុលាការជារឿងពិត ក្នុងហ្នឹងខ្ញុំក៏អត់មាននិយាយអីហួសពីការបំភ្លឺជារឿងពិតដែរ ព្រោះកន្លងព្រោះខ្ញុំនិយាយនេះសំដៅទៅលើខ្ញុំដឹង តែមិនដឹងក៏ខ្ញុំនិយាយមិនកើត។ ឥឡូវឧទាហរណ៍ថា៖ ដូចលោកបានសួរខ្ញុំពីរឿងយាយ ថែម យាយអី ខ្ញុំអត់ដឹងមែន មិនដឹងថាខ្ញុំលើកយកមករាយការណ៍ឲ្យគាត់យ៉ាងម៉េច បើខ្ញុំវាអត់បានដឹងរឿង នេះខ្ញុំសូមជម្រាប។ ហើយរឿងនេះមិនមែនអ្នកណាបញ្ឆេះខ្ញុំ មិនមែនអ្នកណាមិនឲ្យខ្ញុំនិយាយ គឺខ្ញុំនិយាយកម្រិតត្រឹមថាខ្ញុំដឹងចុះ បើខ្ញុំមិនដឹង ក៏ខ្ញុំមិនហ៊ាននិយាយដែរ។ ហ្នឹងខ្ញុំសូមជម្រាបលោកប្រធានអ៊ីចឹង។

[១៤:៤០:១៧]

**ស៖** លោកស្រីបាននិយាយជាច្រើនដងរួចមកហើយថា លោកស្រីមិនបានចងចាំអង្គហេតុ ឬក៏ហេតុការណ៍មួយចំនួននោះទេ ក៏ប៉ុន្តែលោកស្រីបានជម្រាបតុលាការផងដែរថា លោកស្រីនិយាយតែការពិតនៅពេលដែលគេទៅសម្ភាសលោកស្រីប្អូនដង។ នៅពេលដែលអ្នកស៊ើបអង្កេតពីតុលាការទៅស៊ើបអង្កេតលោកស្រីប្អូនដង គឺលោកស្រីនិយាយតែការពិតទេជូនខាងអ្នកស៊ើបអង្កេត តើមែនដែរឬទេ?

**ឆ៖** ខ្ញុំនិយាយតែការពិតទេ នេះជូនលោកអ្នកស៊ើបអង្កេតនោះ។

**ប្រធានអង្គជំនុំ៖**

បាទឥឡូវនេះដល់ពេលសមល្មមនឹងសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី ចាប់ពីពេលនេះទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីតុលាការសម្របសម្រួលឲ្យសាក្សីរូបនេះបានទទួលនូវកន្លែងសម្រាកសមរម្យ ហើយនិងឲ្យអញ្ជើញគាត់ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មឲ្យបានមុនម៉ោង អង្គជំនុំជម្រះចូលកាន់អាសនៈ ដែលហើយអនុរក្សរក្សាសន្តិសុខ សូមសម្របសម្រួលដល់ក្រុមដើមបណ្តឹងរដ្ឋប្បវេណីដែលចូលរួមឲ្យរក្សាសណ្តាប់ធ្នាប់ល្អ មិនអាចបង្កនូវស្ថានភាពសំឡេងដែលមិនសមរម្យនៅក្នុងអង្គជំនុំជម្រះទៀតទេ។

*(សវនាការសម្រាកពីម៉ោង១៤:៤២នាទី ដល់ម៉ោង ១៥:០៦ នាទី)*

[១៥:០៦:៣៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ជាបន្តអង្គជំនុំជម្រះផ្តល់វេទិកាទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីបន្តការតាំងសំណួរចំពោះសាក្សីរូបនេះ។ ប្រសិនបើមានសូមអញ្ជើញ!

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមយកឱកាសនេះដើម្បីឆ្លើយដោយសង្ខេបទៅនឹងអ្វីដែលបានកើតឡើងមុនពេលសម្រាកនេះ។ ជាបឋមខ្ញុំសូមសង្កត់ធ្ងន់ថា យើងយល់ថាយើងមានសិទ្ធិ ហើយនិងកាតព្វកិច្ចដើម្បីតទល់អំពីភាពគួរឲ្យជឿជាក់បានរបស់សាក្សីនេះ ដោយយើងយល់ថា គាត់មិនបាននិយាយបង្ហាញពីការពិតទាំងស្រុងនោះទេ។

ទីពីរ គឺអាស្រ័យទៅលើមេធាវីការពារក្តីក្នុងសួរដេញដោលសាក្សីប្រភេទនេះ ហើយរីឯចៅក្រមក៏មិនទំនងជាមានសិទ្ធិដែលថាអាចនឹងជួយសង្គ្រោះសាក្សីក្នុងស្ថានភាពនេះបាននោះទេ។

[១៥:០៨:១០]

ហើយទីបី អាស្រ័យទៅលើខ្ញុំ ឬក៏ក្រុមមេធាវីរបស់លោក នួន ជា ក្នុងការសម្រេចថាតើយើងគប្បីសម្រេចយកវិធីណាដើម្បីការពារក្តីរបស់ខ្ញុំ។ ដូច្នេះហើយ យើងដរាបណាតែយើងខ្ញុំស្ថិតនៅក្នុងរង្វង់នៃអំណាច្បាប់ និងសិទ្ធិរបស់ជនជាប់ចោទដែលមានដោយច្បាប់នោះ។

ហើយយើងបានកត់សម្គាល់ កំណត់សម្គាល់ដោយចៅក្រម ខាត់វ៉ាយថ៍ នោះគឺមិនស្របទេ ដោយថាចៅក្រមមិនគប្បីរំខាន់ដល់យុត្តិសាស្ត្រ ដល់មេធាវីការពារក្តីនោះទេ។ គឺអាស្រ័យតែលើយើងខ្ញុំក្នុងការសម្រេចថាយកវិធីណាដើម្បីការពារកូនក្តីរបស់យើងខ្ញុំ។

នៅទីបំផុតនេះ ខ្ញុំសូមបញ្ជាក់ថា គឺ ហើយយើងបានលើកឡើងអំពីការរំខាន ការជ្រៀតជ្រែករបស់រដ្ឋាភិបាលនៅក្នុងរឿងក្តីនេះជាច្រើនដងហើយ។ ដូច្នេះហើយសូមឲ្យមានការកំណត់ត្រា ឲ្យតុលាការបានជ្រាបផងដែរ។ ហើយសូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់របស់លោក លោកស្រីចៅក្រម។

[១៥:០៩:១៨]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហព្រះរាជអាជ្ញា តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក ឌេល លីសាក់៖**

ខ្ញុំមិនចង់យកពេលតុលាការនេះមកចំណាយច្រើនទេ។ ប៉ុន្តែខ្ញុំឆ្លើយដោយសង្ខេបទៅនឹងមតិអម្បាញ់មិញនេះ។ ខ្ញុំមិនឯកភាព មិនយល់ស្របទៅនឹងមតិរបស់មេធាវីការពារក្តីទេ ដែលថាចៅក្រមរំខានដល់យុត្តិសាស្ត្ររបស់គាត់។ ដូច្នេះចៅក្រមយល់ថា នេះជាផ្នែកនៃការរក្សាការសម្ងាត់នៅក្នុងរឿងក្តីផ្សេង ជនសង្ស័យផ្សេង។ រីឯការសួរសាក្សីថាតើរដ្ឋាភិបាលជ្រៀតជ្រែក ឬមិនជ្រៀតជ្រែករឿងក្តីនោះ ចំពោះខ្ញុំៗយល់ឃើញថា នេះជាបញ្ហាដែលថា គាត់យល់ថា សាក្សីនេះត្រូវបានបំភិតបំភ័យនោះគឺលោកអាចសួរសំណួរតាមរបៀបផ្សេង។ ដូច្នេះ ក្នុងគំនិតនេះគឺថាអាចឲ្យតុលាការសួរសំណួរដើម្បីបញ្ជាក់ ហើយគាត់បានបញ្ជាក់ហើយ។ ខ្ញុំថា អ្វីដែលចៅក្រម ដែលតុលាការធ្វើនោះ គឺជារឿងដែលសមស្របត្រឹមត្រូវតាមច្បាប់ទាំងស្រុង។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំចង់ត្រឡប់មកនិយាយអំពីបញ្ហាដែលដើមបណ្តឹងរដ្ឋប្បវេណីចង់សួរទៅកាន់សាក្សីរូបនេះ ហើយច្បាស់ជាងនេះទៅទៀតគឺពាក់ព័ន្ធទៅនឹងឯកសារដែលខ្លួនចង់ប្រើប្រាស់ដើម្បីប្រើជាមូលដ្ឋានក្នុងការសួរសំណួររបស់ដើមបណ្តឹងរដ្ឋប្បវេណី។

ជាដំបូង អង្គជំនុំជម្រះចង់ដឹងថា តើឯកសារទាំងអស់នេះមានជាភាសាទាំងបីផ្លូវការរបស់ អ.វ.ត.ក ដែរឬទេ? ហើយថា ប្រសិនបើមិនមានការបកប្រែកឯកសារនោះ ថាតើមានការបកស្នើសុំបកប្រែឯកសារទាំងអស់នេះដែរឬទេ? នេះជាសំណួរ ដំបូងរបស់ខ្ញុំ។ សំណួរទីពីរ ពាក់ព័ន្ធទៅនឹងគោលបំណងដែលឯកសារទាំងអស់នេះ ថាមានសារៈសំខាន់។ ខ្ញុំចង់ដឹងថាតើហេតុអ្វីបានជាខាងដើមបណ្តឹងរដ្ឋប្បវេណីប្រើឯកសារនេះ ដើម្បីសួរសំណួរ ថាតើឯកសារទាំងអស់ហ្នឹងមានភាពពាក់ព័ន្ធយ៉ាងណាដែរ ហើយវាមានសារៈសំខាន់ខ្លាំងប៉ុនណា សម្រាប់សវនាការនៅថ្ងៃនោះ?

[១៥:១២:០៥]

**កញ្ញា ហ្វីលីពីន ស៊ុតហ្ស៍៖**

សូមអរគុណលោកចៅក្រម។ ចំពោះសំណួរទាំងពីររបស់លោកចៅក្រមនេះ គឺថាឯកសារមួយចំនួន មានជាទាំងបីភាសា ហើយឯកសារខ្លះទៀងមានតែជាភាសាអង់គ្លេស ហើយនិងជាភាសាខ្មែរទេ។ ខ្ញុំមិនដឹងៗទេ ថាមានការស្នើសុំឲ្យមានការបកប្រែ ឬក៏អត់នោះ។ ខ្ញុំអាចសួរសំណួរទៅកាន់អ្នកដែលតំណាងឲ្យកូនក្តីនេះបាន ក៏ប៉ុន្តែសំណួរ-- ឯកសារទាំងអស់នេះគឺជាឯកសារដែលមាននៅក្នុងសំណុំរឿងរួចហើយ។ ហើយក៏យើងបានដាក់បញ្ចូលទៅក្នុងសំណុំរឿងតាមរយៈសំណើពីរដែលធ្វើនៅខែ ប្រែលជាខែបួន ខ្ញុំចាំមិនសូវច្បាស់ដែរ។

[១៥:១២:៥៥]

គឺយើងមានសំណើនៅខែមេសា គឺលេខ E9/32 ហើយសំណើទីពីរ គឺនៅខែមករា-- (សូមទោស) គឺខែ កក្កដា E39/2។ ហើយចំពោះសំណួរទីពីរ របស់លោកចៅក្រមនោះ គឺគោលបំណងនៃការសួរសំណួររបស់យើងខ្ញុំនោះ គឺថា ដើម្បីបំភ្លឺការពិតទៅលើខ្សែសង្វាក់បញ្ជាការដែលមាននៅថ្នាក់ភូមិភាគ

ហើយនិងដើម្បីចង់ដឹងថា តើមានមនុស្សដែលត្រូវបានសម្លាប់ដែរឬទេ ហើយថាអ្នកណាជាអ្នកបញ្ជាឲ្យមានការសម្លាប់ទាំងអស់នេះ?

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

អ៊ីចឹងឯកសារទាំងអស់នេះ គឺជាឯកសារសេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីដែលមានហត្ថលេខារបស់ពួកគេទេ?

**កញ្ញា ហ្វីលីពីន ស៊ុតហ្ស៍៖**

លោកចៅក្រម គឺពិតហើយ គឺជាសេចក្តីថ្លែងការណ៍ដែលពួកគាត់ដាក់នៅពេលដែលធ្វើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ហើយជាឯកសារជាភាសាខ្មែរ ហើយមានការសង្ខេបជាភាសាអង់គ្លេស ហើយមាននៅក្នុងសំណុំរឿងរួចហើយ។ ហើយគឺឯកសារទាំងអស់នេះ ខ្ញុំប្រើជាមូលដ្ឋានសម្រាប់សួរហើយ សេចក្តីសង្ខេបនោះ គឺមានបកប្រែជាភាសាបារាំងខ្លះ ហើយខ្លះទៀតគឺអត់មានទេ មានតែជាភាសាខ្មែរ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:១៤:៤៤]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ដូច្នេះ ខ្ញុំគិតថា អង្គជំនុំជម្រះត្រូវការពេល ដើម្បីពិចារណាទៅលើបញ្ហានេះ ហើយយើងនឹងផ្តល់នូវសេចក្តីសម្រេចនៅពេលក្រោយ។

**កញ្ញា ហ្វីលីពីន ស៊ុតហ្ស៍៖**

សូមអរគុណលោកចៅក្រម។

[១៥:១៥:០០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំចង់ប្រើឱកាសនេះ ឬដើម្បីធានាថា សេចក្តីថ្លែងការណ៍ដែលលើកឡើងដោយ ប្រាក់ យុត ទៅសហចៅក្រមស៊ើបអង្កេតនោះ ត្រូវបានដាក់ជូនចំពោះមុខតុលាការហើយ។ ប៉ុន្តែយើងមិនទាន់ច្បាស់នៅត្រង់នេះ ថាតើស្ថានភាពបច្ចុប្បន្ននៃចម្លើយទាំងអស់នោះ ហើយខ្ញុំ

ឥឡូវនេះ គឺសូមប្រកាសដាក់ជូនចំពោះមុខតុលាការបួន D234/4 ហើយនិង ដែលមានការកែតម្រូវ ឯកសារ D324/4 ហើយជាការកែតម្រូវលេខ២ D234/8 ដែលដាក់ដោយមេធាវីការពារ នួន ជា គឺ ឯកសារ D234/15 ហើយនិងឯកសារ D324/16។

**សួរដោយចៅក្រម ស៊ីលវៀ ខាតវ៉ាយធ៍៖**

**ស៖** ខ្ញុំចង់សួរទៅលោកស្រី ប្រាក់ យុត នូវសំណួរមួយចំនួន។ នៅក្នុងភស្តុតាងដែលលោកស្រីបានបញ្ជាក់ពេលមុននោះ លោកស្រីបាននិយាយថា និយាយដដែលៗថា លោកស្រីមិនអាចចាំនូវព័ត៌មានច្រើនបានទេ ពីព្រោះថា ពេលច្រើនឆ្នាំកន្លងផុតមកហើយ។ តើអ៊ីចឹងមែនទេលោកស្រី?

**លោកស្រី ប្រាក់ យុត៖**

**ឆ៖** ចាស។

**ស៖** ហើយក៏ត្រឹមត្រូវដែរឬទេ ដែលលោកស្រីប្រាប់យើងខ្ញុំថា ចម្លើយដែលបានឆ្លើយនោះនៅក្នុងកំណត់ហេតុទាំងបួន ដែលបានឆ្លើយឲ្យសហចៅក្រមស៊ើបអង្កេតនោះ គឺជាចម្លើយដ៏ពិតប្រាកដ។ តើត្រឹមត្រូវទេ?

**ឆ៖** ត្រឹមត្រូវ។

[១៥:១៧:៤៤]

**ស៖** នៅក្នុងឯកសារ D324/16 គេបានសួរលោកស្រីថា ម្សិលមិញលោកស្រីប្រាប់យើងខ្ញុំពីម្សិលមិញថា លោកស្រីទុកចិត្តលើបដិវត្តន៍ ហើយនិងស្វាមីភក្តិចំពោះបដិវត្តន៍។ តើការចាប់ប្តីរបស់លោកស្រី ធ្វើឲ្យលោកស្រីប្តូរចិត្តគំនិតអំពីបដិវត្តន៍ដែរឬទេ? ពេលនោះលោកស្រីឆ្លើយថា "ចាប់តាំងពីគេចាប់ប្តីខ្ញុំទៅ ខ្ញុំបាត់បង់ទំនុកចិត្តលើបដិវត្តន៍ហើយ ពីព្រោះខ្ញុំស្រលាញ់ប្តីខ្ញុំ។ ខ្ញុំមិនអាចនិយាយអ្វីបានទេ ប៉ុន្តែនៅក្នុងខ្លួនខ្ញុំ ខ្ញុំមានការអស់សង្ឃឹមណាស់"។ តើជាការអះអាងពិតទេកាលនោះនោះ?

[១៥:១៨:៣៩]

**ឆ៖** ខ្ញុំសូមឆ្លើយសំណួរ អំពីការចាប់ប្តីនេះ។ កាលមុនដំបូង គឺចាប់ហើយ ខ្ញុំមានការអស់សង្ឃឹមដែរ គឺកន្លងទៅ គឺប្តីស្រលាញ់ដែរ តែពេលចាប់ខ្ញុំក៏មិនប៊ានអារកាត់ចំពោះមុខអង្គការ។ អ៊ីចឹងខ្ញុំអត់ប៊ានទេ ចាប់ក៏ចាប់ទៅ។ តែក្រោយមកការធម្មតាទេ លោកដឹងថា ការស្រលាញ់ប្តីប្រពន្ធវាមានហើយ តែការដាច់ខាតដែរ គឺមានការធាតុលះបង់ចំពោះប្តី ពេលចាប់ហ្នឹង។ ហេតុនេះខ្ញុំអត់មាន ការសោកស្តាយអីទេ ព្រោះមានការលះបង់ទៅហើយ។ នេះខ្ញុំសូមជម្រាបខ្លីប៉ុណ្ណឹង។ ព្រោះកន្លងទៅខ្ញុំគិត

ខ្លួនឯងគឺអ៊ីចឹងកាលណាយើងធ្វើខ្លាំងក៏វាអត់ទៅដែរ។ អ៊ីចឹងខ្ញុំតាមដំណើរតាមអង្គការទៅចុះ ធ្វើយ៉ាងម៉េចក៏ធ្វើចុះ។ តែការពិតគឺប្ដីប្រពន្ធមានការស្រលាញ់គ្នាមែន តែខ្ញុំក៏មានធាតុលះបង់ខ្ពស់ដែរ។ នេះខ្ញុំសូមជម្រាបខ្ញុំបានរាយការណ៍ក្នុង-- បានទៅសង្កេតឲ្យឃើញច្បាស់លាស់ដែរបញ្ហានេះ ធាតុលះបង់គឺខ្ពស់ណាស់ ដោយសារប្ដីចាប់ គឺអត់មានយំ មានស្រែកអីទេ មានការអាណិតអាសូរអីទេពេលនោះ។ នេះខ្ញុំសូមជម្រាបត្រង់អ៊ីចឹងតែម្ដង។

**ស៖** គេក៏បានសួរលោកស្រីដែលថា សំណួរផ្សេងទៀតអំពីជំនឿរបស់របស់លោកស្រីលើបដិវត្តន៍។ គេសួរដូចជាសំណួរខាងក្រោមនេះ៖

"ថាតើជាខុស ឬត្រូវទេ ដែលគេបង្ខំមនុស្សឲ្យធ្វើការ?" តើលោកស្រីចាំទេ លោកស្រីឆ្លើយទៅចៅក្រមស៊ើបអង្កេតដូចម្ដេច ទៅសំណួរខាងដើមនេះ ដែលគេសួរថា តើត្រូវ ឬខុសដែលគេបង្ខំឲ្យធ្វើការនោះ?

[១៥:២០:៥២]

**ឆ៖** ខ្ញុំសូមឆ្លើយ។ ការធ្វើការដែលយើងបង្ខំ គឺខ្ញុំក៏យល់ថាខុសដែរ។ មិនមែនថាត្រូវទេ ខុសត្រង់ថា យើងឲ្យគ្នាធ្វើហ្នឹង គឺវាខ្លាំងដែរអ៊ីចឹង ខ្ញុំក៏មិនយល់ថាត្រូវដែរកាលសម័យនោះ។ ឲ្យបង្ខំមនុស្សដែរ តែខ្ញុំក៏នឹកឃើញថា ខាងលើដាក់ផែនការឲ្យធ្វើម៉េច ក៏ធ្វើអ៊ីចឹងទៅ វាមិនអាច មិនហ៊ានថាយ៉ាងម៉េចទេ។ នេះសូមជម្រាបអ៊ីចឹង។

**ស៖** គេក៏បានសួរលោកស្រីដែរ ថាតើអ្នកដែលមិនអាចអប់រំកែប្រែបាន គេយកទៅធ្វើអ្វី? គេសួរលោកស្រីថា "តើគេត្រូវចាប់អ្នកហ្នឹង? គេសម្លាប់អ្នកហ្នឹង? ឬក៏គេធ្វើអ្វីលើអ្នកហ្នឹង?" តើលោកស្រីបានឆ្លើយម៉េចទៅនឹងសំណួរហ្នឹងអង្កាល់ណោះ?

[១៥:២២:០៧]

**ឆ៖** ខ្ញុំសូមឆ្លើយ។ អង្កាល់នោះ ខ្ញុំ-- គាត់បានសួរ តែយើងកាលនោះ ខ្ញុំបាននិយាយខ្លះការចាប់ការសម្លាប់អី គឺអត់មានទេ គឺមានការអប់រំនៅក្នុងស្រុក។ ចាប់យកទៅចង អ៊ំ ទៅសម្លាប់អី ឬយ៉ាងលើឲ្យយកទៅអីក៏អត់ដែរ ព្រោះខ្ញុំក៏មិនអារកាត់យកទៅសម្លាប់ទេ ព្រោះការខុសឆ្គងបន្តិចបន្តួច យើងយកទៅសម្លាប់មនុស្សក៏មិនកើតដែរ។ នេះខ្ញុំឆ្លើយតាមហ្នឹងដែរតើកាលនោះ។ សូមអស់។

**ស៖** ដូច្នេះលោកស្រីប្រាប់តុលាការថ្ងៃនេះថា នៅត្រឹមថ្នាក់របស់លោកស្រីធ្វើការនោះមិនមានការកាប់សម្លាប់ មិនការចាប់មនុស្សទេ ដែលថាមានការចាប់ ការយកទៅសម្លាប់នោះ គឺនៅថ្នាក់លើ

ដែលលោកស្រីធ្វើការទេ។ តើអ៊ីចឹងឬទេ?

**ឆ៖** ចាស ពិត។ នេះជារឿងពិត ខ្ញុំបាន--

**ស៖** គេបានសួរលោកស្រីថា ថាកាលដែលសម្លាប់មនុស្ស គឺជាដំណាក់កាលចុងក្រោយនៃការអប់រំ។ ហើយលោកស្រីបានឆ្លើយថា "ខ្ញុំមិនបានទទួលការខុសត្រូវលើការសម្លាប់ទេ។ ការសម្លាប់គឺជាការទទួលខុសត្រូវរបស់ថ្នាក់លើ កាលណាមនុស្សខុសហើយ ថ្នាក់លើរៀបចំ ដើម្បីបញ្ជូនអ្នកហ្នឹងទៅថ្នាក់លើដើម្បីទៅធ្វើការអប់រំ ឬក៏ដែលថ្នាក់ជាអ្នកអប់រំ អ្នកចាត់ចែង"។ តើការណ៍ហ្នឹងត្រឹមត្រូវអ៊ីចឹងដែរឬទេ?

[១៥:២៤:០០]

**ឆ៖** ត្រឹមត្រូវ។

**ស៖** ដូច្នេះលោកស្រីបញ្ជាក់ថា ព័ត៌មានដែលលោកស្រីបានឆ្លើយ ប្រហែលជាពីរឆ្នាំទៅហើយទៅឲ្យសហចៅក្រមស៊ើបអង្កេតនោះ គឺត្រឹមត្រូវ ពិតប្រាកដ ទោះបីជាលោកមិនចាំសេចក្ដីលម្អិតទាំងអស់នៅតុលាការនោះក៏ដោយ។ តើអ៊ីចឹងទេ ដែលលោកស្រីបញ្ជាក់ថ្ងៃនេះនោះ?

**ឆ៖** ចាស។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រីចៅក្រម។

ជាបន្តអង្គជំនុំជម្រះ សូមផ្ដល់វេទិកាទៅក្រុមមេធាវីការពារក្ដីលោក អៀង សារី ដើម្បីមានឱកាសនៅក្នុងការសាកសួរទៅដល់សាក្សីរូបនេះ ប្រសិនបើមានសំណួរ។

សូមអញ្ជើញ!

[១៥:២៥:០០]

**លោក អាង ឧត្តម៖**

សូមគោរពលោកចៅក្រមប្រធាន សូមគោរពលោក លោកស្រីចៅក្រមសមាជិក សូមគោរពអង្គសវនាការ។ សួស្ដីលោកអ្នកទាំងឡាយដែលចូលរួមសវនាការនៅក្នុងបន្ទប់ និងក្រៅបន្ទប់សវនាការនេះ។

សហមេធាវីការពារក្តីលោក អៀង  សារី នេះប្រកាន់ជំហរមិនសួរសំណួរសាក្សីនេះទេ។ សូមតុលាការជ្រាប។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ ជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផនដើម្បីមានឱកាសក្នុងការតាំងសំណួរចំពោះសាក្សីរូបនេះ ប្រសិនបើខ្លួនមានបំណងក្នុងការសួរ។

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន សូមគោរពក្រុមប្រឹក្សាជំនុំជម្រះ សូមគោរពអង្គសវនាការ។ នៅពេលបច្ចុប្បន្ននេះ។ ឥឡូវនេះក្រុមមេធាវីការពារលោក ខៀវ សំផន ពុំមានសំណួរសម្រាប់សាក្សីលោកស្រី ប្រាក់ យុត ទេ ក៏ប៉ុន្តែបើសិនក្រុមប្រឹក្សាអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណីសួរនៅពេលក្រោយ ខ្ញុំនឹងបាទនឹងសុំសិទ្ធិចំពោះការត្រួតពិនិត្យទៅលើសំណួរ   ឬក៏អាចលើកជាសំណួរតទៅទៀតក្នុងករណីដែលជាប់ពាក់ព័ន្ធ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ឥឡូវនេះកិច្ចដំណើរការសវនាការស្តាប់សក្ខីកម្មសាក្សី ប្រាក់ យុត ឃើញថាដល់ទីបញ្ចប់ហើយ ហើយដោយពេលវេលាសមល្មមនឹងសម្រាកដែលហើយ។

[១៥:២៦:៥៣]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:២៩:១៤]

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះអង្គជំនុំជម្រះបន្តនូវដំណើរការសវនាការបន្តិចទៀត  ដោយមូលដ្ឋានមានបញ្ហាមិនទាន់ជ្រះស្រឡះនូវឡើយ  ដែលពាក់ព័ន្ធទៅនឹងការប៉ុនប៉ងក្នុងការតាំងសំណួរចំពោះសាក្សីនេះ  ដោយមេធាវីដើមបណ្តឹងរដ្ឋប្បវេណីតំណាងឲ្យ  ទទួលសិទ្ធិពីមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី  ដើម្បីឲ្យមានមូលដ្ឋានកាន់តែច្បាស់ទៅលើបញ្ហានេះ  សូមផ្តល់វេទិកាទៅលោកចៅក្រម  ហ្សង់ម៉ាក  ដើម្បីសួរបញ្ជាក់បញ្ជាក់បញ្ហានេះឲ្យច្បាស់លាស់។

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក!

[១៥:៣០:០០]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណលោកប្រធាន។ ជាដំបូងអង្គជំនុំជម្រះចង់ដឹងថា ខ្លួនយល់ច្បាស់អត់បញ្ហាអំមិញនេះ ហើយឯកសារដែលខាងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីយោងនោះគឺមានជាភាសាខ្មែរ ឬក៏ភាសាមួយទៀតនៃតុលាការ គឺអង់គ្លេស ឬក៏បារាំង។ ហើយឯកសារខ្លះគឺអត់មានជាបីភាសាទេ តើមែនទេ? អ៊ីចឹងយ៉ាងហោចណាស់ក៏មានឯកសារខ្លះជាភាសាខ្មែរ ឬក៏ផ្សេងទៀតជាបារាំង និងអង់គ្លេស?

**កញ្ញា ហ្វីលីពីន ស៊ុតហ្ស៍៖**

ពិតជាអ៊ីចឹងហើយ។

**លោក អាកទួរ វែកគែន៖**

លោកចៅក្រមខ្ញុំចង់ឲ្យយើងបញ្ជាក់អំពីលេខយោងទាំងអស់នេះ ពីព្រោះថាដើមបណ្តឹងរដ្ឋប្បវេណីគឺថាបានលើកឡើងអំពីការបកប្រែតែសេចក្តីសង្ខេបទេ គឺមិនបានលើកអំពីឯកសារដែលខ្លួនចង់បង្ហាញជូនទៅកាន់សាក្សីទេ លោកប្រធាន។

[១៥:៣០:៥០]

**កញ្ញា ហ្វីលីពីន ស៊ុតហ្ស៍៖**

ពិតណាស់ គឺយើងចង់បង្ហាញសេចក្តីសង្ខេបនេះ គឺថានៅក្នុងសំណុំរឿងមានពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមានជាភាសាខ្មែរ ហើយការសង្ខេបគឺធ្វើជាភាសាអង់គ្លេស ដោយអង្គភាពការពារជនរងគ្រោះ ហើយការសង្ខេបនេះ មួយចំនួនត្រូវបានបកប្រែជាភាសាបារាំងផងដែរ។ ហើយឯកសារមួយចំនួនទៀតអត់មានជាភាសាបារាំងទេ។ ហើយឯកសារដែលខ្ញុំចង់យោងទៅនេះ គឺថាមិនត្រូវបានបកប្រែជាភាសាបារាំងទេ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

អ្វីដែលខ្ញុំចង់ដឹងនោះគឺថា តើលោកស្រីចង់ប្រើប្រាស់សេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ហើយអ្នកណាជាអ្នកសង្ខេបពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនេះ។

**កញ្ញា ហ្វីលីពីន ស៊ុតហ្ស៍៖**

គឺយើងយោងទៅលើឯកសារពីរគឺថា យើងមិនធ្វើការជាភាសាខ្មែរទេ គឺយើងទៅលើសេចក្តីសង្ខេបជាភាសាអង់គ្លេស។ ដូច្នេះយើងអាចមើលជាភាសាខ្មែរបាន ពីព្រោះឯកសារខ្មែរជាឯកសារ

ពេញលេញគឺអត់មានសង្ខេបទេ។

[១៥:៣១:៥៧]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

តើឯកសារជាភាសានោះមានតែជាភាសាខ្មែរ ឬមានជាភាសាខ្មែរ ហើយមានជាភាសាអីផ្សេងទៀតដែរ?

**កញ្ញា ហ្វីលីពីន ស៊ុតហ្ស៍៖**

លោកចៅក្រម គឺថាឯកសារទាំងស្រុងមានតែជាភាសាខ្មែរទេ អត់មានជាភាសាអីផ្សេងទៀតទេ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:៣៣:១១]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន ខ្ញុំចង់ផ្ដល់ការបញ្ជាក់ជូនមួយចំនួន ពីព្រោះថាវាជាសេចក្ដីប្រកាសព័ត៌មានដែលមាននៅក្នុងពាក្យសុំតាំងខ្លួនរដ្ឋប្បវេណី ហើយដែលដាក់ និងបំពេញដោយដើមបណ្ដឹងរដ្ឋប្បវេណី ហើយមិនមានការបកប្រែជាភាសាផ្សេងៗទៀតទេ ពីព្រោះថាកាលពីសម័យនោះគឺថាមិនមានការអនុញ្ញាតឲ្យមានការបកប្រែទេ។ គឺយើងមិនអាចធ្វើការបកប្រែឯកសារទាំងអស់ហ្នឹងទេ។

ខ្ញុំសូមបញ្ជាក់ថារវាងពាក្យសុំតាំងខ្លួន ហើយនិងពាក្យបណ្ដឹង គឺថាមានប្រហែលជាប្រាំបីពាន់ឯកសារឯណោះនៅពេលសម័យនោះ។ ហើយគឺដើម្បីឲ្យវាមានភាពជឿជាក់ទៅលើឯកសារទាំងអស់នេះ ហើយនិងយថាភាពនៃឯកសារទាំងអស់នេះ គឺឯកសារទាំងអស់នេះ គឺជាមូលដ្ឋានសម្រាប់ចៅក្រមស៊ើបអង្កេត ហើយបន្ទាប់សម្រាប់អង្គបុរេជំនុំជម្រះដើម្បីប្រកាសអំពីភាពដែលអាចទទួលយកបាននៃដើមបណ្ដឹងរដ្ឋប្បវេណីទាំង ៣៩០០នាក់។ ដូច្នេះឯកសារនោះមានភាពជឿជាក់បាន ហើយអាចប្រើជាមូលដ្ឋានសម្រាប់ការសួរសំណួរ។

[១៥:៣៤:១៧]

ខ្ញុំសូមបញ្ជាក់ថាសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះទៅលើការប្រើប្រាស់ឯកសារ វាមានសារៈសំខាន់ណាស់ ពីព្រោះថាយើងបានដាក់ឯកសារទាំងអស់នោះចូលទៅក្នុងសំណុំរឿងហើយ។ ហើយចុះ

លេខយោងត្រឹមត្រូវ ហើយយើងនឹងផ្តល់លេខនេះឲ្យបានច្បាស់លាស់នៅពេលក្រោយ។ ហើយបើយោងតាមវិធាន៨៧ គឺថាបើសិនយើងអាច-- យើងប្រើប្រាស់ឯកសារនោះយើងអាចលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះ។ ដូច្នេះបញ្ហាកើតមាននៅថ្ងៃនេះពាក់ព័ន្ធទៅនឹងសាក្សីរូបនេះ ហើយនិងមានបញ្ហាសម្រាប់ថ្ងៃក្រោយទៀត សម្រាប់សាក្សីផ្សេងទៀត ពីព្រោះថានៅពេលក្រោយនោះ គឺមានការប្រើប្រាស់ឯកសាររបៀបនេះទៀតនៅក្នុងអង្គជំនុំជម្រះ។

[១៥:៣៥:០៤]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:៣៦:១៣]

**ប្រធានអង្គជំនុំ៖**

ក្រោយពីបានសួរបញ្ជាក់ម្តងហើយម្តងទៀតទៅលើបញ្ហាឯកសារចំនួនពីរ ដែលមេធាវីដើមបណ្តឹងរដ្ឋប្បវេណីទទួលសិទ្ធិពីមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ប៉ុនប៉ងក្នុងការស្នើសុំដាក់បង្ហាញសួរសំណួរពាក់ព័ន្ធទៅនឹងសាក្សីរូបនេះ ដោយមូលហេតុឯកសារនេះមានតែមួយភាសានោះ អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យធ្វើការបង្ហាញដើម្បីតាំងសំណួរនោះឡើយ។

[១៥:៣៧:០៣]

បាទ ឥឡូវនេះដំណើរការសវនាការសវនាការស្តាប់សក្ខីកម្មសាក្សី ប្រាក់ យុត ឃើញដល់ទីបញ្ចប់ហើយ ហើយពេលវេលាក៏សមល្មមនឹងសម្រាកដែរ។

ហើយអង្គជំនុំជម្រះសូមអរគុណលោកស្រី ប្រាក់ យុត ដែលបានអញ្ជើញចូលមកផ្តល់សក្ខីកម្មតាមការកោះហៅរបស់អង្គជំនុំជម្រះ។ ហើយកិច្ចដំណើរការសវនាការក្នុងការស្តាប់សក្ខីកម្មរបស់លោកស្រីចប់ហើយ ហើយអង្គជំនុំជម្រះមិនមានតម្រូវក្នុងការស្តាប់សក្ខីកម្មរបស់លោកស្រីតទៅទៀតទេ។ ហេតុដូច្នេះលោកស្រីអាចវិលត្រឡប់ទៅលំនៅដ្ឋាន ឬក៏ទៅគោលដៅរបស់លោកស្រីដែលចង់ទៅបានហើយ។ ហើយក្រោយពេលចប់មន្ត្រីច្បាប់សម្របសម្រួលជូនគាត់ទៅប្រគល់ជូនទៅដល់មន្ត្រីអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ដើម្បីនាំគាត់ទៅរកកន្លែងស្នាក់នៅ ហើយនិងបញ្ជូនគាត់ទៅកាន់លំនៅដ្ឋានទៅកន្លែងដែលគាត់ចង់ទៅដោយសុវត្ថិភាព។

ឥឡូវនេះដល់ពេលសម្រាកហើយ ហើយសម្រាប់ថ្ងៃនេះ។ ដូច្នេះអង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសម្រាប់ថ្ងៃនេះត្រឹមនេះ ហើយសវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែកចាប់ពីវេលាម៉ោងប្រាំ

ប្អូនព្រឹក។

អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទាំងបីរូបទៅកាន់មន្ទីរឃុំឃាំងនៃអ.វ.ត.ក វិញចុះ ហើយបង្គាប់ឲ្យនាំខ្លួនពួកគាត់ទាំងបីរូបមកកាន់បន្ទាប់សវនាការនេះ នៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន៕

*(សវនាការផ្អាកនៅម៉ោង១៥:៣៨នាទី)*